វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវ
ដើម្បីអភិវឌ្ឍន៍កម្ពុជា (វបសអ)

# សង្ខេប
# របាយការណ៍អភិវឌ្ឍន៍
# ប្រចាំឆ្នាំ២០១២-១៣





ការបោះពុម្ពផ្សាយរបស់វិទ្យាស្ថាន វបសអ

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវ
ដើម្បីអភិវឌ្ឍន៍កម្ពុជា (វបសអ)

# សង្ខេប
# របាយការណ៍អភិវឌ្ឍន៍
# ប្រចាំឆ្នាំ២០១២-១៣

*Annual Development Review*
*2012 - 2013*

ភ្នំពេញ ខែកុម្ភៈ ឆ្នាំ២០១៣

ក្នុងលក្ខណៈជា វិទ្យាស្ថានឯករាជ្យមួយរបស់កម្ពុជា ខាងការស្រាវជ្រាវពីគោលនយោបាយអភិវឌ្ឍន៍ CDRI មានបេសកកម្មចូលរួមចំណែកដល់ការអភិវឌ្ឍន៍ ប្រទេសកម្ពុជាប្រកបដោយចីរភាព និងការលើកកម្ពស់សុខុមាលភាពរបស់ប្រជាពលរដ្ឋកម្ពុជា តាមរយៈការស្រាវជ្រាវមានគុណភាពខ្ពស់ពីគោលនយោបាយអភិវឌ្ឍន៍ ការផ្សព្វផ្សាយចំណេះដឹង និងការកសាងសមត្ថភាព។

CDRI ប្រឹងប្រែងបំពេញបេសកកម្មនេះ ដោយធ្វើការងារជាដៃគូជាមួយស្ថាប័នសាធារណៈ និងសង្គមស៊ីវិលកម្ពុជា ស្ថាប័នអភិវឌ្ឍន៍ក្នុងតំបន់ និងពិភពលោក និងដោយគោរពដល់សមត្ថភាពរបស់ប្រជាពលរដ្ឋ និងស្ថាប័នកម្ពុជា ចំណេះដឹង និងបទពិសោធន៍ក្នុងស្រុក ព្រមទាំងប្រវត្តិសាស្ត្រ និងវប្បធម៌របស់ប្រទេសកម្ពុជា ។

**© រក្សាសិទ្ធិឆ្នាំ២០១៣ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**

រក្សាសិទ្ធិគ្រប់យ៉ាង - គ្មានផ្នែកណាមួយនៃឯកសារនេះ ត្រូវបានចម្លងទុក ឬផ្សព្វផ្សាយតាមទម្រង់ និងតាមមធ្យោបាយផ្សេងៗដូចជាអេឡិចត្រូនិក យន្តកម្មថតចម្លង...។ល។ដោយគ្មានការអនុញ្ញាតជាលាយល័ក្ខណ៍អក្សរពីវិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជាឡើយ ។

ISBN-13: 978–99950–52–68-3

**សង្ខេបរបាយការណ៍អភិវឌ្ឍន៍ប្រចាំឆ្នាំ២០១២-២០១៣**
*Annual Development Review 2012-13*
ភ្នំពេញ ខែកុម្ភៈ ឆ្នាំ២០១៣

**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**

☞ អគារលេខ ៥៦ ផ្លូវលេខ ៣១៥

✉ ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា

☏ ទូរស័ព្ទ៖ (៨៥៥ ២៣) ៨៨១ ៣៨៤, ៨៨១ ៧០១, ៨៨១ ៩១៦, ៨៨៣ ៦០៣

🖷 ទូរសារ៖ (៨៥៥ ២៣) ៨៨០ ៧៣៤

អ៊ីមែល៖ cdri@cdri.org.kh
គេហទំព័រ៖ www.cdri.org.kh

កែសម្រួល និងរចនាដោយ៖ អ៊ុំ-ចាន់ថា និង យូ សិទ្ធីរិទ្ធ
បកប្រែដោយ៖ ខេង-សេង
បោះពុម្ពនៅប្រទេសកម្ពុជា ដោយ សាលាបច្ចេកទេសដុនបូស្កូ ភ្នំពេញ

# មាតិកា


បញ្ជីរូបភាព និងតារាង ............ vi
បញ្ជីអក្សរកាត់ ............ vii

**១. ស្ថានភាពសេដ្ឋកិច្ច និងបញ្ហាប្រឈមលើការអភិវឌ្ឍ** ............ 1

១.១ សេដ្ឋកិច្ចនៅឆ្នាំ២០១២ ............ 1
១.២ ស្ថានភាពសេដ្ឋកិច្ចទូទៅសម្រាប់ឆ្នាំ២០១៣ ............ 3
១.៣ ទស្សនវិស័យរយៈពេលវែង និងបញ្ហាប្រឈមលើការអភិវឌ្ឍ ............ 4
គន្ថនិទ្ទេស ............ 8

**២. ទស្សនៈរបស់ប្រជាពលរដ្ឋអំពីទំនួលខុសត្រូវរបស់ខ្លួនៈ ការវិភាគបឋម ពីការរួមចំណែកនៃ គំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ នៅក្នុងទំនាក់ទំនងជាបដិការរវាងរដ្ឋ និងសង្គម នៅខេត្តបាត់ដំបង** ............ 9

២.១ សេចក្តីផ្តើម ............ 9
២.២ លទ្ធផលរកឃើញជាដំបូងៗ ............ 11
២.២.១ ទស្សនៈរបស់ប្រជាពលរដ្ឋចំពោះរដ្ឋ ............ 11
២.២.២ ឥរិយាបថប្រជាពលរដ្ឋចំពោះទំនួលខុសត្រូវរបស់ខ្លួន ............ 11
២.២.៣ ភាពពេញចិត្តរបស់ប្រជាពលរដ្ឋចំពោះសេវារដ្ឋផ្តល់ឲ្យ ............ 14
២.៣ សេចក្តីសន្និដ្ឋាន ............ 15
ឯកសារយោង ............ 15

**៣. រចនាសម្ព័ន្ធអប់រំថ្នាក់ឧត្តមសិក្សានៅកម្ពុជា និងការជំពាក់ទាក់ទងជាមួយ សហគមន៍សេដ្ឋកិច្ចអាស៊ានឆ្នាំ២០១៥** ............ 17

៣.១ សេចក្តីផ្តើម ............ 17
៣.២ រចនាសម្ព័ន្ធប្រព័ន្ធអប់រំថ្នាក់ឧត្តមសិក្សានៅកម្ពុជា ............ 17
៣.២.១ ការសម្របសម្រួល ការប្រើប្រាស់ធនធាន និង ការអនុវត្តនិងត្រួតពិនិត្យ គោលនយោបាយអប់រំ ............ 19
៣.២.២ ភាពជាប់ទាក់ទងល្អ និងគុណភាពនៃការអប់រំ ............ 19
៣.២.៣ លទ្ធភាពទទួលបានការងារធ្វើក្រោយបញ្ចប់ការសិក្សា និងបញ្ហា សង្គមពាក់ព័ន្ធ ............ 20
៣.៣ តើសហគមន៍សេដ្ឋកិច្ចអាស៊ានឆ្នាំ២០១៥ មានពាក់ព័ន្ធដូចម្តេចជាមួយ ប្រព័ន្ធ អប់រំថ្នាក់ឧត្តមសិក្សានៅកម្ពុជានាបច្ចុប្បន្ន? ............ 21

៣.៤ សេចក្តីសន្និដ្ឋាន ........ 22
ឯកសារយោង ........ 23

**៤. និន្នាការនៃការចុះកិច្ចសន្យាជួលសេវា ក្នុងវិស័យសុខាភិបាល នៅប្រទេសកម្ពុជា** ........ 24

៤.១ សេចក្តីផ្តើម ........ 24
៤.២ បទពិសោធន៍ចុះកិច្ចសន្យានៅកម្ពុជា ........ 25
៤.២.១ ដំណាក់កាលទី១ នៃការចុះកិច្ចសន្យា៖ ដំណាក់កាលសាកល្បង ........ 25
៤.២.២ ដំណាក់កាលទី២ នៃការចុះកិច្ចសន្យា ........ 26
៤.២.៣ ដំណាក់កាលទី៣ នៃការចុះកិច្ចសន្យា៖ ទីភ្នាក់ងារប្រតិបត្តិការពិសេស ........ 26
៤.៣ ការពិភាក្សា ........ 28
៤.៤ សេចក្តីសន្និដ្ឋាន ........ 30
គន្ថនិទ្ទេស ........ 31

**៥. ការឡើងថ្លៃម្ហូបអាហារនៅប្រទេសកម្ពុជា៖ មូលហេតុ ផលប៉ះពាល់ និង គោលនយោបាយឆ្លើយតប** ........ 32

៥.១ សេចក្តីផ្តើម ........ 32
៥.២ ទ្រឹស្តី និងវិធីសាស្ត្រស្រាវជ្រាវ ........ 33
៥.៣ មូលហេតុនៃការឡើងថ្លៃម្ហូបអាហារ ........ 34
៥.៤ ផលប៉ះពាល់នៃការឡើងថ្លៃម្ហូបអាហារ ........ 36
៥.៥ គោលនយោបាយឆ្លើយតប ........ 38
៥.៦ សង្ខេបលទ្ធផលសំខាន់ៗ សេចក្តីសន្និដ្ឋាន និងជម្រើសគោលនយោបាយ ........ 40
គន្ថនិទ្ទេស ........ 43

**៦. ការសម្រាលផលប៉ះពាល់នៃវិបត្តិហិរញ្ញវត្ថុសាកល ទៅលើទីផ្សារពលកម្មនៅជនបទកម្ពុជា** ........ 45

៦.១ សេចក្តីផ្តើម ........ 45
៦.២ វិបត្តិ និងឥទ្ធិពលលើទីផ្សារពលកម្មនៅជនបទ ........ 45
៦.៣ ឥទ្ធិពលលើអត្រាចូលរួមបម្រើការងារ ........ 45
៦.៤ ឥទ្ធិពលលើប្រាក់ចំណូល ........ 46
៦.៥ ឥទ្ធិពលលើចំណាកស្រុក ........ 46
៦.៦ គោលនយោបាយឆ្លើយតប ........ 46
៦.៧ សន្និដ្ឋាន ........ 47
ឯកសារយោង ........ 48

**៧. ការវាយតម្លៃពីផលប្រយោជន៍នៃអង្គការកសិករ ទៅលើផលិតភាពកសិកម្ម៖ ភស្តុតាងបានពីអង្កេតគ្រួសារនៅតំបន់ជនបទកម្ពុជា** ..... 49

៧.១ សេចក្តីផ្តើម ..... 49
៧.១.១ ប្រវត្តិដើម ..... 49
៧.១.២ គោលបំណង ..... 50
៧.១.៣ វិធីសាស្ត្រ ..... 50
៧.២ លទ្ធផលស្រាវជ្រាវជាក់ស្តែង ..... 50
៧.២.១ ការវិភាគពីចរិតលក្ខណៈនៃការចូលរួមក្នុង FOs ..... 50
៧.២.២ ឥទ្ធិពលនៃការចូលរួមក្នុង FO ទៅលើជីវភាព ..... 52
៧.៣ សេចក្តីសន្និដ្ឋាន និងភាពជំពាក់ទាក់ទងផ្នែកគោលនយោបាយ ..... 54
៧.៣.១ ភាពជំពាក់ទាក់ទងខាងគោលនយោបាយ ..... 55
គន្ថនិទ្ទេស ..... 55

**បញ្ជីឯកសារបោះពុម្ពផ្សាយរបស់វិទ្យាស្ថាន CDRI** ..... 57

# បញ្ជីរូបភាព និងតារាង


រូបភាព ១.១៖ ការនាំចេញ និងកំណើនឧស្សាហកម្ម ........................................................ 2
រូបភាព ១.២៖ ចំណូលក្នុងមនុស្សម្នាក់ក្រោមសេណារីយ៉ូកំណើនខុសៗគ្នា ............................. 6

រូបភាព ៥.១៖ សន្ទស្សន៍ថ្លៃទំនិញនៅទីផ្សារអន្តរជាតិ ....................................................... 34
រូបភាព ៥.២៖ អតិផរណាប្រចាំខែ ឆ្នាំ១៩៩៨-២០១១ ..................................................... 35

តារាង ៥.១៖ ផលប៉ះពាល់ទៅលើសុខមាលភាពដោយសារការឡើងថ្លៃអង្ករ ........................ 37
តារាង ៥.២៖ ផលប៉ះពាល់ទៅលើសុខមាលភាពដោយសារការឡើងថ្លៃម្ហូបអាហារ ............... 37
តារាង ៥.៣៖ ផលប៉ះពាល់ទៅលើភាពក្រីក្រដោយសារ ការឡើងថ្លៃម្ហូបអាហារ..................... 38
តារាង ៥.៤៖ ផលប៉ះពាល់ទៅលើភាពក្រីក្រដោយសារ ការឡើងថ្លៃអង្ករ ............................. 38

តារាង ៧.១៖ ការគណនាពី ទំនោរសម្រាប់ការចូលរួមក្នុង FO ( Logit Estimation for Pooled Samples )..............................................................................................51
តារាង ៧.២៖ ឥទ្ធិពលប្រព្រឹត្តកម្មជាមធ្យមនៃវិធីសាស្ត្រ PSM សំរាប់ដំណាំស្រូវ .................... 53
តារាង ៧.៣៖ ឥទ្ធិពលប្រព្រឹត្តិកម្មជាមធ្យមនៃវិធីសាស្ត្រ PSM សម្រាប់ការចិញ្ចឹមសត្វ............ 53

# បញ្ជីអក្សរកាត់

| | | |
|---|---|---|
| AC | សហករណ៍កសិកម្ម (Agricultural Cooperative) |
| AEC | សហគមន៍សេដ្ឋកិច្ចអាស៊ាន (ASEAN Economic Community) |
| AFD | ទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍ (Agence Française de Développement) |
| BTC | អង្គការសហប្រតិបត្តិការបច្ចេកទេសបែលហ្ស៊ិក (Belgium Technical Cooperation) |
| CC | ក្រុមប្រឹក្សាឃុំ (Commune council) |
| CDRI | វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (Cambodia Development Resource Institute) |
| CSF | មូលនិធិឃុំសង្កាត់ (Commune/Sangkat Fund) |
| D&D | វិមជ្ឈការ និងវិសហមជ្ឈការ (Decentralisation and Deconcentration) |
| DFID UK | ក្រសួងអភិវឌ្ឍន៍អន្តរជាតិអង់គ្លេស (Department for International Development, UK) |
| DHE | នាយកដ្ឋានឧត្តមសិក្សា (Department of Higher Education) |
| EIC | វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា (Economic Institute of Cambodia) |
| FA | សមាគមកសិករ (Farmer Association) |
| FG | ក្រុមកសិករ (Farmer Group ) |
| FGD | ការពិភាក្សាតាមក្រុមស្នូល (Focus Group Discussions) |
| FO | អង្គការកសិករ (Farmer Organisation) |
| HCMC | គណៈកម្មាធិការគ្រប់គ្រងមណ្ឌលសុខភាព (Health Centre Management Committee) |
| HEF | មូលនិធិសមធម៌សុខភាព (Health Equity Fund) |
| HEIs | គ្រឹះស្ថានអប់រំថ្នាក់ឧត្តមសិក្សា (Higher Education Institution) |
| HSSP | គម្រោងទ្រទ្រង់វិស័យសុខាភិបាល (Health Sector Support Project) |
| IMF | មូលនិធិរូបិយវត្ថុអន្តរជាតិ (International Monetary Fund) |
| IRI | វិទ្យាស្ថានសាធារណរដ្ឋអន្តរជាតិ (International Republican Institute) |
| MoEYS | ក្រសួងអប់រំ យុវជន និងកីឡា (Ministry of Education, Youth and Sport) |
| MoLVT | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (Ministry of Labour and Vocational Training) |
| MPA | កញ្ចប់សកម្មភាពអប្បរមា (Minimum Package of Activity) |
| NIPH | វិទ្យាស្ថានជាតិសុខភាពសាធារណៈ (National Institute of Public Health) |
| OD | ស្រុកប្រតិបត្តិ (Operational District) |
| PDA | មន្ទីរកសិកម្មខេត្ត (Provincial Department of Agriculture) |
| PIC | មជ្ឈមណ្ឌលព័ត៌មានសាធារណៈ (Public Information Centre) |
| SNCE | ឧត្តមក្រុមប្រឹក្សាអប់រំជាតិ (Supreme National Council of Education) |
| SOA | ទីភ្នាក់ងារប្រតិបត្តិការពិសេស (Special Operating Agency) |
| UNFPA | មូលនិធិប្រជាជនអង្គការសហប្រជាជាតិ (United Nations Population Fund) |
| VAR | Vector Auto- Regression |
| VHSG | ក្រុមការងារទ្រទ្រង់សុខភាពតាមភូមិ (Village Health Support Group) |
| WB | ធនាគារពិភពលោក (World Bank) |

-១-

# ស្ថានភាពសេដ្ឋកិច្ច និងបញ្ហាប្រឈមលើការអភិវឌ្ឍ

*ដោយ បណ្ឌិត តុង គឹមស៊ុន និង បណ្ឌិត Srinivasa Madhur*[១]

## ១.១ សេដ្ឋកិច្ចនៅឆ្នាំ ២០១២

សេដ្ឋកិច្ចកម្ពុជា បន្តបង្កើនសន្ទុះ និងនៅរឹងមាំដដែល។ តាមការប៉ាន់ស្មាន ផសស កើន ៦,៥% នៅឆ្នាំ ២០១២ គឺយឺតជាងកំណើន ៧,១% កាលពីឆ្នាំមុនបន្តិច ប៉ុន្តែនៅតែខ្លាំងក្លា បើធៀបនឹងស្តង់ដារកំណើនក្នុងតំបន់។ ក្នុងអាស៊ានទាំងមូល មានតែប្រទេសឡាវមួយប៉ុណ្ណោះ ដែលមានកំណើនលឿនជាងកម្ពុជា កាលពីឆ្នាំកន្លងទៅ។ ក្នុងសេដ្ឋកិច្ចកម្ពុជា មាននិន្នាការបញ្ច្រាសគ្នាពីរនៅកម្រិតវិស័យ។ កំណើនផលិតកម្មកសិកម្ម ដែលបានធ្លាក់ចុះដល់ ៣% នៅឆ្នាំ២០១១ ដោយសារទឹកជំនន់ធ្ងន់ធ្ងរមិនធ្លាប់មាននោះ បានឡើងដល់អត្រាដូចក្នុងនិន្នាការរយៈពេលវែងវិញ គឺ ៤,៥% នៅឆ្នាំ២០១២។ ផ្ទុយទៅវិញ កំណើនផលិតផលមិនមែនកសិកម្ម បានថយចុះប្រហែល ១,៤ ឯកតាភាគរយ ពី ៨,៦% នៅឆ្នាំ២០១១ មកត្រឹម ៧,២% នៅឆ្នាំ២០១២។ ក្នុងវិស័យមិនមែនកសិកម្ម ផ្នែកសំណង់ហាក់ចូលរួមចំណែកខ្លាំងក្នុង ផសស ព្រោះមានកំណើនទាំងចំនួន និងតម្លៃនៃគម្រោងសាងសង់បានអនុម័ត ក្នុយរយៈពេល ១០ខែដំបូងនៃឆ្នាំ២០១២។

ការថយចុះកំណើនក្នុងវិស័យមិនមែនកសិកម្ម ជាពិសេសផលិតផលឧស្សាហកម្ម បណ្តាលជាចម្បងមកពីការធ្លាក់កំណើនក្នុងការនាំចេញ។ ការនាំចេញរបស់កម្ពុជា មានជាប់ទាក់ទងខ្លាំងទៅនឹងលទ្ធផលក្នុងវិស័យឧស្សាហកម្ម (រូបភាព ១.១)។ ការបន្តធ្លាក់កំណើនសេដ្ឋកិច្ចសាកលគួបផ្សំនឹង កំណើនទាបជាងការរំពឹងទុក នៅប្រទេសចិន និងតំបន់អាស៊ាន បានកាត់បន្ថយតម្រូវការផលិតផលនាំចេញរបស់កម្ពុជា។ ការនាំចេញ ដែលកើនឡើង ៣៦% នៅឆ្នាំ២០១១ បានធ្លាក់ចុះខ្លាំងវិញនៅឆ្នាំ២០១២ ដោយក្នុងរយៈពេល១០ខែដំបូង មានកំណើនត្រឹម ២៦% ប៉ុណ្ណោះ។ ការនាំចេញសម្លៀកបំពាក់ ដែលមានចំណែកជាង ៨០% ក្នុងការនាំចេញសរុបនោះ បានកើន ២១% ក្នុង ១០ខែដំបូងឆ្នាំ២០១២ ធៀបនឹង ៣៣% ក្នុងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។

ទោះបីការនាំចេញស្រូវមានកំណើនខ្លាំងដល់ ៣៩% ក្នុង ១០ខែដំបូងឆ្នាំ២០១២ ក្តី ក៏វាកើនយឺតណាស់ បើធៀបនឹងអត្រាកំណើនបីខ្ទង់កាលពីឆ្នាំ២០១១។ គិតជាបរិមាណវិញ ការនាំចេញស្រូវបានកើនពី ០,១៤លានតោន កាលពីឆ្នាំ២០១១ ដល់ប្រមាណ ០,១៦លានតោន ក្នុង ១០ខែដំបូងឆ្នាំ២០១២។ ពិនិត្យតាមនិន្នាការនាបច្ចុប្បន្ន ដើម្បីសម្រេចគោលដៅរបស់រដ្ឋាភិបាល ក្នុងការនាំចេញស្រូវឲ្យបាន ១លានតោនក្នុងមួយឆ្នាំ នៅឆ្នាំ២០១៥ ការនាំចេញស្រូវត្រូវកើនឡើងយ៉ាងខ្លាំងក្នុង ៣ឆ្នាំខាងមុខនេះ។ កន្លងមកមានលទ្ធផលគួរឲ្យពេញចិត្តមួយដែរ ព្រោះកម្ពុជាបានធ្វើពិពិធកម្មទីផ្សារនាំចេញស្រូវ គឺក្រៅពីទីផ្សារជាប្រពៃណី ដូចជា សហភាពអឺរ៉ុប នោះ កម្ពុជាឈានទៅកាន់ទីផ្សារថ្មីៗ ដូចជា តំបន់អាស៊ាន ជាដើម។

---

[១] បណ្ឌិត តុង គឹមស៊ុន ជាអ្នកស្រាវជ្រាវ និងអ្នកសម្របសម្រួលកម្មវិធីសេដ្ឋកិច្ច ពាណិជ្ជកម្ម និងសហប្រតិបត្តិការក្នុងតំបន់ ហើយបណ្ឌិត Srinivasa Madhur ជានាយកផ្នែកស្រាវជ្រាវ នៅវិទ្យាស្ថាន CDRI។

ក្នុង ១០ខែដំបូងឆ្នាំ២០១២ មានភ្ញៀវទេសចរ ២,៩លាននាក់ បានមកដល់កម្ពុជា។ ផ្អែកលើតួលេខនេះ ចំនួនប៉ាន់ស្មាននៃភ្ញៀវមកដល់សរុបសម្រាប់ពេញមួយឆ្នាំ២០១២ គឺ ៣,៥លាននាក់ ឬ កើន ១២,៥% ដែលទាបជាងអត្រាកំណើន ៣២% កាលពីឆ្នាំ២០១១។ តាមនេះ ចំណូលប៉ាន់ស្មានបានពីទេសចរណ៍ មានប្រហែល ២ពាន់លានដុល្លារ ដែលមានន័យថា អត្រាកំណើនចំណូលពីវិស័យនេះ ធ្លាក់ចុះស្ទើរអស់ពាក់កណ្តាល ពី ៣៧% នៅឆ្នាំ២០១១ មកត្រឹម ២០% នៅឆ្នាំ២០១២។ វិស័យទេសចរណ៍នៅកម្ពុជា កំពុងមានការផ្លាស់ប្តូរយ៉ាងជ្រាលជ្រៅ ដោយសមាសភាពភ្ញៀវទេសចរបានផ្លាស់ប្តូរពីភ្ញៀវមកពីបស្ចិមប្រទេស មកជាភ្ញៀវក្នុងតំបន់អាស៊ី ដែលបង្ហាញមួយផ្នែកពីកំណើនវិបុលភាពនៅអាស៊ីក្នុងប៉ុន្មានឆ្នាំថ្មីៗ។ ឧទាហរណ៍ នៅឆ្នាំ២០១២ វៀតណាម កូរ៉េខាងត្បូង ចិន ឡាវ និង ថៃ ជាប្រទេសទាំងប្រាំ ដែលមានភ្ញៀវទេសចរចូលមកកម្ពុជាច្រើនជាងគេ។

រូបភាព ១.១៖ ការនាំចេញ និងកំណើនឧស្សាហកម្ម




ដោយឆ្លុះបញ្ចាំងមួយផ្នែកនូវការថយចុះកំណើនក្នុងវិស័យឧស្សាហកម្ម និងសេវាកម្ម អតិផរណាបានថយចុះពីប្រហែល ៥% នៅឆ្នាំ២០១១ មកត្រឹម ៣,៤% ក្នុងឆ្នាំ២០១២ ។ និន្នាការនេះ បានបញ្ឈប់កំណើនការនាំចូល ប៉ុន្តែការថយចុះការនាំចូលនេះ វាមានទំហំតូចជាង ការធ្លាក់ចុះការនាំចេញ។ ជាលទ្ធផល ឱនភាពគណនីចរន្ត បានកើនឡើងពីប្រមាណ ១២% នៃ ផសស នៅឆ្នាំ២០១១ ដល់ជាង ១៣% នៅឆ្នាំ២០១២។ ដោយសារបំណុលខាងក្រៅរបស់កម្ពុជាមួយភាគធំមានរយៈពេលវែង ហើយធនបម្រុងជារូបិយវត្ថុបរទេសរបស់កម្ពុជាអាចប្រើប្រាស់សម្រាប់ទូទាត់ការនាំចូលបានប្រហែល ៤ខែ ដូច្នេះ ឱនភាពគណនីចរន្តនេះ ប្រហែលមិនប៉ះពាល់ខ្លាំងដល់ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនោះទេ។ តាមការប៉ាន់ស្មានរបស់ មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF 2013) ឱនភាពគណនីចរន្តនេះ អាចថយចុះបន្តិចម្តងៗ ក្នុងអនាគតដ៏ខ្លីខាងមុខ។

## ១.២ ស្ថានភាពសេដ្ឋកិច្ចទូទៅសម្រាប់ឆ្នាំ ២០១៣

ក្នុងលក្ខណៈជាសេដ្ឋកិច្ចបើកចំហតូចមួយ ស្ថានភាពសេដ្ឋកិច្ចកម្ពុជាក្នុងពេលចំពោះមុខ វាអាស្រ័យលើបរិយាកាសខាងក្រៅ។ ពិតហើយ សេដ្ឋកិច្ចកម្ពុជាហាក់ចាប់ផ្តើមមានកំណើនយឺត ចាប់តាំងពីពេលមានវិបត្តិហិរញ្ញវត្ថុសាកលឆ្នាំ២០០៨-០៩ មក ទោះជាមិនគិតបញ្ចូលនូវការធ្លាក់ចុះសេដ្ឋកិច្ចយ៉ាងគំហុកនៅឆ្នាំ២០០៩ ក្តី។ កំណើនសេដ្ឋកិច្ចចំនួនបួនឆ្នាំ ពីឆ្នាំ២០០៨-១២ (មិនគិតឆ្នាំ២០០៩) មានជាមធ្យមប្រហែល ៦,៦% ដែលទាបជាងអត្រាប្រចាំឆ្នាំជាមធ្យម ១១% ពីឆ្នាំ២០០៤-០៧ គឺនៅមុនពេលមានវិបត្តិសាកល។ ការថយចុះកំណើនមានលក្ខណៈកាន់តែធ្ងន់ធ្ងរថែមទៀត ក្នុងវិស័យមិនមែនកសិកម្ម ជាពិសេសវិស័យឧស្សាហកម្ម។ កំណើនប្រចាំឆ្នាំក្នុងវិស័យឧស្សាហកម្ម ដែលមានអត្រាជាមធ្យម ១៤% ពីឆ្នាំ២០០៤-០៧ បានធ្លាក់មកត្រឹម ៨,៥% ពីឆ្នាំ២០០៨-១២ (មិនគិតឆ្នាំ២០០៩)។ ដូច្នេះស្ថានភាពសេដ្ឋកិច្ចក្នុងពេលចំពោះមុខ វាផ្សារភ្ជាប់ជាខ្លាំងទៅនឹងកម្លាំងរើបឡើងវិញនៃសេដ្ឋកិច្ចសាកល។

នៅក្នុងឯកសារចេញផ្សាយនៅខែតុលា ២០១២ ស្តីពី អនាគតសេដ្ឋកិច្ចពិភពលោក IMF បានប៉ាន់ស្មានថា ផសស ពិភពលោក មានកំណើនប្រហែល ៣,៦% នៅឆ្នាំ២០១៣ ឬកើនឡើងបន្តិច បើធៀបនឹងកំណើន ៣,៣% នៅឆ្នាំ២០១២។ ជារួម តួលេខនេះបង្ហាញពីការកែតម្រូវបញ្ចុះយ៉ាងខ្លាំងនូវអត្រាកំណើន ផសស សាកល សម្រាប់ឆ្នាំ២០១៣ ដែល IMF បានបញ្ជាក់ថាមានកម្រិត ៣,៩% និង ៤,១% តាមការព្យាករណ៍កាលពីខែកក្កដា ២០១២ និង ខែមេសា ២០១២។ កំណើន ផសស នៅសហរដ្ឋអាមេរិក រំពឹងថា កើនលើស ២% បន្តិច នៅឆ្នាំ២០១៣ រីឯកំណើននៅតំបន់អឺរ៉ុប គេព្យាករណ៍ថាមានកម្រិតខ្សោយ ហើយ ផសស នៅប្រទេសជប៉ុន រំពឹងថានឹងធ្លាក់ចុះពី ២,២% នៅឆ្នាំ២០១២ មកត្រឹម ១,១% នៅឆ្នាំនេះ។ ការព្យាករណ៍សម្រាប់ប្រទេសមានសេដ្ឋកិច្ចកំពុងលេចធ្លោឡើងនៅអាស៊ី មានតួលេខល្អ ប៉ុន្តែចំណងទាក់ទងច្រើនជាមួយសហរដ្ឋអាមេរិក និងតំបន់អឺរ៉ូ ប្រហែលធ្វើឲ្យប្រទេសទាំងនោះមិនមានកំណើនខ្លាំងក្លាប៉ុន្មានទេក្នុងឆ្នាំនេះ។ សរុបមក មានការមូលមតិថា សេដ្ឋកិច្ចសាកលនឹងបន្តកើនឡើងក្នុងអត្រាទាបជាងធម្មតានៅឆ្នាំ២០១៣។

ដោយសារការព្យាករណ៍ពីសេដ្ឋកិច្ចសាកលវាមិនសូវល្អនោះ ការនាំចេញរបស់កម្ពុជាទំនងមិនអាចស្ទុះឡើងបានច្រើនទេនៅឆ្នាំ២០១៣ ។ នាបច្ចុប្បន្ន ការនាំចេញរបស់កម្ពុជាទៅសហរដ្ឋអាមេរិក មានប្រហែល ៣៨% (ធៀបនឹង ៧០% ក្នុងឆ្នាំ២០០០) ទៅសហភាពអឺរ៉ុប ៣៥% (២០% ក្នុងឆ្នាំ២០០០) និង ទៅប្រទេសផ្សេងទៀត ២៧% (១០% ក្នុងឆ្នាំ២០០០)។ ការបន្តរើបសេដ្ឋកិច្ចយឺតៗនៅសហរដ្ឋអាមេរិក និងអឺរ៉ុប មិនផ្តល់ប្រផ្នូលល្អ សម្រាប់ការនាំចេញរបស់កម្ពុជានោះទេ។ យោងតាមនិន្នាការបច្ចុប្បន្ន ការនាំចេញទំនងកើនឡើងប្រហែល ២៦% ដែលស្រដៀងគ្នានឹងតួលេខឆ្នាំ២០១២។ ចំណូលពីវិស័យទេសចរណ៍ ប្រហែលអាចរក្សាលំនឹងបានមួយរយៈដោយសារមួយចំណែក មានភ្ញៀវទេសចរមកពីកាន់តែច្រើនប្រទេសឡើងចូលមកកម្ពុជាក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ។ ការអនុវត្តកម្មវិធីទិដ្ឋការរួម រវាងថៃ និងកម្ពុជា (ទម្រង់អនុវត្តនៅអាស៊ាននៃគំរូប្រព័ន្ធទិដ្ឋាការ Schengen របស់សហភាពអឺរ៉ុប) ដែលបានដាក់អនុវត្តនៅខែធ្នូ ២០១២ និងផ្លូវហោះហើរថ្មីរបស់ក្រុមហ៊ុនអាកាសចរណ៍ Tiger Airline ពីភ្នំពេញ ទៅសិង្ហបុរី ដែលបានចាប់ដំណើរការក្នុងខែតុលា ២០១២ ទំនងអាចជួយដល់វិស័យទេសចរណ៍។

ដោយបន្តមានលទ្ធផលរឹងមាំក្នុងវិស័យអចលនទ្រព្យ និងសំណង់ កម្ពុជាអាចរក្សាកំណើន ផសស សម្រាប់វិស័យមិនមែនកសិកម្មក្នុងអត្រាប្រហែល ៧,៥%។ ប្រសិនបើមិនមានគ្រោះធម្មជាតិអ្វីធ្ងន់ធ្ងរទេនោះ កំណើន ផសស ៤,៥% ក្នុងវិស័យកសិកម្ម ប្រហែលជាអាចរក្សាបាន។ តាមនេះ កំណើន ផសស សរុប សម្រាប់ឆ្នាំ២០១៣ អាចមានប្រហែល ៧%។ អត្រាកំណើនទំហំប៉ុណ្ណេះ មិនគួរដាក់សម្ពាធអ្វីជ្រុលទៅលើអតិផរណា ឬឱនភាពគណនីចរន្តនោះទេ ហើយគួរតែអាចជួយរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចបាន។

ទោះជាយ៉ាងនេះក្តី ដូច IMF បានជាស់តឿនដែរ និន្នាការផុសឡើងមួយចំនួន ដូចជាការរីកធំយ៉ាងឆាប់រហ័សនៃឥណទានធនាគារ ការថយចុះកម្លាំងខាងហិរញ្ញវត្ថុជាលទ្ធផលនៃចំណូលពន្ធធ្លាក់កំណើន និង បំណុលធំៗដែលអាចកើតមាន (ដោយសាររដ្ឋាភិបាលអនុវត្តគម្រោងជាដៃគូរវាងរដ្ឋ-ឯកជន ក្នុងវិស័យថាមពល) អាចបង្កជាហានិភ័យដល់ស្ថិរភាពម៉ាក្រូហិរញ្ញវត្ថុ ក្នុងប៉ុន្មានឆ្នាំខាងមុខនេះ។ ពិតហើយ អ្នកគ្រប់គ្រងហិរញ្ញវត្ថុ ត្រូវតែប្រុងប្រយ័ត្ន និងពិនិត្យតាមដានការវិវត្តផ្នែកឥណទានឲ្យបានដិតដល់។ ប៉ុន្តែអត្រាខ្ពស់នៃកំណើនឥណទាន ក្នុងប៉ុន្មានឆ្នាំថ្មីៗ អាចបណ្តាលជាចម្បងមកពីកំណែទម្រង់រចនាសម្ព័ន្ធ ដូចជា ច្បាប់ស្តីពីប្រតិបត្តិការមានកិច្ចធានាឆ្នាំ២០០៩ (លុបបំបាត់របាំងចំពោះការប្រើប្រាស់ចលនទ្រព្យធ្វើជាវត្ថុធានា) បទបញ្ញត្តិថ្មីដែលអនុញ្ញាតឲ្យ ការិយាល័យឥណទាន ប្រមូល និងចែកចាយព័ត៌មានឥណទានវិជ្ជមាននិងអវិជ្ជមាន និងការបង្កើតការិយាល័យឥណទានដំបូងនៅកម្ពុជាក្នុងឆ្នាំ២០១២។

## ១.៣ ទស្សនវិស័យរយៈពេលវែង និងបញ្ហាប្រឈមលើការអភិវឌ្ឍ

ប្រសិនបើការព្យាករណ៍ ផសស ខាងលើ វាកើតឡើងមែន ប្រទេសកម្ពុជាអាចនឹងទទួលបានចំណូលលេខបួនខ្ទង់សម្រាប់មនុស្សម្នាក់ គឺប្រហែល ១០០០ដុល្លារ/នាក់ នៅត្រឹមចុងឆ្នាំនេះ ដែលជាជោគជ័យមួយដ៏ធំ និងដែលប្រទេសវៀតណាមសម្រេចបាននៅឆ្នាំ២០០៨ ហើយ ឡាវនៅឆ្នាំ២០១០។ គិតក្នុងរយៈពេលវែង វាជាកំណើនមួយជាបួននៃចំណូលក្នុងមនុស្សម្នាក់នៅកម្ពុជា (គិតតាមអត្រាប្តូរប្រាក់លើទីផ្សារ) ក្នុង ២០ឆ្នាំចុងក្រោយនេះ ពោលគឺចាប់ពីកម្រិត ២៤០ដុល្លារ/នាក់ នៅឆ្នាំ១៩៩៣ មក។ តាមនេះ កម្ពុជាជិតឈានឡើងទៅដល់ ឋានៈដែលធនាគារពិភពលោកបានកំណត់ថាជា ប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតទាប ពោលគឺ ប្រទេសមានប្រាក់ចំណូលក្នុងមនុស្សម្នាក់ ពីជាង ១០២៥ ដល់ក្រោម ៤០៣៥ដុល្លារ។

ឯកសារពិភាក្សានាពេលថ្មីៗមួយរបស់ IMF (ដែលបានគួបផ្សំ ម៉ូដែលម៉ាក្រូសេដ្ឋកិច្ចបែបបរិមាណតូចមួយ នៃសេដ្ឋកិច្ចកម្ពុជា ជាមួយនឹង វិធីសាស្ត្រវិភាគកំណើនបែបគុណភាពជាងនេះ) បានប៉ាន់ស្មានថា កំណើនជាសក្តានុពលក្នុងរយៈពេលវែងនៅកម្ពុជា មានប្រហែល ៧,៥% ហើយ អត្រាវិនិយោគមានកម្រិតប្រហែល ២០% (Rungcharoenkitkul 2012)។ រាល់កំណើនមួយឯកតាភាគរយ ពីលើកម្រិតគោល ៧,៥% ត្រូវមានកំណើនអត្រាវិនិយោគក្នុងប្រទេស ប្រហែល ៥ ឯកតាភាគរយ។ គេអាចនិយាយមួយបែបទៀតថា ដើម្បីបង្កើនកំណើន ផសស ដល់ប្រហែល ៨,៥% ត្រូវបង្កើនអត្រាវិនិយោគឲ្យដល់ប្រហែល ២៥%។ ទំនាក់ទំនងបែបនេះរវាងវិនិយោគ នឹងកំណើនរយៈពេលវែង វាស្របគ្នានឹងបទពិសោធន៍អភិវឌ្ឍន៍ក្នុងសាកលលោក។

"កំណើនខ្លាំងនិងយូរអង្វែង ត្រូវមានអត្រាវិនិយោគខ្ពស់។ តាមការវិនិយោគធនធាន ជាជាងការចំណាយប្រើប្រាស់ធនធាន សេដ្ឋកិច្ចត្រូវធ្វើការសម្របសម្រួលរវាងកម្រិតជីវភាពនាបច្ចុប្បន្ននឹងកម្រិតជីវភាពនាអនាគត។ ការសម្របសម្រួលនេះតឹងតែងខ្លាំងដែរ។ បើពិនិត្យតាមកំណើន

កម្រិតខ្ពស់និងយូរអង្វែងដែលធ្លាប់មានកន្លងមក គេប្រហែលត្រូវបង្កើនអត្រាវិនិយោគសរុបឲ្យដល់ ២៥% នៃ ផសស ឬលើសនេះទៀត... ហើយជារឿយៗគេត្រូវវិនិយោគយ៉ាងហោចណាស់ ៧-៨% នៃ ផសស ក្នុងផ្នែកអប់រំ បណ្តុះបណ្តាល និងសុខាភិបាល... ថ្វីត្បិតតែ នៅក្នុងគណនីជាតិ គេមិនចាត់ទុកវាជាវិនិយោគក៏ដោយ" (Commission on Growth and Development 2008: 34)។ ប្រទេសមានកំណើនខ្ពស់ៗនៅអាស៊ីបូព៌ា ក៏តែងរក្សាអត្រាវិនិយោគឲ្យខ្ពស់ជាង ២៥% ដែរ ហើយតាមពិតជិតដល់ ៣០% ឯណោះ នៅក្នុងដំណាក់កាលរីកលូតលាស់ឆាប់រហ័សរបស់ខ្លួន (World Bank 1991-93; Gill & Kharas 2007; Yusuf 2009)។

ប្រសិនបើអាចរក្សាបានអត្រាកំណើន ផសស ៧,៥% ក្នុងរយៈពេល ១៧ឆ្នាំខាងមុខនោះ នៅឆ្នាំ២០៣០ ចំណូលក្នុងមនុស្សម្នាក់នៅកម្ពុជា អាចឡើងដល់ជាង ២៨០០ដុល្លារ ឬកំណើនមួយជាបី នៃចំណូលក្នុងមនុស្សម្នាក់នៅឆ្នាំ២០១៣។ បើបានដល់កម្រិតនោះ ចំណូលក្នុងមនុស្សម្នាក់នៅកម្ពុជាក្នុងឆ្នាំ២០៣០ អាចប្រហាក់ប្រហែលនឹង ចំណូលក្នុងមនុស្សម្នាក់ដែលប្រទេសឥណ្ឌូណេស៊ីសម្រេចបាននៅឆ្នាំ២០១០ ។ ហើយប្រសិនបើកម្ពុជាអាចសម្រេចបានអត្រាកំណើនដល់ ៨,៥% នោះ ចំណូលក្នុងមនុស្សម្នាក់នៅកម្ពុជា អាចឡើងដល់ ៣៣០០ដុល្លារ នៅឆ្នាំ២០៣០ ដែលស្មើគ្នានឹងប្រទេសឥណ្ឌូណេស៊ីកាលពីឆ្នាំ២០១១។ ឯកសារមួយចងក្រងដោយវិទ្យាស្ថាន CDRI ក្នុងឆ្នាំ២០១២ បានគណនានូវ គន្លងនៃចំណូលក្នុងមនុស្សម្នាក់នៅកម្ពុជា ដោយប្រើសេណារីយ៉ូបីនៃកំណើន ផសស សម្រាប់រយៈពេលពីឆ្នាំ២០១០ ដល់ ២០៣០ ដែលរួមមាន (១) សេណារីយ៉ូកំណើនខ្ពស់ ៩% (២) សេណារីយ៉ូកំណើនមធ្យម ៧% និង (៣) សេណារីយ៉ូកំណើនទាប ៥% (Strange *et al.* 2012)។ ការគណនាឡើងវិញនូវគន្លងចំណូលក្នុងមនុស្សម្នាក់នៅក្រោមសេណារីយ៉ូទាំងនេះ ដោយប្រើចំណូលក្នុងមនុស្សម្នាក់នៅឆ្នាំ២០១៣ (១០០០ដុល្លារ) ជាមូលដ្ឋាន បានផ្តល់លទ្ធផលថា ចំណូលក្នុងមនុស្សម្នាក់នៅឆ្នាំ២០៣០ គឺ ៣៦០០ដុល្លារសម្រាប់សេណារីយ៉ូកំណើនខ្ពស់ ២៦០០ដុល្លារសម្រាប់សេណារីយ៉ូកំណើនមធ្យម និង ១៩០០ដុល្លារសម្រាប់សេណារីយ៉ូកំណើនទាប (រូបភាព ១.២)។

គួរសម្គាល់ថា ប្រសិនប្រើតួលេខធៀបរវាង វិនិយោគ-កំណើន វាស្មើនឹង ៥:១ នោះ ដើម្បីសម្រេចបានកំណើនលឿននៃ ផសស រហូតដល់ ៩% នៅក្រោមសេណារីយ៉ូកំណើនខ្ពស់របស់ CDRI គេត្រូវបង្កើនអត្រាវិនិយោគឲ្យដល់ ២៧-២៨%។ ទោះបីជាអត្រាវិនិយោគ និងអត្រាសន្សំប្រាក់របស់កម្ពុជា វាប្រែប្រួលខ្លាំងពីមួយឆ្នាំទៅមួយឆ្នាំក្តី ក៏នៅអំឡុងឆ្នាំ២០០៥-១០ វាមានអត្រាជាមធ្យមប្រហែល ២០% និង ១៥% រៀងគ្នា។ ដូច្នេះ ដើម្បីសម្រេចកំណើន ផសស ប្រហែល ៩% ត្រូវមានកំណើនអត្រាវិនិយោគប្រហែល ៧-៨ ឯកតាភាគរយ។ "កំណើនលឿន វាមានថ្លៃខ្ពស់" (Yusuf 2009: 85)។ កំណើនដែលខ្ពស់ជាងអត្រាគោល ៧,៥% មិនមែនមិនអាចទៅរួចនោះទេ ប៉ុន្តែត្រូវមានកំណើនច្រើនៗក្នុងអត្រាវិនិយោគនៅកម្ពុជា។ ដោយពិចារណាពីបញ្ហានេះ និងឧបសគ្គដទៃទៀត វាជាការជាក់ស្តែងជាង ដែលកម្ពុជាគួរកំណត់គោលដៅរយៈពេលវែងនៃការរក្សាកំណើន ផសស ឲ្យបាន ៧,៥% ទៅ ៨,៥% ដែលជាកំណើនខ្លាំងក្លាមួយហើយ បើធៀបនឹងស្តង់ដារក្នុងពិភពលោក និងក្នុងតំបន់។ គោលដៅកំណើនលើសពីកម្រិតនេះ ទំនងដាក់សម្ពាធជ្រុលទៅលើតុល្យភាពរវាងប្រាក់សន្សំ និងវិនិយោគនៅកម្ពុជា ហើយអាចបង្កគ្រោះថ្នាក់ដល់ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ចំពោះប្រទេសកម្ពុជា ដែលកន្លងមកតែងជួបវិសមភាពចំណូលធំៗ និងការផ្តុំចំណូលទៅម្ខាងៗ គឺអាចជួបការលំបាក ប្រសិនបើអនុម័តយកគន្លងកំណើនខ្ពស់ពេក។ ទោះបីជាទំនាក់ទំនង

រវាងកំណើន និងវិសមភាពចំណូល នៅមិនទាន់ស្វែងយល់បានច្បាស់លាស់ក្តី ក៏មានភស្តុតាងមួយចំនួនបង្ហាញថា ប្រទេសជាច្រើន ក្នុងដំណាក់កាលមានកំណើនខ្លាំងលើសលប់នោះ បានជួបបញ្ហាវិសមភាពចំណូលកាន់តែអាក្រក់ឡើង និងការផ្តុំចំណូលទៅម្ខាងៗរវាងអ្នកមាន និងអ្នកក្រ (Basu 2011; ADB 2012; Stiglitz 2012)។ ការផ្តោតខ្លាំងពេក ទៅលើតែការទាញយកចំណេញជាអតិបរមាពីកំណើនខ្ពស់លើសលប់ ក៏អាចជំរុញអ្នកបង្កើតគោលនយោបាយឲ្យបោះបង់ការអភិវឌ្ឍធនធានមនុស្ស និងការរាប់បញ្ចូលគ្រប់គ្នាក្នុងសង្គម ដែលពួកគេគួរតែយកចិត្តទុកដាក់។ ប្រសិនបើបញ្ហានេះកើតមានឡើង វិស័យសំខាន់ៗ ដូចជា សុខាភិបាល និងអប់រំជាដើម អាចត្រូវគេធ្វេសប្រហែស ហើយបញ្ហានេះអាចបង្កការខូចខាតដល់ការរីកចម្រើនគួរឲ្យកោតសរសើរ ដែលកម្ពុជាសម្រេចបានចាប់ពីពាក់កណ្តាលទសវត្សរ៍១៩៩០ មក ថ្វីបើនៅមានបញ្ហាប្រឈមជាច្រើនទៀតក្តី។

រូបភាព ១.២៖ ចំណូលក្នុងមនុស្សម្នាក់ក្រោមសេណារីយ៉ូកំណើនខុសៗគ្នា




ទោះជាសូចនាករវិស័យសុខាភិបាលទាំងមូល បានល្អប្រសើរឡើងគួរឲ្យស្ញប់ស្ញែងក្តី ក៏កម្ពុជានៅមានការងារជាច្រើនទៀតដែលមិនទាន់បញ្ចប់ ដូចជា ការបង្ការជំងឺឆ្លង ការកែលំអសេវាសុខភាពបន្តពូជ ការកាត់បន្ថយអត្រាមរណៈកុមារ និងការផ្តល់ប្រព័ន្ធអនាម័យ និងទឹកស្អាតសម្រាប់ហូប ជាដើម។ វិស័យអប់រំក៏ដូចគ្នាដែរ ប្រទេសកម្ពុជាអនុវត្តបានល្អណាស់ ដោយស្ទើរតែសម្រេចបានទាំងស្រុងនូវការអប់រំថ្នាក់បឋមសិក្សាសម្រាប់គ្រប់គ្នា ប៉ុន្តែនៅមានចន្លោះខ្វះខាតធំៗជាច្រើននៅកម្រិតអនុវិទ្យាល័យ វិទ្យាល័យ និងការបណ្តុះបណ្តាលវិជ្ជាជីវៈ។ គិតតែក្នុងប្រទេសកម្ពុជាខ្លួនឯង គ្រួសារក្រីក្រមានលទ្ធភាពទាបជាខ្លាំង ជាងគ្រួសារធូរធារ ក្នុងការទទួលបានសេវាសុខភាព និងសេវាអប់រំ ហើយក៏មានគម្លាតគ្នាខ្លាំងដែរ ក្នុងលទ្ធភាពទទួលបានសេវាទាំងពីរនេះ រវាងគ្រួសារនៅជនបទ នឹងគ្រួសារនៅតំបន់ទីក្រុង/ទីប្រជុំជន។ ការដោះស្រាយតម្រូវការដ៏ចាំបាច់ទាំងនេះរបស់

មនុស្ស គួរទទួលបានអាទិភាពខ្ពស់ជាង ការផ្តោតតែមួយមុខទៅលើការសម្រេចគោលដៅកំណើន ផសស ដ៏ខ្ពស់លើសលប់។ "ប្រាក់កាសជាបញ្ហាសំខាន់មែន ប៉ុន្តែមានភស្តុតាងលើសលុបបង្ហាញច្បាស់ថា ការរីកចម្រើនធំធេង ក្នុងទិដ្ឋភាពផ្សេងៗទៀតនៃការអភិវឌ្ឍធនធានមនុស្ស អាចសម្រេចទៅបាន ដោយមិនចាំបាច់ផ្តោតកម្លាំងតែលើកំណើនសេដ្ឋកិច្ចនោះទេ" (UNDP 2010: 63)។

ទោះបីអាចសម្រេចបានកំណើន ផសស ប្រចាំឆ្នាំ ជិតដល់ ៨,៥% ក្តី ក៏ការឈានឡើងថែមទៀតពីកម្រិតដ៏ខ្ពស់នេះ វាមានបញ្ហាប្រឈមខ្លាំង ព្រោះត្រូវបង្កើនអត្រាវិនិយោគឲ្យបានប្រហែល ៥ ឯកតាភាគរយទៀត។ ដើម្បីរក្សាអតុល្យភាពគណនីចរន្តឲ្យស្ថិតក្នុងកម្រិតអាចគ្រប់គ្រងបាននោះ អត្រាប្រាក់សន្សំជាមធ្យមក្នុងប្រទេស ១៥% នាពេលបច្ចុប្បន្ន ត្រូវកើនឡើងច្រើនថែមទៀត ខណៈដែល ជំនួយពីខាងក្រៅកំពុងថយចុះចៀសមិនផុត។ កំណើនខ្លាំងនៃអត្រាវិនិយោគ ក៏ត្រូវមានការកែលំអច្រើនទៀតដែរនូវហេដ្ឋារចនាសម្ព័ន្ធ ការកែលំអធំៗនូវបរិយាកាសជំនួញ ការវិនិយោគដ៏ច្រើនៗលើធនធានមនុស្ស ការគ្រប់គ្រងអាចជឿទុកចិត្តបាននូវធនធានធម្មជាតិ ការគ្រប់គ្រងម៉ាក្រូហិរញ្ញវត្ថុយ៉ាងប្រុងប្រយ័ត្ន និងជាពិសេស ការបន្តពង្រឹងអភិបាលកិច្ច និងស្ថាប័នផ្សេងៗ (Strange *et al.* 2012: CDRI 2013 forthcoming)។

ពិតហើយ តាំងពីពាក់កណ្តាលទសវត្សរ៍១៩៩០ មក កម្ពុជាឈានទៅមុខបានច្រើនណាស់ ហើយសឹងតែគ្រប់វិស័យ។ការកសាងឡើងវិញដ៏អស្ចារ្យពីកម្រិតសូន្យនូវសេដ្ឋកិច្ច សង្គម និងប្រព័ន្ធនយោបាយនៅកម្ពុជា ពីស្ថានភាពដ៏លំបាកស្មុគស្មាញបំផុតនៅពាក់កណ្តាលទសវត្សរ៍១៩៩០ រហូតមកដល់ស្ថានភាពសព្វថ្ងៃ គឺសឹងតែមិនដែលមានសោះទេ ទាំងនៅក្នុងពិភពលោក ឬនៅក្នុងអាស៊ាន។ កម្ពុជាធ្វើដំណើរបានឆ្ងាយណាស់ហើយនៅលើផ្លូវអភិវឌ្ឍន៍ដ៏លំបាក ដែលមិនមែនមានត្រឹមតែកំណើនសេដ្ឋកិច្ចប៉ុណ្ណោះទេ គឺមានទាំងការរីកចម្រើនក្នុងការកាត់បន្ថយភាពក្រីក្រ ការអភិវឌ្ឍមនុស្ស សមភាពយេនឌ័រ ការថែទាំសុខភាព និងការអប់រំ ផងដែរ ប៉ុន្តែគោលដៅនៃការកសាងសង្គមមួយដែលរួចផុតពីភាពក្រីក្រ មានសុខភាពល្អ មានការអប់រំល្អ និងមានការរាប់បញ្ចូលទាំងអស់គ្នា វានៅឆ្ងាយខាងមុខទៀត (CDRI 2013 forthcoming)។

ប្រទេសសកម្ពុជាកំពុងទៅដល់ផ្លូវបំបែកដ៏សំខាន់បំផុតមួយ ក្នុងដំណើរអភិវឌ្ឍន៍របស់ខ្លួន។ កម្មវិធីអភិវឌ្ឍន៍ សេដ្ឋកិច្ច-សង្គមកិច្ចដែលមិនទាន់បានបញ្ចប់ ពិតជានៅធំណាស់ ហើយទាមទារការចេះចាត់ចែងយ៉ាងប៉ិនប្រសព្វ និងបានផលជាក់ស្តែង។ ប្រទេសកម្ពុជាត្រូវតែធ្វើបែបនេះ នៅក្នុងបរិបទក្រោយវិបត្តិសេដ្ឋកិច្ចពិភពលោក ដែលអាចមិនសូវមានកំណើនក្នុងមួយរយៈពេលទៀត។ ស្ថានភាពក្នុងតំបន់ក៏កំពុងមានការផ្លាស់ប្តូរជ្រាលជ្រៅដែរ ដោយសារការស្ទុះឡើងនៃប្រទេសមីយ៉ាន់ម៉ា និងការបង្កើត សហគមន៍សេដ្ឋកិច្ចអាស៊ាន ក្នុងពេលឆាប់ៗ ហើយព្រឹត្តិការណ៍ទាំងពីរនេះអាចផ្តល់នូវឱកាសថ្មីៗដល់កម្ពុជា ប៉ុន្តែវាក៏បង្រួមដែនគោលនយោបាយរបស់ប្រទេសកម្ពុជាផងដែរ។

## គន្ថនិទ្ទេស

ADB–Asian Development Bank (2012), *Asian Development Outlook 2012: Confronting Rising Inequality in Asia* (Manila: ADB)

Basu, Kaushik (2011), *Beyond the Invisible Hand: Groundwork for a New Economics* (New Delhi: Penguin)

CDRI–Cambodia Development Resource Institute (2013), "Cambodia's Socio-economic Development: Past Performance, Future Challenges and Policy Options", Special Report (forthcoming) (Phnom Penh: CDRI)

Commission on Growth and Development (2008), "The Growth Report: Strategies for Sustained Growth and Inclusive Development" (Washington, DC: World Bank)

Gill, Indermit & Homi Kharas (2007), *An East Asian Renaissance: Ideas for Economic Growth* (Washington, DC: World Bank)

IMF–International Monetary Fund (2013), "Cambodia: 2012 Article IV Consultation Report" (Washington, DC: IMF)

Strange, Larry, Khieng Sothy, Saing Chan Hang, Hing Vutha & Lun Pide (2012), *ASEAN 2030: Growing Together For Economic Prosperity—The Challenges* (Phnom Penh: CDRI)

Rungcharoenkitkul, Phurichai (2012), *Modeling with Limited Data: Estimating Potential Growth in Cambodia*, IMF Working Paper No. 12/96 (Washington, DC: IMF)

Stiglitz, Joseph E. (2012), *The Price of Inequality* (London: Penguin)

UNDP–United Nations Development Programme (2010), "The Real Wealth of Nations: Pathways to Human Development", Human Development Report—20th Anniversary Edition (New York, NY: UNDP)

World Bank (1991), *World Development Report 1991: The Challenge of Development* (Washington, DC: World Bank)

World Bank (1993), *The East Asian Miracle: Economic Growth and Public Policy* (New York: Oxford University Press)

Yusuf, Shahid (2009), *Development Economics Through the Decades* (Washington, DC: World Bank)

-២-

# ទស្សនៈរបស់ប្រជាពលរដ្ឋអំពីទំនួលខុសត្រូវរបស់ខ្លួន៖ ការវិភាគបឋមពីការរួមចំណែកនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ នៅក្នុងទំនាក់ទំនងជាបដិការរវាងរដ្ឋ និងសង្គម នៅខេត្តបាត់ដំបង[១]

*ដោយលោក ហេង សីហា និង សូ សុខប៊ុនធឿន[២]*

ការសិក្សានេះ ពិភាក្សាពីកម្រិតដែលកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ (D&D) ចូលរួមចំណែកកសាងទំនាក់ទំនងជាបដិការរវាងរដ្ឋ-សង្គមនៅកម្ពុជា។ ជាទូទៅមានការយល់ឃើញថា ការកកើតទំនាក់ទំនងជាបដិការរវាងរដ្ឋ និងសង្គម ត្រូវរាំងស្ទះដោយសារបែបបទវប្បធម៌ចាក់ឫសដែលប្រកាន់ខ្ជាប់ទស្សនៈបិតុភាពចំពោះរដ្ឋ និងដែលពង្រឹងភាពពឹងផ្អែករបស់ប្រជាពលរដ្ឋទៅលើរដ្ឋ ប៉ុន្តែការសិក្សានេះរកឃើញថា ដោយសារលទ្ធផលនៃកំណែទម្រង់ផ្សេងៗ និងការអភិវឌ្ឍសង្គមនិងសេដ្ឋកិច្ចក្នុងមួយទសវត្សរ៍កន្លងទៅនេះ ទំនាក់ទំនងជាបដិការរវាងរដ្ឋ និងសង្គម មានសន្ទុះខ្លាំងឡើងជាងអតីតកាល ។

## ២.១ សេចក្តីផ្តើម

ក្នុងប្រទេសកំពុងអភិវឌ្ឍនានា ទំនាក់ទំនងរដ្ឋ-សង្គម[៣] ត្រូវបានគ្របដណ្តប់ភាគច្រើនដោយទស្សនៈបិតុភាព ចំពោះរដ្ឋ (Edigheji 2007: 60; see also Edigheji 2003: 75) ដែលមានន័យថារដ្ឋ ឬរដ្ឋាភិបាល ជាឪពុកម្តាយ ហើយប្រជាពលរដ្ឋជាកូនចៅ។ តាមទស្សនៈនេះ ការកសាងទំនាក់ទំនងជាបដិការរវាងរដ្ឋ និងសង្គមនៅប្រទេសកំពុងអភិវឌ្ឍ ជាបញ្ហាប្រឈមធំមួយ។ ដូចជាប្រទេសកំពុងអភិវឌ្ឍឯទៀតដែរ ឯកសារស្តីពី ទំនាក់ទំនងរដ្ឋ និងសង្គម ក្នុងប្រទេសកម្ពុជា តែងបង្ហាញនូវទស្សនៈ បិតុភាពរបស់ប្រជាពលរដ្ឋចំពោះរដ្ឋ។ ឯកសារសិក្សាស្តីពីការចិញ្ចឹមទុកនូវទស្សនៈបិតាភាពនេះ ក្នុងសង្គមកម្ពុជា ចែកជាបីក្រុម។

---

[១] លទ្ធផលរកឃើញក្នុងការសិក្សានេះ បានពី ការពិនិត្យជាប្រព័ន្ធនូវ អត្ថបទទស្សនាវដ្តី របាយការណ៍ និងការស្រាវជ្រាវផ្សេងៗ សម្ភាសន៍បែបគុណភាពជាមួយអ្នកពាក់ព័ន្ធសំខាន់ៗ (ដូចជា ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាស្រុក និងអភិបាលស្រុក) និងកិច្ចពិភាក្សាជាក្រុម (FGD) នៅកម្រិតមូលដ្ឋាន តាមឃុំ/សង្កាត់បានជ្រើសរើស ក្នុងខេត្តបាត់ដំបង ព្រមទាំងបានពីការសិក្សាមុនៗរបស់អ្នកនិពន្ធ។

[២] លោក ហេង សីហា ជាអ្នកស្រាវជ្រាវ, បណ្ឌិត សូ សុខប៊ុនធឿន ជាអ្នកស្រាវជ្រាវជាន់ខ្ពស់ នៅ CDRI។

[៣] ទំនាក់ទំនងរដ្ឋ និងសង្គម ជាអន្តរកម្មរវាងរដ្ឋ និងសមាជិកសង្គម។ ទំនាក់ទំនងរដ្ឋ និង សង្គមដ៏សក្តិសិទ្ធិអាចសម្រេចបាន នៅពេល រដ្ឋមានសិទ្ធិអំណាចអនុវត្តមុខងារចម្បងរបស់ខ្លួន ក្នុងការផ្តល់ទំនិញ ឬ សេវាសាធារណៈតាមការសន្យា ហើយប្រជាពលរដ្ឋក៏បំពេញតាមកាតព្វកិច្ចផ្លូវការរបស់ខ្លួនចំពោះរដ្ឋ។ ទំនាក់ទំនងជាបដិការរវាងរដ្ឋ និងសង្គម តំណាងឲ្យ "អន្តរកម្មរវាងស្ថាប័នរដ្ឋ និងក្រុមនានាក្នុងសង្គម ក្នុងការចរចាពី បែបបទអនុវត្តសិទ្ធិអំណាចរបស់រដ្ឋ និង បែបបទដែលប្រជាជនអាចជះឥទ្ធិពលទៅលើការអនុវត្តនោះ។ ទំនាក់ទំនងទាំងនោះ ផ្តោតលើបញ្ហា ដូចជា ការកំណត់សិទ្ធិ និងកាតព្វកិច្ចទៅវិញទៅមករបស់រដ្ឋ និងសង្គម..." (DFID 2010: 15)។

ឯកសារសិក្សាក្រុមទី១ ផ្ដល់គំនិតថា ទស្សនៈបិតុភាពចំពោះរដ្ឋ វាជាប់ទាក់ទងជិតស្និទ្ធជាមួយ ឬកើតចេញពីឥទ្ធិពលដ៏ខ្លាំងនៃ "បែបបទវប្បធម៌បុរាណបែបពុទ្ធសាសនា ឬរាជានិយម" ទៅលើសង្គមកម្ពុជាដែលចាត់ទុករដ្ឋាភិបាល ឬរដ្ឋ ដូចជាឪពុក និងប្រជាពលរដ្ឋជាកូនចៅ (CAS 2001: 26)។ ប្រការនេះ បង្ហាញថា ទស្សនៈ បិតុភាពចំពោះរដ្ឋ មិនមែនជារឿងថ្មីទេ ប៉ុន្តែជាវប្បធម៌ចាក់ឫសចូលជ្រៅទៅក្នុងសង្គម។ ឯកសារសិក្សាក្រុមទី២ លើកថា ប្រវត្តិសាស្ត្រកម្ពុជាក៏ដើរតួនាទីក្នុងការពង្រឹងទស្សនៈ បិតុភាពចំពោះរដ្ឋដែរ។ សង្គ្រាមជាច្រើនទសវត្សរ៍ និងជម្លោះផ្ទៃក្នុង បណ្ដាលឲ្យកម្ពុជាក្លាយជាប្រទេសក្រីក្របំផុតមួយក្នុងពិភពលោក។ ដូច្នេះ សម្រាប់ធនធាន និងសម្ភារៈនានា ប្រជាជនមានការពឹងផ្អែកកម្រិតខ្ពស់ទៅលើរដ្ឋ (ជាឪពុក)។

ឯកសារសិក្សាក្រុមទី៣ ផ្ដោតលើទំនាក់ទំនងនយោបាយ (ឧទាហរណ៍ នយោបាយទាក់ទងនឹងការបោះឆ្នោត) ដែលជួយឲ្យភាពពឹងផ្អែកនៅមានជាប់រហូត។ សង្គ្រាមស៊ីវិល និងជម្លោះពីរទសវត្សរ៍កន្លងមក បានរុញច្រានប្រទេសកម្ពុជាឲ្យធ្លាក់ចូលក្នុងចំណោមប្រទេសកំពុងអភិវឌ្ឍដែលពឹងផ្អែកខ្លាំងបំផុតលើជំនួយ ដោយមានថវិកាប្រចាំឆ្នាំជិតពាក់កណ្ដាលបានមកពីជំនួយបរទេស (Ear 2006; Ek & Sok 2008)។ ការពឹងផ្អែកកម្រិតខ្ពស់លើជំនួយបែបនេះ បានប៉ះពាល់ជាខ្លាំងដល់ទំនាក់ទំនងជាបដិការរវាងរដ្ឋ-សង្គម។ ពិតណាស់ ការពឹងផ្អែកលើជំនួយ បានបង្កើតបរិយាកាសនយោបាយមួយនៅកម្ពុជាដែលមានការលាក់លៀមច្រើន និងផ្ដល់អាទិភាពចំពោះ "បុគ្គលម្នាក់ និងសកម្មភាពជាលក្ខណៈបុគ្គល ជាជាង ក្របខ័ណ្ឌសាធារណៈ និងសកម្មភាពជាសមូហភាព" (Hughes 2009: 22)។ ចំណុចនេះវាជួយពង្រឹងបែបបទពីបុរាណ និងវប្បធម៌មានស្រាប់ នៃការពឹងផ្អែករបស់ប្រជាជនទៅលើរដ្ឋ ឬ បុគ្គលមានឋានៈខ្ពស់ ដើម្បីការរស់រានមានជីវិត។

បែបបទវប្បធម៌ដែលបន្តរក្សាទស្សនៈបិតុភាពចំពោះរដ្ឋ និងកត្តាផ្សេងៗដែលបង្ខំឲ្យប្រជាជនពឹងផ្អែកទៅលើរដ្ឋ ហាក់ដូចត្រឹមត្រូវមួយកម្រិតដែរ។ ប៉ុន្តែការសង្កត់ធ្ងន់លើប្រការនេះខ្លាំងពេក អាចកាត់បន្ថយសារៈសំខាន់នៃការផ្លាស់ប្ដូរផ្សេងៗដែលជាលទ្ធផលនៃ កំណែទម្រង់ និងការកែសម្រួលកន្លងមក។

សម្រាប់វិមជ្ឈការ គេបានដឹងយូរមកហើយថាជាកាតាលីករសម្រាប់កែលំអទំនាក់ទំនងរដ្ឋ-សង្គម (Heller 2000 cited in Beall 2005; Dabo *et al.* 2010)។ ទំនាក់ទំនងប្រសើរឡើងរវាងរដ្ឋ-សង្គម អាចមើលឃើញច្បាស់តាមរយៈការខិតចូលនៃរដ្ឋ/រដ្ឋាភិបាល ទៅជិតប្រជាជន, កំណើនប្រសិទ្ធភាពរបស់រដ្ឋាភិបាល/រដ្ឋ និងកំណើនការចូលរួមរបស់ប្រជាជនប្រកបដោយលក្ខណៈប្រជាធិបតេយ្យ (Heller 2000 cited in Beall 2005: 6)។ នៅកម្ពុជា កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ បានឈានដល់កម្រិតពេញលេញ ដោយមានការបោះឆ្នោតដោយផ្ទាល់ជ្រើសរើសក្រុមប្រឹក្សាឃុំ/សង្កាត់ តាំងពីឆ្នាំ២០០២ និង ការបោះឆ្នោតដោយប្រយោលជ្រើសរើសក្រុមប្រឹក្សាថ្នាក់ស្រុក និងខេត្ត ចាប់ពីឆ្នាំ២០០៩។ ក្នុងកំណែទម្រង់ដ៏ធំទូលាយនេះ មុខងារសំខាន់ៗដូចជា សិទ្ធិអំណាច និងធនធានផ្សេងៗ បានផ្ទេរពីកម្រិតមជ្ឈឹមទៅឲ្យកម្រិតក្រុង ស្រុក និង ខេត្ត ក្នុងគោលដៅចម្បងលើកកម្ពស់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងការកែលំអការផ្ដល់សេវាមូលដ្ឋានក្រោមរបបរដ្ឋបាលឯកភាពតែមួយ។

## ២.២ លទ្ធផលរកឃើញជាដំបូងៗ

### *២.២.១ ទស្សនៈរបស់ប្រជាពលរដ្ឋចំពោះរដ្ឋ*

បែបបទវប្បធម៌មានឋានានុក្រមដែលចាក់ឫសជ្រៅ នៅតែឃើញមាននៅក្នុងទស្សនៈរបស់ប្រជាពលរដ្ឋចំពោះរដ្ឋ។ លទ្ធផលបានពីសម្ភាសន៍ និង កិច្ចពិភាក្សាជាក្រុម (FGDs) បង្ហាញថា ប្រជាពលរដ្ឋនៅតែបន្តមានទស្សនៈ បិតុភាពចំពោះរដ្ឋ ប៉ុន្តែគេឃើញមានអន្តរកម្មជាបដិការរវាងប្រជាពលរដ្ឋ និងក្រុមប្រឹក្សាថ្នាក់មូលដ្ឋានកាន់តែច្រើនឡើង ហើយក្តីរំពឹងសង្ឃឹមទៅលើរដ្ឋពីសំណាក់ប្រជាជនក៏បានផ្លាស់ប្តូរដែរ។ ចំពោះសំណួរថា តើគួរចាត់ទុករដ្ឋាភិបាលជាឪពុក ជាចៅហ្វាយនាយ ឬជាអ្នកផ្តល់សេវានោះ ជាទូទៅ ប្រជាជនទូទៅយល់ឃើញថា រដ្ឋាភិបាលជាឪពុក និងបញ្ជាក់ថា ឪពុកមិនមែនជាចៅហ្វាយនាយ ឬអ្នកកាន់អំណាចផ្តាច់ការដែលចាត់ចែងពលកររបស់ខ្លួនដូចជាទាសករនោះទេហើយថាឪពុកត្រូវតែបម្រើនិងការពារកូនចៅ។ប្រជាជនមើលឃើញរដ្ឋាភិបាលជាចៅហ្វាយនាយក្នុងអំឡុងទសវត្សរ៍១៩៨០ នៅពេលមានការកេណ្ឌបង្ខំឲ្យចូលបម្រើកងទ័ព ឬដាក់បញ្ជាឲ្យអនុវត្តការងារជាក់លាក់មួយចំនួន។ ដូច្នេះជាទូទៅ គេមើលឃើញ រដ្ឋជា "ឪពុក" ហើយប្រជាពលរដ្ឋជា "កូនចៅ" ប៉ុន្តែគេរំពឹងថា ឪពុកត្រូវមានអាកប្បកិរិយាសមរម្យ និង ការពារផលប្រយោជន៍របស់កូនចៅ។

ការប្រែប្រួលនៃការរំពឹងទុកចំពោះរដ្ឋនេះ វាជាប់ទាក់ទិនទៅនឹងការផ្លាស់ប្តូរជាក់ស្តែងក្នុងរបៀបគ្រប់គ្រងឃុំ ចាប់តាំងពីបានដាក់អនុវត្ត D&D មក។ តួនាទីរបស់សមាជិកក្រុមប្រឹក្សាឃុំ (CCs) ដែលជាមន្ត្រីក្នុងរបបមុនៗ បានប្រែប្រួលច្រើន។ មេឃុំមួយរូបនៅខេត្តបាត់ដំបង ពន្យល់ថា៖ ...កាលពីមុន រដ្ឋ ឬរដ្ឋាភិបាល (គឺ ឃុំ) គេមើលឃើញថាជា កងល្បាតប្រយុទ្ធទប់ទល់នឹងទ័ពព្រៃ តែឥឡូវនេះ គេមើលឃើញឃុំថាជា ភ្នាក់ងារអភិវឌ្ឍថ្នាក់មូលដ្ឋានដែលផ្តោតការងារលើការអភិវឌ្ឍ និងសុខុមាលភាពប្រជាជន។ (កិច្ចសម្ភាសន៍ជាមួយមេឃុំមួយរូបនៅខេត្តបាត់ដំបង ថ្ងៃទី៩ កក្កដា ២០១២)។

### *២.២.២ ឥរិយាបថប្រជាពលរដ្ឋចំពោះទំនួលខុសត្រូវរបស់ខ្លួន*

*...ការបង់ពន្ធ មូលនិធិបដិភាគ និង ការប្រមូលកម្រៃ*

ប្រជាជនមានឥរិយាបថកណ្តាល ចំពោះការចូលរួមវិភាគទានជាប្រាក់ក្នុងទម្រង់ជាមូលនិធិបដិភាគ ថ្លៃប្រើសេវា និងប្រាក់ពន្ធ។ ពួកគាត់ផ្តល់វិភាគទានជាសាច់ប្រាក់ ឬសម្ភារៈ ដល់គម្រោងអភិវឌ្ឍន៍សហគមន៍ ដោយជឿជាក់ថា ការចូលរួមចំណែកនេះ ជួយឲ្យអាជ្ញាធរនៅមូលដ្ឋានគាត់ អាចឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍន៍ក្នុងមូលដ្ឋាន។ ការផ្តល់វិភាគទានជាសាច់ប្រាក់មកទល់សព្វថ្ងៃ មានលក្ខណៈជាការស្ម័គ្រចិត្ត ឬ ជាមូលនិធិបដិភាគ (៣% នៃតម្លៃគម្រោងអភិវឌ្ឍន៍សរុប) ដែលត្រូវប្រើប្រាស់សម្រាប់អនុវត្តគំនិតផ្តួចផ្តើមអភិវឌ្ឍន៍ក្នុងគម្រោងជាក់លាក់ណាមួយ ដោយប្រជាជនភាគច្រើនយល់ឃើញថា វាជាភារកិច្ចរបស់គាត់។ ប្រជាជនជាច្រើននាក់និយាយថា គាត់ពេញចិត្តចូលរួមចំណែកឲ្យបានកាន់តែជាប្រព័ន្ធថែមទៀត ដូចជា ក្នុងទម្រង់ជាការបង់ពន្ធដីធ្លីប្រចាំឆ្នាំ ជាដើម។ ចំពោះសំណួរថា តើគាត់មានប្រតិកម្មបែបណាចំពោះការបង់ពន្ធដែលអាចកើតមាននៅពេលអនាគត ជំនួសឲ្យវិភាគទានជាក់លាក់ទៅក្នុងគម្រោងតាមសំណើម្តងម្កាលនោះ អ្នកចូលរួម FGD ប្រាប់ថា គាត់រីករាយនឹងបំពេញតាមកាតព្វកិច្ចរបស់គាត់

ឲ្យតែប្រាក់នោះមានចំនួនសមរម្យអាចបង់បាន ហើយមួយចំណែកធំនៃប្រាក់ចំណូលវិភាគទានត្រូវបានរក្សាទុកសម្រាប់តម្រូវការអភិវឌ្ឍន៍ក្នុងមូលដ្ឋាន (មានជាអាទិ៍ ការកែលំអហេដ្ឋារចនាសម្ព័ន្ធ ដូចជា ផ្លូវថ្នល់ សាលារៀន មន្ទីរពេទ្យ និង សេវាសង្គម ដូចជា ការអប់រំ សុខាភិបាល និងអនាម័យ) និងការថែទាំគម្រោងមានស្រាប់។

ប្រជាជនចង់ឲ្យរក្សាទុក និងប្រើប្រាស់ចំណូលពន្ធនៅក្នុងមូលដ្ឋាន ព្រោះគាត់កើនទំនុកចិត្តទៅលើមន្ត្រីកម្រិតមូលដ្ឋាន ដោយសារជាសំខាន់ កំណែទម្រង់ D&D ដែលធ្វើឲ្យរដ្ឋាភិបាលកាន់តែខិតទៅជិតប្រជាជន និងបានដាក់អនុវត្តនូវយន្តការលើកកម្ពស់គណនេយ្យភាពនៃក្រុមប្រឹក្សាក្នុងមូលដ្ឋាន និងភាពអើពើទៅនឹងតម្រូវការប្រជាពលរដ្ឋ។ នៅក្នុង FGDs ជាមួយប្រជាជនទាំងនៅជនបទ និងទីក្រុង អ្នកចូលរួមបានយល់ស្របទាំងអស់គ្នាថា គាត់មានទំនុកចិត្តទៅលើក្រុមប្រឹក្សាមូលដ្ឋាន ច្រើនជាង អាជ្ញាធរនៅកម្រិតដទៃទៀតនៅក្នុងប្រព័ន្ធឋានានុក្រមរដ្ឋបាល។ ទំនុកចិត្តដ៏ខ្ពស់នេះ កើតមានជាសំខាន់ដោយសារប្រជាជនបាននៅជិត និងមានភាពស្និទ្ធស្នាលជាមួយក្រុមប្រឹក្សាក្នុងមូលដ្ឋានរបស់ខ្លួន។

ការផ្តល់វិភាគទានជាសាច់ប្រាក់ និងការចូលរួមយ៉ាងសកម្មរបស់ប្រជាពលរដ្ឋ អាចកើតមានឡើងមួយផ្នែកដោយសារវត្តមានរបស់សមាគមនានាក្នុងមូលដ្ឋាន ដែលជួយបង្កើតជាវិភាគទានធំៗពីសំណាក់ប្រជាជនក្នុងឃុំមួយចំនួន សម្រាប់គម្រោងអភិវឌ្ឍន៍សហគមន៍ផ្សេងៗ ក្រៅពីគម្រោងទទួលមូលនិធិ ពីមូលនិធិឃុំសង្កាត់ (CSF) (កិច្ចសម្ភាសន៍ជាមួយ មេឃុំ២ ក្នុងខេត្តបាត់ដំបង ថ្ងៃទី៩ កក្កដា ២០១២)។ នៅតាមឃុំ មានសមាគម/ក្រុមមិនផ្លូវការជាច្រើន (ក្រុមយាមផ្លូវជនបទ សមាគមអ្នកប្រើប្រាស់ទឹក ក្រុមអ្នកប្រើប្រាស់ទឹកស្អាត) ត្រូវបានបង្កើតឡើងជាសមូហភាព ដើម្បីការពារគម្រោងរបស់ឃុំ ដោះស្រាយបញ្ហាសង្គមផ្សេងៗក្នុងមូលដ្ឋាន ឬជួយគ្នាទៅវិញទៅមក។ ក្រុម និងសមាគមទាំងនេះ មិនត្រឹមតែជួយភ្ជាប់ទំនាក់ទំនងរវាងប្រជាជន និងអាជ្ញាធរមូលដ្ឋានប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជួយឲ្យអាជ្ញាធរបំពេញភារកិច្ចរបស់ខ្លួនបានកាន់តែប្រសើរ ដោយមានការគាំទ្រកាន់តែច្រើនពីប្រជាជន។

អវត្តមាន ឬចំនួនតិចតួចនៃសមាគមមូលដ្ឋាននៅតំបន់ទីក្រុង អាចបំភ្លឺមួយចំណែកពីមូលហេតុដែលការប្រមូលមូលនិធិបដិភាគ/វិភាគទាននៅតំបន់ទាំងនេះវាលំបាកជាងនៅតំបន់ជនបទ។ ចៅសង្កាត់មួយរូបនៅខេត្តបាត់ដំបង ត្អូញត្អែរថា "ការចូលរួមវិភាគទានរបស់ប្រជាជន ជាបញ្ហាមួយសម្រាប់សង្កាត់។ អ្នកដែលមិនទទួលបានផលប្រយោជន៍ផ្ទាល់ពីគម្រោង មិនពេញចិត្តនឹងចូលរួមវិភាគទានទេ (កិច្ចសម្ភាសន៍ជាមួយមេឃុំ/ចៅសង្កាត់ បីរូប នៅខេត្តបាត់ដំបង ថ្ងៃទី១០ កក្កដា ២០១២)"។

*...ការចូលរួមបោះឆ្នោត*

ជាទូទៅ ពួកអ្នកចូលរួមក្នុង FGD សម្តែងភាពសប្បាយរីករាយនឹងការទៅចូលរួមបោះឆ្នោត និងលទ្ធភាពរបស់ខ្លួនក្នុងការជ្រើសរើសអ្នកដឹកនាំ។ គាត់រីករាយដូច្នេះ ដោយសារបានយល់ដឹងច្រើនពីដំណើរការបោះឆ្នោតចាប់តាំងពីការបោះឆ្នោតថ្នាក់ជាតិលើកដំបូងក្នុងឆ្នាំ១៩៩៣ និងអវត្តមាននៃអំពើហិង្សាជាប់ពាក់ព័ន្ធផ្នែកនយោបាយ។ ដោយឡែក គាត់បញ្ជាក់ថា បានយល់ដឹងច្បាស់ពីសិទ្ធិរបស់គាត់ ជាពិសេសសិទ្ធិបោះឆ្នោត សិទ្ធិចូលរួមក្នុងកិច្ចប្រជុំ និងសិទ្ធិបញ្ចេញយោបល់។

បដិការ[៤] វាលេចធ្លោឡើង នៅពេលប្រជាជនប្រើប្រាស់សិទ្ធិគាត់ដើម្បីបោះឆ្នោត។ ប្រជាជនចូលរួមជ្រើសរើសក្រុមប្រឹក្សាក្នុងមូលដ្ឋានគាត់ដោយរំពឹងថា នឹងមានការផ្តល់សេវាសាធារណៈកាន់តែប្រសើរដោយក្រុមប្រឹក្សាជាប់ឆ្នោត។ ប៉ុន្តែបដិការក្នុងទម្រង់នេះ វាមានលក្ខណៈផ្សារភ្ជាប់នឹងបុគ្គល។ CSF មានចំនួនតិចតួចណាស់ មិនអាចឲ្យមន្ត្រីជាប់ឆ្នោតឆ្លើយតបបានគ្រប់តម្រូវការក្នុងមូលដ្ឋានទេ។ ជារឿយៗ អ្នកដឹកនាំក្នុងមូលដ្ឋានតែងស្វែងរកជំនួយឧបត្ថម្ភពីប្រភពផ្សេងទៀត ដូចជា សប្បុរសជន គណបក្សនយោបាយ និងអង្គការមិនមែនរដ្ឋាភិបាល (NGO)។

ការពឹងផ្អែកខ្លាំងរបស់មន្ត្រីជាប់ឆ្នោត ទៅលើប្រភពចំណូលឯកជន ដើម្បីផ្តល់សេវាសាធារណៈតាមការសន្យា វាបង្កើតជាសំណាញ់ស្មុគស្មាញមួយនៃ ទំនាក់ទំនងបដិការជាលក្ខណៈបុគ្គល រវាងប្រជាពលរដ្ឋ និងមន្ត្រីជាប់ឆ្នោត, និង រវាងមន្ត្រីជាប់ឆ្នោត និងអ្នកឧបត្ថម្ភរបស់ពួកគេ (ផ្សារភ្ជាប់ទៅនឹងកិច្ចការនយោបាយធំទូលាយបែបចៅហ្វាយនាយ-កូនចៅ), ជាជាង ទំនាក់ទំនងជាបដិការផ្លូវការរវាងប្រជាពលរដ្ឋ និងរដ្ឋ។ ចំណុចនេះខុសពីគោលការណ៍ប្រជាធិបតេយ្យដែលក្នុងនោះ ការផ្តល់សេវាសាធារណៈតាមការសន្យា ត្រូវធ្វើឡើងដោយប្រើប្រាក់បានពីអ្នកបង់ពន្ធ ក្នុងទំនាក់ទំនងជាបដិការផ្លូវការរវាងប្រជាពលរដ្ឋ និងរដ្ឋ។

*....សកម្មភាពអភិវឌ្ឍសហគមន៍*

សកម្មភាពធ្វើផែនការអភិវឌ្ឍន៍សហគមន៍ ជាឧបករណ៍អភិវឌ្ឍន៍បែបការចូលរួមមួយ ដែលជួយឲ្យក្រុមប្រឹក្សាជាប់ឆ្នោតបានយល់ដឹងពីតម្រូវការរបស់ប្រជាជន និងកសាងទំនុកចិត្តរវាងប្រជាជនមូលដ្ឋាន នឹងក្រុមប្រឹក្សាឃុំ។ វាក៏ជាឱកាសសម្រាប់ឲ្យប្រជាជនអាចចូលរួមក្នុងគម្រោង និងការធ្វើផែនការថវិកា និងចូលរួមក្នុងការងារអភិវឌ្ឍន៍ តាមរយៈការបញ្ចេញមតិរបស់ខ្លួនអំពីតម្រូវការអភិវឌ្ឍន៍សហគមន៍ ព្រមទាំងទទួលបានព័ត៌មានអំពីសកម្មភាពរបស់ក្រុមប្រឹក្សាឃុំ។

អ្នកចូលរួមក្នុង FGD បានរក្សាទស្សនៈអព្យាក្រឹតអំពីការចូលរួមរបស់ខ្លួននៅក្នុងសកម្មភាពផ្សេងៗដោយទទួលស្គាល់ថា វាជា "កាតព្វកិច្ចរបស់រូបគាត់ ក្នុងការចូលរួមអភិវឌ្ឍសហគមន៍មូលដ្ឋានរបស់គាត់"។ ពួកគាត់មានអារម្មណ៍ថា ការចូលរួមនេះជួយឲ្យក្រុមប្រឹក្សាឃុំបានយល់ដឹងពីតម្រូវការរបស់គាត់ ហើយអាចបំពេញតាមតម្រូវការទាំងនោះបានកាន់តែប្រសើរ។ នៅក្នុង FGD មួយ អ្នកចូលរួម ៧នាក់ និយាយថា ពួកគាត់បានចូលរួមក្នុងសកម្មភាពអភិវឌ្ឍន៍សហគមន៍សំខាន់ៗជាច្រើន ព្រោះ "គាត់មានអារម្មណ៍ថា គាត់មានកាតព្វកិច្ចត្រូវចូលរួម (ដើម្បីផលប្រយោជន៍សហគមន៍)" ខណៈអ្នកចូលរួមម្នាក់ទៀត លើកថា គាត់ចូលរួមព្រោះគាត់ "ខ្លាចរដ្ឋ" (FGD ថ្ងៃទី១១ កក្កដា ២០១២)។ យោងតាមអ្នកចូលរួមម្នាក់នេះ ការបំពេញនូវទំនួលខុសត្រូវជាក់លាក់តាមការតម្រូវពីរដ្ឋ ជា "ការចាំបាច់" ព្រោះរដ្ឋមានអំណាចដើម្បីដាក់ទោសទណ្ឌលើអ្នកមិនប្រតិបត្តិតាម។ ការកត់សម្គាល់នេះ បង្ហាញថា បែបបទវប្បធម៌ និងបទពិសោធន៍ពីមុននៅតែមានឥទ្ធិពលលើការគិតគូររបស់ប្រជាជន ហើយធ្វើឲ្យខូចខាតដល់ការចូលរួមចំណែកមានផ្លែផ្កា ថ្វីបើការភ័យខ្លាចការបង្ក្រាប និងការបង្ខិតបង្ខំផ្សេងៗ បាននិងកំពុងរលាយបាត់ជាបណ្តើរៗក្តី។

---

[៤] អ្នកនិពន្ធ ទទួលស្គាល់ថា ក្នុងសង្គមកម្ពុជា បដិការកើតមានជាយូរមកហើយ ក្នុងទម្រង់ជា ទំនាក់ទំនងរវាងប្រជាជននិងប្រជាជន ទំនាក់ទំនងតាមរយៈបណ្តាញចៅហ្វាយនាយ-កូនចៅ និងទំនាក់ទំនងសាច់ញាតិ (Ledgerwood & Vijghen 2002)។ ការសិក្សានេះ បានផ្តោតទៅលើទំនាក់ទំនងរវាងរដ្ឋ និងសង្គម។

ការស្តាប់បង្គាប់ និងឥរិយាបថខ្លបខ្លាចខ្លះ បង្ហាញដោយអ្នកចូលរួមក្នុង FGD និងអ្នកឆ្លើយសម្ភាសន៍ ឆ្លុះបញ្ចាំងពីលក្ខខណ្ឌមួយដែលបានចាក់ឫសក្នុងបែបបទវប្បធម៌មានឋានានុក្រមក្នុងប្រទេសកម្ពុជា និងផលប៉ះពាល់នៃការគាបសង្កត់យូរឆ្នាំ និងការគ្រប់គ្រងបែបផ្តាច់ការ ដែលបានរារាំងដល់ការចូលរួមមានផ្លែផ្កា។ ការស្រាវជ្រាវពីមុនៗ បង្ហាញថា ប្រជាជនកម្ពុជាច្រើនរារែកក្នុងការចូលរួមក្នុងកិច្ចប្រជុំ និងសកម្មភាពសាធារណៈ។ ដូចមានលើកឡើងក្នុងការស្រាវជ្រាវរបស់ KIM ... មូលហេតុ និងគំនិតបង្កប់នៃការរារែកឡើងបញ្ចេញមតិក្នុងវេទិកាសាធារណៈ គឺជាលទ្ធផលនៃការអៀនខ្មាស់ ប៉ុន្តែស្ទើរគ្រប់គ្នានិយាយផ្សេងថា វាជាទំនៀមទម្លាប់... (KIM 2011:184)។

ការសិក្សាមុនៗ បង្ហាញថា ប្រជាជនភាគច្រើនអវត្តមាននៅពេលប្រជុំធ្វើផែនការអភិវឌ្ឍន៍ (កិច្ចប្រជុំក្រុមប្រឹក្សា) ដោយសារស្ថានភាពក្រីក្ររបស់គាត់ (CAS 2007)។ ជីវភាពក្រីក្របង្អាក់ទឹកចិត្តក្នុងការចូលរួម។ ទោះបីកំណែទម្រង់គោលនយោបាយនានា បានជួយកាត់បន្ថយអត្រាភាពក្រីក្រជារួមក្តី ក៏ប្រជាជនជនបទកម្ពុជាជាច្រើននាក់នៅក្រីក្រនៅឡើយ។ ចំណុចនេះតម្រូវឲ្យពួកគាត់ចំណាយពេលច្រើនក្នុងការរកចិញ្ចឹមជីវិត ដោយមិនផ្តល់អាទិភាពដល់សកម្មភាពសាធារណៈទេ (COMFREL 2007; EIC 2012; KAS 2007)។ ឧបសគ្គមួយទៀតដល់ការចូលរួមធ្វើផែនការអភិវឌ្ឍន៍ គឺក្រុមប្រឹក្សាឃុំអសមត្ថភាពក្នុងការឆ្លើយតបនឹងតម្រូវការរបស់ពលរដ្ឋ។

ឧបសគ្គដែលរារាំងការចូលរួមរបស់ប្រជាជន វាកាត់បន្ថយទឹកចិត្តប្រឹងគិតគូរពិចារណាពិតៗពីតម្រូវការក្នុងមូលដ្ឋានក្នុងការអភិវឌ្ឍសហគមន៍ និងលទ្ធភាពពង្រឹងកិច្ចសហប្រតិបត្តិការវាងប្រជាពលរដ្ឋ និងក្រុមប្រឹក្សារបស់ពួកគេ។

### ២.២.៣ ភាពពេញចិត្តរបស់ប្រជាពលរដ្ឋចំពោះសេវារដ្ឋផ្តល់ឲ្យ

ការប្រជុំ FGDs នៅខេត្តបាត់ដំបង ជាទូទៅ បង្ហាញនូវភាពពេញចិត្តកម្រិតខ្ពស់របស់ប្រជាពលរដ្ឋចំពោះសេវារបស់រដ្ឋ។ ប៉ុន្តែអ្នកចូលរួមភាគច្រើនបញ្ជាក់តិចតួចណាស់ពីសេវាសង្គមនីមួយៗ តែបានលើកថា ប្រទេសជាតិមានសុខសន្តិភាព ហើយមានការល្អប្រសើរឡើងជាក់ស្តែងក្នុងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត (ជាពិសេស ផ្លូវថ្នល់) ដែលជាការចូលរួមចំណែកដ៏សំខាន់ ឬជាសេវារបស់រដ្ឋ។ ភាពពេញចិត្តកម្រិតខ្ពស់នេះ អាចមកពីក្នុង ៣០ឆ្នាំកន្លងទៅនេះ ប្រទេសមិនដែលមានផ្តល់សេវាសាធារណៈកម្រិតខ្ពស់ដូចសព្វថ្ងៃទេ។ ប្រជាជន ជាពិសេសអ្នកវ័យកណ្តាល និងវ័យចំណាស់ នៅតែភ័យខ្លាចពីអតីតកាលដ៏វឹកវរ។ ការចងចាំពីការលំបាកនេះ ធ្វើឲ្យពួកគេនឹកឃើញថា ស្ថិរភាព សន្តិភាព និងវឌ្ឍនភាពដែលកម្ពុជាសម្រេចបាននាបច្ចុប្បន្ន គឺជាសមិទ្ធផលដ៏សំខាន់ ដូច្នេះគួរតែដឹងគុណប្រទេសជាតិ។ ចំណុចនេះ បង្កើតជាការរំពឹងសង្ឃឹមតិចតួចបំផុតអំពីអ្វីដែលរដ្ឋគួរតែផ្តល់ឲ្យប្រជាពលរដ្ឋ។

ភាពពេញចិត្តកម្រិតខ្ពស់របស់ប្រជាពលរដ្ឋចំពោះសេវារដ្ឋផ្តល់ឲ្យ មានបញ្ជាក់ជាទូទៅក្នុងការសិក្សាថ្មីៗជាច្រើន។ យោងតាមអង្កេតមួយអំពីភាពពេញចិត្តរបស់ប្រជាពលរដ្ឋ ដែលអនុវត្តដោយ EIC ប្រជាជនភាគច្រើន (អ្នកឆ្លើយសម្ភាសន៍ ២៣៤១នាក់) យល់ស្របថា ក្រុមប្រឹក្សាឃុំមានការឆ្លើយតបប្រសើរជាងមុនចំពោះតម្រូវការរបស់ប្រជាពលរដ្ឋ។ អង្កេតរបស់ វិទ្យាស្ថានសាធារណរដ្ឋអន្តរជាតិ (IRI, 2012) ស្តីពី មតិសាធារណជនកម្ពុជា ក៏បង្ហាញពីភាពពេញចិត្តកម្រិតខ្ពស់របស់ប្រជាពលរដ្ឋចំពោះសេវារដ្ឋដែរ។

## ២.៣ សេចក្តីសន្និដ្ឋាន

ចាប់តាំងពីការអនុវត្តវិមជ្ឈការជាលើកដំបូងនៅឆ្នាំ២០០២ មក សង្គម និងរដ្ឋ ហាក់មានទំនាក់ទំនងតភ្ជាប់គ្នាឡើងវិញ។ តំបន់ជនបទកម្ពុជា កាន់តែមានលក្ខណៈចម្រុះ ស្មុគស្មាញ និងបើកចំហជាងមុន (Ojendal & Kim 2006:526)។ ទំនាក់ទំនងរវាងរដ្ឋ និងប្រជាជន ក៏ហាក់ដូចជាកាន់តែស្និទ្ធស្នាលឡើងដែរ។ ទន្ទឹមគ្នានេះ ស្ថាប័នរដ្ឋនានាដែលទទួលបានថវិកា ក៏ខំព្យាយាមឆ្លើយតបនឹងតម្រូវការរបស់ប្រជាជន (Ojendal & Kim 2006; Kim & Ojendal 2009; Heng *at al.* 2011)។ ដំណើរការកំណែទម្រង់ បានធ្វើឲ្យប្រជាពលរដ្ឋ ពេញចិត្តក្នុងការចូលរួមវិភាគទានដល់រដ្ឋ។ នាបច្ចុប្បន្ន ការចូលរួមវិភាគទានសំខាន់ៗរបស់ប្រជាជនដល់អាជ្ញាធរមូលដ្ឋាន នៅមានទំហំតូច ដូចជា ការផ្តល់វិភាគទានជាសាច់ប្រាក់ និងសម្ភារៈផ្សេងៗ ទៅដល់គម្រោងអភិវឌ្ឍន៍មូលដ្ឋាន ជាដើម។ ទោះយ៉ាងនេះក្តី ពួកគេពេញចិត្តនឹងចូលរួមវិភាគទានយ៉ាងទៀងទាត់ក្នុងទម្រង់ជាការបង់ពន្ធ (ឧទាហរណ៍ ពន្ធដីធ្លី) ប្រសិនបើចំណូលពីការរួមចំណែកនោះត្រូវបានរក្សាទុកក្នុងមូលដ្ឋាន និងយកទៅប្រើប្រាស់ប្រកបដោយតម្លាភាពសម្រាប់ការអភិវឌ្ឍនៅក្នុងមូលដ្ឋាន។ ចំណុចនេះបង្ហាញថា មូលដ្ឋានគ្រឹះសម្រាប់ទំនាក់ទំនងជាបដិការរវាងសង្គម-រដ្ឋ ត្រូវបានបង្កើតឡើងរួចជាស្រេចហើយ។

បញ្ហាប្រឈមនៅខាងមុខ គឺ តើត្រូវធ្វើយ៉ាងណាដើម្បីរឹតចំណងទាក់ទងរវាងរដ្ឋ និងសង្គម ព្រមទាំងប្រែក្លាយវាឲ្យទៅជាទំនាក់ទំនងជាបដិការផ្លូវការមួយ។ គណនេយ្យភាព តម្លាភាព និងការឆ្លើយតបពីសំណាក់រដ្ឋ និង ការលើកកម្ពស់ការយល់ដឹង និងការចូលរួមពីសំណាក់ប្រជាពលរដ្ឋ ជាកត្តាដ៏ចាំបាច់ពីរសម្រាប់តភ្ជាប់ទំនាក់ទំនងរវាងរដ្ឋ និងសង្គម។

ទោះបីមានការល្អប្រសើរឡើងយ៉ាងច្បាស់នូវ ការយល់ដឹងក្នុងចំណោមប្រជាពលរដ្ឋអំពីសិទ្ធិ និងទំនួលខុសត្រូវរបស់ពលរដ្ឋ ក៏ចន្លោះខ្វះខាតចំណេះដឹងនៅតែឃើញមាន ហើយកម្រិតចំណេះដឹងទាំងនោះក៏មិនទាន់កើតមានជាទូទៅដែរ។ ក្នុងការចុះសិក្សាដល់កន្លែងនាពេលថ្មីៗ សំណូមពរមួយដែលក្រុមប្រឹក្សាឃុំជាទូទៅបានលើកឡើងគឺ "ប្រជាជនគួរទទួលបានការអប់រំ និងការបណ្តុះបណ្តាលស្តីពីសិទ្ធិ តួនាទី និងកាតព្វកិច្ចជាពលរដ្ឋរបស់គាត់"។

## ឯកសារយោង


Beall, Jo (2005), "Decentralizing Government and Decentering Gender: Lessons from Local Government Reform in South Africa," Politics and Society, 33 (2), pp. 253-276

Centre for Advanced Study (2001), Democracy in Cambodia: A Survey of the Cambodian Electorate (Phnom Penh: Asia Foundation)

Centre for Advanced Study (2007), Social Accountability Public Opinion Poll Findings (Phnom Penh: World Bank)

COMFREL (2007), Assessment of the First Term of Decentralisation in Cambodia: Commune Council Performance and Citizens' Participation, 2002-2007 (Phnom Penh: COMFREL)

Dabo, Awa, Jago Salmon, Moises Venancio & Patrick Keuleers (2010), "Local Governance, Peace Building and State Building in Post-conflict Settings," A UNDP Discussion paper, www.uncdf.org/gfld/docs/post-conflict.pdf (accessed 1 August 2012)

Department for International Development (2010), Building Peaceful States and Societies, A DFID Practice Paper, (UK: DFID)

Ear Sophal (2006), "The Political Economy of Aid, Governance, and Policy-Making: Cambodia in Global, National and Sectoral Perspectives", PhD dissertation, University of California, Berkely

Edigheji, Oghenemano Emmanuel (2003), "State-society Relations in Post-apartheid South Africa: The Challenges of Globalisation in Co-operative Governance," in G. Mhone & O.Edigheji (eds.) Governance in the New South Africa: The Challenges of Globalisation (Cape Town: University of Cape Town Press)

Edigheji, Omano (2007), "The State, State-Society Relations and Developing Countries' Economic Performance," PhD dissertation, Norwegian University of Science and Technology

EIC (2010), Report of the Second Citizen Satisfaction Survey in Target Communes of the LAAR Project (Phnom Penh: EIC)

Ek Chanboreth & Sok Hach (2008), "Aid Effectiveness in Cambodia," Wolfensohn Center for Development, Working Paper 7 (Washington, DC: Brookings Institution)

Heng Seiha, Kim Sedara & So Sokbunthoeun (2011), Decentralised Governance in a Hybrid Polity: Localisation of Decentralisation in Cambodia, Working Paper 63 (Phnom Penh: CDRI)

Hughes, Caroline (2009), Dependent Communities: Aid and Politics in Cambodia and East Timor (New York: Cornell University)

Internatinal Republican Institute, "Survey of Cambodian Public Opinion," http://www.iri.org/news-events-press-center/news/iri-releases-survey-cambodian-public-opinion-0 (accessed 1 August 2012)

KAS (2007), Cambodian Commune Councils in the First Term (Phnom Penh: KAF)

Kim Sedara (2011), "Democracy in Action: Decentralization in Post-Conflict Cambodia", PhD dissertation, Goteborg University

Kim Sedara & Joakim Öjendal (2009), "Decentralization as a Strategy for State Reconstruction in Cambodia", in J. Öjendal & M. Lilja (eds.) Beyond Democracy in Cambodia: Political Reconstruction in a Post-Conflict Society (Copenhagen: NIAS Press) pp. 101–135

Ledgerwood, Judy & John Vijghen (2002), "Decision-making in Rural Khmer Villages", in J. Ledgerwood (ed.) Cambodia Emerges from the Past: Eight Essays (Dekalb,IL: Center for Southeast Asian Studies, Northern Illinois University)

Malena, Carmen & Kristina Chhim (2009), Linking the Citizens and the State: An Assessment of Civil Society Contributions to Good Governance in Cambodia (Phnom Penh: World Bank)

Öjendal, Joakim & Kim Sedara (2006), "Korob, Kaud, Klach: In Search of Agency in Rural Cambodia", Journal of Southeast Asia Studies, 37 (3), pp. 507–526

-៣-

# រចនាសម្ព័ន្ធអប់រំថ្នាក់ឧត្តមសិក្សានៅកម្ពុជា និងការជំពាក់ទាក់ទងជាមួយ សហគមន៍សេដ្ឋកិច្ចអាស៊ានឆ្នាំ២០១៥

*ដោយលោក សែន វិចិត្រ*[១]

## ៣.១ សេចក្តីផ្តើម

កម្ពុជា បាននិងកំពុងព្យាយាមស្តាបនាឡើងវិញ និងពង្រីកបន្ថែមនូវប្រព័ន្ធអប់រំថ្នាក់ឧត្តមសិក្សាឲ្យបានស្របតាមតម្រូវការ និងសេចក្តីប្រាថ្នារបស់ប្រជាជនខ្លួន។ ក្នុងអំឡុងពីរទសវត្សរ៍កន្លងទៅនេះ ប្រព័ន្ធអប់រំថ្នាក់ឧត្តមសិក្សាកម្ពុជា មានការរីកលូតលាស់ ប៉ុន្តែក្នុងលក្ខណៈមិនមានការត្រួតពិនិត្យត្រឹមត្រូវនៅឡើយទៅលើការចុះឈ្មោះចូលរៀន និងទៅលើអ្នកផ្តល់សេវាអប់រំថ្នាក់ឧត្តមសិក្សា។អត្រារីកលូតលាស់កាន់តែមានល្បឿនលឿនឡើងចាប់តាំងពីមានសេរីភាវូបនីយកម្មនៃការផ្តល់សេវាអប់រំថ្នាក់ឧត្តមសិក្សាក្នុងឆ្នាំ១៩៩៧ មក។ ចំនួនសិស្សចុះឈ្មោះចូលរៀននៅគ្រឹះស្ថានអប់រំថ្នាក់ឧត្តមសិក្សា (HEIs) បានកើនឡើងទ្វេដងពី ១១៧.៤២០នាក់ នៅឆ្នាំសិក្សា២០០៦-២០០៧ ដល់ ២៤៥.៣២៩នាក់ នៅឆ្នាំសិក្សា២០១១-២០១២ (You, 2012)។ ចំនួន HEIs នៅកម្ពុជា កើនឡើងគួរឲ្យកត់សម្គាល់ពី ១០ស្ថាប័ន ក្នុងទសវត្សរ៍ឆ្នាំ១៩៩០ (Pak, 2011) ដល់ ៩៧ ស្ថាប័ន នៅត្រីមាសទី១ ឆ្នាំ២០១២ (You, 2012)។ ការលូតលាស់ឆាប់រហ័សនៃប្រព័ន្ធនេះ និងអត្រាចុះឈ្មោះចូលរៀន មានផលប៉ះពាល់យ៉ាងច្រើនដល់ប្រព័ន្ធអប់រំថ្នាក់ឧត្តមសិក្សា អ្នកផ្តល់សេវាអប់រំថ្នាក់ឧត្តមសិក្សា និស្សិតនិងគ្រួសារពួកគេ និងកម្លាំងពលកម្មរបស់ប្រទេស។ លើសពីនេះទៀត សមាហរណកម្មទៅក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ាន (AEC) ដែលគ្រោងនឹងចាប់ផ្តើមនៅឆ្នាំ២០១៥ នោះ នឹងបង្កើនភាពជំពាក់ជំពិនថែមទៀតជាមួយប្រព័ន្ធអប់រំថ្នាក់ឧត្តមសិក្សានៅកម្ពុជា។ អត្ថបទនេះ មានគោលបំណងផ្តល់នូវទិដ្ឋភាពរួមមួយអំពី រចនាសម្ព័ន្ធអភិបាលកិច្ចនៃប្រព័ន្ធអប់រំថ្នាក់ឧត្តមសិក្សានៅកម្ពុជានាបច្ចុប្បន្ន និងការជំពាក់ទាក់ទងនៃការរៀបចំរចនាសម្ព័ន្ធនេះ ជាមួយនឹងអ្នកពាក់ព័ន្ធទាំងឡាយ ក៏ដូចជា សេដ្ឋកិច្ចរបស់ប្រទេស។ អត្ថបទនេះ នឹងពិនិត្យដែរពី ការជំពាក់ទាក់ទងរវាង សហគមន៍សេដ្ឋកិច្ចអាស៊ានឆ្នាំ២០១៥ និងប្រព័ន្ធអប់រំថ្នាក់ឧត្តមសិក្សានៅកម្ពុជា។

## ៣.២ រចនាសម្ព័ន្ធប្រព័ន្ធអប់រំថ្នាក់ឧត្តមសិក្សានៅកម្ពុជា

ប្រព័ន្ធអប់រំថ្នាក់ឧត្តមសិក្សានៅកម្ពុជានាបច្ចុប្បន្ន រួមមាន ១៤ ទីភ្នាក់ងាររដ្ឋ ដែលត្រួតពិនិត្យលើ ៩៧ HEIs និងសាខាតាមខេត្តជាច្រើនទៀត[២]។ លក្ខណៈសំខាន់បំផុតគឺ បើទោះជាមាន

[១] លោក សែន វិចិត្រ ជាអ្នកស្រាវជ្រាវ កម្មវិធីអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ និងកំណែទម្រង់សាធារណៈនៃវិទ្យាស្ថាន CDRI។

[២] ទិន្នន័យនេះ ទទួលបាននៅដើមឆ្នាំ២០១២។ នៅពេលនោះ មានលេចឮថា មានក្រសួងខ្លះទៀតគ្រោងចាប់ដំណើរការ HEIs ដែរ។ ដូច្នេះនាបច្ចុប្បន្ន ប្រហែលមានទីភ្នាក់ងាររដ្ឋាភិបាលកាន់តែច្រើនដែលកំពុងត្រួតត្រាលើ HEIs កាន់តែច្រើនដែរ។

ទីភ្នាក់ងារ និងក្រសួងមេជាច្រើនក្ដី ក៏មិនមានអង្គភាព ឬអាជ្ញាធរត្រួតពិនិត្យរួមណាមួយ ត្រូវបានកំណត់ឡើងដើម្បីសម្របសម្រួលស្ថាប័នអប់រំថ្នាក់ឧត្ដមសិក្សាទាំងអស់នោះឡើយ ជាពិសេសនៅក្នុងការបង្កើត ការអនុវត្ត និងការត្រួតពិនិត្យគោលនយោបាយអប់រំថ្នាក់ជាតិ (Sen & Ros ចេញផ្សាយនាពេលឆាប់ៗនេះ)[៣]។ ថ្វីបើនាយកដ្ឋានឧត្ដមសិក្សា (DHE) នៃក្រសួងអប់រំ យុវជន និងកីឡា (MoEYS) ហាក់កំពុងដើរតួនាទីសំខាន់ក្នុងការសម្របសម្រួល ព្រោះ HEIs ជាច្រើនស្ថិតនៅក្រោមការត្រួតត្រារបស់ខ្លួនក្ដី ប៉ុន្តែតួនាទីនាយកដ្ឋាននេះមានដែនអនុវត្តតូចចង្អៀតណាស់។ កិច្ចសហការរវាង DHE/MoEYS ជាមួយក្រសួងមេដទៃទៀត មានពាក់ព័ន្ធតែលើមុខងារមួយចំនួនតូច ដូចជា ការជ្រើសរើសនិស្សិតទទួលអាហារូបករណ៍ពីរដ្ឋាភិបាល ការផ្ដល់ជំនួយបច្ចេកទេសលើវគ្គសិក្សាជាក់លាក់ខ្លះៗ និងកិច្ចពិភាក្សាខាងគោលនយោបាយមួយចំនួន។ DHE/MoEYS ហាក់មិនមានសិទ្ធិអំណាចគ្រប់គ្រាន់ សម្រាប់ត្រួតពិនិត្យដំណើរការអនុវត្តគោលនយោបាយផ្នែកអប់រំឡើយ។ ចំណុចនេះបង្ហាញនូវកម្រិតឥទ្ធិពល ឬអំណាចដែល DHE/MoEYS មាន ធៀបទៅនឹងក្រសួងមេដទៃទៀត។ ច្បាប់ស្ដីពីការអប់រំនៅកម្ពុជា[៤] មិនមានផ្ដល់តួនាទីដាច់ដោយឡែកឲ្យក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ (MoLVT) ទេ បើទោះជាមាន HEIs ជាច្រើន ស្ថិតនៅក្រោមការត្រួតត្រារបស់ក្រសួងនេះក្ដី។ បញ្ហានេះបានបង្កើតជាចន្លោះប្រហោងនៅក្នុងក្របខ័ណ្ឌគោលនយោបាយបច្ចុប្បន្នដែលហាក់មានផលប៉ះពាល់ខ្លាំងទៅលើ ប្រព័ន្ធអប់រំថ្នាក់ឧត្ដមសិក្សាទាំងមូលរបស់កម្ពុជា។

ច្បាប់ស្ដីពីការអប់រំនៅកម្ពុជា (RGC 2007) មានចែងពីការបង្កើតឧត្ដមក្រុមប្រឹក្សាអប់រំជាតិ (SNCE) ដែលមានតួនាទីស្នើជាយុទ្ធសាស្ត្ររយៈពេលវែង និងគោលនយោបាយផ្នែកអប់រំដើម្បីឆ្លើយតបនឹងតម្រូវការសង្គម មានតួនាទីវាយតម្លៃលទ្ធផលដំណើរការនៃប្រព័ន្ធអប់រំ ព្រមទាំងកំណត់ និងប្រមូលធនធានចាំបាច់សម្រាប់ផ្នែកអប់រំ។ ទោះយ៉ាងណាក្ដី អង្គភាពនេះមិនទាន់បានបង្កើតឡើងទេ នៅពេលកំពុងសរសេរអត្ថបទនេះ ហើយបញ្ហានេះបានរាំងស្ទះដល់ដំណើរការសម្របសម្រួលថ្នាក់ជាតិសម្រាប់ក្រសួងមេនានា ធ្វើឲ្យប្រព័ន្ធអប់រំថ្នាក់ឧត្ដមសិក្សាលំបាកនឹងបំពេញតាមកំណើនតម្រូវការរបស់និស្សិត ដែលប្រាថ្នាចង់បានការអប់រំបន្ថែមទៀត ស្របតាមតម្រូវការទីផ្សារពលកម្ម។ ចរិតលក្ខណៈនៃរចនាសម្ព័ន្ធអភិបាលកិច្ចនាពេលបច្ចុប្បន្នរបស់ប្រព័ន្ធអប់រំថ្នាក់ឧត្ដមសិក្សានៅកម្ពុជា មានការជំពាក់ទាក់ទងសំខាន់ណាស់ជាមួយ ការសម្របសម្រួល និងការប្រើប្រាស់ធនធាន ការអនុវត្តនិងត្រួតពិនិត្យគោលនយោបាយអប់រំ គុណភាពនិងទំនាក់ទំនងរវាងការអប់រំជាមួយសេដ្ឋកិច្ចនិងទីផ្សារការងារ លទ្ធភាពទទួលបានការងារក្រោយពេលបញ្ចប់ការសិក្សា និងបញ្ហាសង្គមពាក់ព័ន្ធដទៃទៀត។

---

[៣] ការរៀបរៀងភាគច្រើននៅក្នុងអត្ថបទនេះ ផ្អែកលើឯកសារពិភាក្សារបស់ CDRI ស្ដីពីលក្ខណៈលំអិតនៃអភិបាលកិច្ចការអប់រំថ្នាក់ឧត្ដមសិក្សានៅកម្ពុជា ដោយអ្នកនិពន្ធលោក សែន វិចិត្រ និងលោក រស់ សុវាចា។

[៤] គួរកត់សម្គាល់ថា MoLVT ត្រូវបានបង្កើតឡើងដោយរាជរដ្ឋាភិបាលកម្ពុជានៅឆ្នាំ២០០៥ (RGC, 2005)។ ដូច្នេះគួរឲ្យភ្ញាក់ផ្អើលដែរ ដែលច្បាប់អនុម័តចេញក្នុងឆ្នាំ២០០៧ ស្ដីពីការអប់រំនៅកម្ពុជាមិនមានបទបញ្ញត្តិដាច់ដោយឡែកមួយសម្រាប់តួនាទីនៃ MoLVT បើទោះជាក្រសួងនេះមានចំណែកធំដែរក្នុងការត្រួតពិនិត្យការអប់រំ និងបណ្ដុះបណ្ដាលនៅកម្ពុជា។

### ៣.២.១ ការសម្របសម្រួល ការប្រើប្រាស់ធនធាន និង ការអនុវត្តនិងត្រួតពិនិត្យគោលនយោបាយអប់រំ

វត្តមានអាជ្ញាធរត្រួតពិនិត្យផ្សេងៗជាច្រើនក្រុមនៅក្នុងប្រព័ន្ធអប់រំថ្នាក់ឧត្តមសិក្សានៅកម្ពុជានាបច្ចុប្បន្ន បង្ហាញពីភាពដាច់ដោយដុំខាងផ្នែករចនាសម្ព័ន្ធ។ ក្រសួងមេជាច្រើនដែលត្រួតត្រាលើ HEIs ហាក់ដូចជាអង្គភាពដាច់ដោយឡែកពីគ្នា និងធ្វើការងារដោយឯករាជ្យរៀងខ្លួននៅក្នុងដែនដ៏ធំទូលាយនៃការអប់រំថ្នាក់ឧត្តមសិក្សា។ អវត្តមាននៃអង្គភាពជាក់លាក់មួយដែលមានសិទ្ធិអំណាច មានការទទួលស្គាល់គ្រប់គ្រាន់ សម្រាប់ត្រួតពិនិត្យលើការអនុវត្តរបស់ HEIs ហើយអាចទាមទារគណនេយ្យភាពពីក្រសួងមេនានា បានបង្កការលំបាកខ្លាំងដល់កិច្ចសហការទូទាំងប្រព័ន្ធ (UNDP 2011; HRINC 2010)។ សេណារីយ៉ូនេះ ហាក់នាំឲ្យមានចន្លោះប្រហោងក្នុងការអនុវត្ត និងត្រួតពិនិត្យគោលនយោបាយអប់រំថ្នាក់ជាតិ ដោយទុកឲ្យក្រសួងមេនីមួយៗ និង HEIs មានសេរីភាពពេញលេញក្នុងការអនុវត្តគោលនយោបាយអប់រំតាមអំពើចិត្តខ្លួន។ ក្នុងរយៈពេលវែង បញ្ហានេះនឹងធ្វើឲ្យប្រព័ន្ធអប់រំថ្នាក់ឧត្តមសិក្សាចុះខ្សោយជាលំដាប់។

ការរចនារៀបចំប្រព័ន្ធអប់រំថ្នាក់ឧត្តមសិក្សានាពេលបច្ចុប្បន្ន មានភាពជំពាក់ទាក់ទងសំខាន់ជាមួយនឹងការប្រើប្រាស់ធនធាន ដោយមិនបានផ្ដល់មធ្យោបាយអ្វីសក្ដិសិទ្ធិសម្រាប់ការបែងចែកនិងការប្រើប្រាស់ធនធានដែលមានស្រាប់ ហើយបានបង្កជាការខ្វះខាតធនធានដែលកំពុងមានកំហិត និងបង្កើតនូវតួនាទី និងទំនួលខុសត្រូវត្រួតគ្នា។ មន្ត្រីរដ្ឋាភិបាលជាន់ខ្ពស់ម្នាក់ ធ្វើការកត់សម្គាល់ថា ប្រព័ន្ធអប់រំថ្នាក់ឧត្តមសិក្សាដែលមានលក្ខណៈដាច់ដោយដុំនាពេលបច្ចុប្បន្ននេះ គួបផ្សំនឹងវត្តមាននៃក្រសួងមេច្រើនពេក ដោយមិនមានអង្គភាពទទួលខុសត្រូវរួមមួយនោះ បានបង្កការលំបាកដល់ការវិនិយោគដើម្បីលើកកម្ពស់ការអប់រំថ្នាក់ឧត្តមសិក្សា ដោយសារធនធានដែលមានតិចនោះ ត្រូវបែងចែកទៅឲ្យអង្គភាពផ្សេងៗគ្នាជាច្រើន។ បញ្ហានេះប៉ះពាល់ខ្លាំងទៅលើគុណភាព និងប្រសិទ្ធភាពនៃការអនុវត្ត និងត្រួតពិនិត្យគោលនយោបាយអប់រំនៅកម្រិតជាតិ។

### ៣.២.២ ភាពជាប់ទាក់ទងល្អ និងគុណភាពនៃការអប់រំ

ដោយសារអវត្តមាននៃអង្គភាពត្រួតពិនិត្យសម្រាប់តម្រង់ទិសដល់ កិច្ចប្រឹងប្រែងជារួមក្នុងការអភិវឌ្ឍមូលធនមនុស្សឲ្យបានស្របតាមតម្រូវការទីផ្សារពលកម្មនោះ មានបាតុភូតធ្ងន់ធ្ងរមួយបានកើតឡើងក្នុងប្រព័ន្ធអប់រំថ្នាក់ឧត្តមសិក្សានៅកម្ពុជានាពេលបច្ចុប្បន្ន ពោលគឺ HEIs មានផ្ដល់ជាកម្មវិធី ឬវគ្គសិក្សាដែលមានតម្រូវការខ្ពស់ពីនិស្សិតអ្នកមកបង់ប្រាក់ចូលរៀន[៥] ប៉ុន្តែកម្មវិធីទាំងនោះមិនមែនសុទ្ធតែជាប់ទាក់ទងល្អទៅនឹងតម្រូវការទីផ្សារពលកម្មឡើយ។សេណារីយ៉ូនេះកាន់តែលេចច្បាស់ឡើងក្នុងស្ថានភាពបច្ចុប្បន្នដែលរដ្ឋផ្ដល់ហិរញ្ញប្បទានតិចតួចដល់ HEIs សាធារណៈ និងសឹងតែគ្មានផ្ដល់សោះទៅឲ្យ HEIs ឯកជន ដែលធ្វើឲ្យរដ្ឋ បាត់បង់ឥទ្ធិពលទៅលើកម្មវិធី ឬវគ្គសិក្សាផ្ដល់ដោយ HEIs។ បញ្ហានេះ អាចកាន់តែធ្វើឲ្យអាក្រក់ឡើងនូវស្ថានភាពមិនស៊ីគ្នាខាងផ្នែកជំនាញនៅក្នុងប្រទេស ដោយផ្នែកខ្លះមានការផ្គត់ផ្គង់ច្រើនពេក ឯផ្នែកសំខាន់ៗខ្លះទៀតសម្រាប់

---

[៥] ហិរញ្ញប្បទានដ៏ច្រើនពីប្រភពឯកជនសម្រាប់ការអប់រំថ្នាក់ឧត្តមសិក្សានៅកម្ពុជា ស្ទើរទទួលបានទាំងស្រុងពីប្រាក់បង់ថ្លៃសិក្សារបស់និស្សិត ហើយគេប៉ាន់ស្មានថា វារួមចំណែកលើស ៨០% នៃហិរញ្ញប្បទានសរុបសម្រាប់ការអប់រំថ្នាក់ឧត្តមសិក្សា។ បាតុភូតនេះធ្វើឲ្យស្ថានភាពហិរញ្ញប្បទានរដ្ឋាភិបាល/ឯកជន មានភាពបញ្ច្រាសទិសនឹងបណ្ដាប្រទេសកំពុងអភិវឌ្ឍន៍ភាគច្រើន (World Bank, 2010a)។

ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ បែរជាមានការផ្គត់ផ្គង់មិនគ្រប់គ្រាន់[៦]។ ក្នុងរយៈពេលវែង វាធ្វើឲ្យសេដ្ឋកិច្ចធ្លាក់ល្បឿនលូតលាស់ ព្រមទាំងថយចុះសមត្ថភាពប្រកួតប្រជែង។

បញ្ហានេះ ក៏មានជាប់ជំពាក់ទាក់ទងដល់គុណភាពការអប់រំថ្នាក់ឧត្តមសិក្សាដែលផ្តល់ទៅឲ្យនិស្សិតផងដែរ។ ក្នុងស្ថានភាពដែលមិនមានអង្គភាពចាត់តាំងដើម្បីធានាប្រសិទ្ធភាពការអនុវត្តគោលនយោបាយអប់រំ និងត្រួតពិនិត្យគោលដៅអនុវត្តរបស់ HEIs ធៀបនឹងអាទិភាពសម្រាប់ការអភិវឌ្ឍជាតិនោះ HEIs ច្រើនតែសម្រួលបន្ធូរបន្ថយគុណភាពការអប់រំដោយកាត់កងផ្នែកខ្លះចេញដើម្បីបានចំណេញកាន់តែច្រើន អាចធ្វើអាជីវកម្មបានយូរឆ្នាំ ឬមិនដួលរលំឆាប់ពេក។ ស្ថានភាពនេះកាន់តែគ្រោះថ្នាក់ថែមទៀតនៅកម្ពុជា ដោយសារអង្គភាពដែលផ្តល់ការទទួលស្គាល់ផ្នែកគុណភាពនៅបន្តផ្តល់ការទទួលស្គាល់លើកម្មវិធី ហើយមិនទាន់ឈានទៅដល់លក្ខណៈជាស្ថាប័នផ្តល់ការទទួលស្គាល់គុណភាពពេញលេញនៅឡើយ បើទោះជាអង្គភាពនេះបានកើតឡើងប្រហែលមួយទសវត្សរ៍ហើយក្តី (Pijano, 2012)។

### ៣.២.៣ លទ្ធភាពទទួលបានការងារធ្វើក្រោយបញ្ចប់ការសិក្សា និងបញ្ហាសង្គមពាក់ព័ន្ធ

លទ្ធភាពទាបក្នុងការទទួលបានការងារនៃនិស្សិតបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យ ជាផលវិបាកមួយទៀតនៃអវត្តមានអង្គភាពសម្រាប់គ្រប់គ្រងរួមពីលើ និងកង្វះភាពជាប់ទាក់ទងល្អនិងគុណភាពនៃការអប់រំ។ ការគន់គូរពីទីផ្សារការងារអនុវត្តដោយក្រុមហ៊ុន HRINC បានផ្តល់ឧទាហរណ៍ច្បាស់មួយនៃកង្វះលទ្ធភាពទទួលបានការងារធ្វើរបស់និស្សិតបញ្ចប់ការសិក្សា ដោយសារភាពមិនស៊ីគ្នារវាងតម្រូវការ និងការផ្គត់ផ្គង់និស្សិតចេញពីសាកលវិទ្យាល័យ និងបញ្ហាកង្វះចំណេះដឹងនិងជំនាញចាំបាច់ដើម្បីទទួលបានការងារ។ លទ្ធផលពីអង្កេតផ្សេងៗបង្ហាញថា យុវជនកម្ពុជាជាច្រើន ខ្វះទាំងជំនាញបច្ចេកទេស និងគុណសម្បត្តិផ្ទាល់ខ្លួន (World Bank 2010b) ហើយនិយោជកភាគច្រើន មិនពេញចិត្តនឹងជំនាញដែលយុវជនទាំងនោះមានឡើយ (CAMFEBA 2008)។ ចំណុចនេះ បានកាត់បន្ថយលទ្ធភាពទទួលបានការងារធ្វើក្រោយបញ្ចប់ការសិក្សា ហើយក្នុងរយៈពេលវែង ទំនងបង្កបញ្ហាភាពមានការងារធ្វើមិនពេញលេញ ឬគ្មានការងារធ្វើ ចំពោះនិស្សិតបញ្ចប់ការសិក្សា និងយុវជន។

អត្រាយុវជនគ្មានការងារធ្វើកម្រិតខ្ពស់ ទំនងជារួមចំណែកបង្កើនបញ្ហាសង្គមផ្សេងៗ ដូចជាបទឧក្រិដ្ឋ និងឥរិយាបថប្រកបដោយគ្រោះថ្នាក់គ្រប់ប្រភេទ។ កម្ពុជាទំនងត្រូវប្រឈមកាន់តែខ្លាំងនឹងភាពវឹកវរក្នុងសង្គមដែលកើតចេញពីអត្រាគ្មានការងារធ្វើកម្រិតខ្ពស់ក្នុងចំណោមយុវជន ប្រសិនបើ HEIs នៅក្នុងស្រុក មិនអាចផលិតកម្លាំងពលកម្មគ្រប់គ្រាន់ដែលមានជំនាញ និងចំណេះដឹង

---

៦ ផ្អែកលើការគន់គូរពីទីផ្សារការងារអនុវត្តដោយ HRINC សម្រាប់អំឡុងឆ្នាំ២០០៩-២០១៤ ប្រព័ន្ធអប់រំថ្នាក់ឧត្តមសិក្សានៅកម្ពុជា រំពឹងថានឹងផ្គត់ផ្គង់និស្សិតបញ្ចប់ថ្នាក់បរិញ្ញាបត្រ ២២០.០០០នាក់ តែទីផ្សារការងាររំពឹងថានឹងអាចស្រូបយកត្រឹមតែ ៨៦.០០០នាក់ ប៉ុណ្ណោះ។ តួលេខទាំងនេះ បង្ហាញពីភាពមិនស៊ីគ្នាខ្លាំងរវាងតម្រូវការ និងការផ្គត់ផ្គង់និស្សិតបញ្ចប់ការសិក្សាពីមហាវិទ្យាល័យ ដោយមាននិស្សិតរាប់ម៉ឺននាក់ មិនអាចរកការងារសក្តិសមនឹងកម្រិតអប់រំរបស់ខ្លួនបាន។ ការគន់គូរសម្រាប់រយៈពេល៦ឆ្នាំនេះ បង្ហាញថា មុខវិជ្ជាសិក្សាដែលមានការផ្គត់ផ្គង់លើសតម្រូវការ រួមមាន មុខវិជ្ជាការគ្រប់គ្រងនិងអាជីវកម្ម ភាសាបរទេស បច្ចេកវិទ្យាព័ត៌មាន គណនេយ្យ ធនាគារ ហិរញ្ញវត្ថុនិងសេដ្ឋកិច្ច សង្គមវិទ្យា មនុស្សសាស្ត្រនិងសិល្បៈ ច្បាប់ ទេសចរណ៍ កសិកម្មនិងអភិវឌ្ឍន៍ជនបទ និងវិទ្យាសាស្ត្រផ្សេងទៀត ចំណែកឯមុខវិជ្ជាដែលមានការផ្គត់ផ្គង់មិនគ្រប់គ្រាន់វិញ រួមមាន វិស្វកម្ម វិទ្យាសាស្ត្រថែទាំសុខភាព និងផ្នែកទីផ្សារ (HRINC, 2010)។

ស្របតាមតម្រូវការទីផ្សារការងារ។ វិទ្យាស្ថានអន្តរជាតិសម្រាប់ធ្វើផែនការអប់រំ (IIEP 2011) ក៏បានព្រមានថា "ភាពគ្មានការងារធ្វើក្នុងចំណោមយុវជន នឹងបន្តរួមចំណែកបង្កភាពផុយស្រួយ និងការរីកវក្នុងសង្គមកម្ពុជា ប្រសិនបើឱកាសការងារ មិនអាចកើនទាន់តម្រូវការ[៧]... និស្សិត (អ្នកគ្មានការងារធ្វើ) ងាយធ្លាក់ចូលក្នុងស្ថានភាពគ្មានសិទ្ធិអំណាច ហើយអាចប្រព្រឹត្តអំពើហិង្សា បទឧក្រិដ្ឋ និងឥរិយាបថប្រកបដោយគ្រោះថ្នាក់ផ្សេងទៀត" (IIEP, 2011, p. 33)។ ហានិភ័យនៃភាពគ្មានការងារធ្វើក្នុងចំណោមយុវជន គឺមានកម្រិតខ្ពស់។

## ៣.៣ តើសហគមន៍សេដ្ឋកិច្ចអាស៊ានឆ្នាំ២០១៥ មានពាក់ព័ន្ធដូចម្តេចជាមួយប្រព័ន្ធអប់រំថ្នាក់ឧត្តមសិក្សានៅកម្ពុជានាបច្ចុប្បន្ន?

សហគមន៍សេដ្ឋកិច្ចអាស៊ាន (AEC) ជាគោលដៅឆ្នាំ២០១៥ នៃសមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់។ តាមផែនការសហគមន៍សេដ្ឋកិច្ចអាស៊ាន មូលដ្ឋានផលិតកម្ម និងទីផ្សារអាស៊ានរួមតែមួយ នឹងត្រូវកសាងឡើងលើគ្រឹះប្រាំ៖ ១) លំហូរទំនិញដោយសេរី ២) លំហូរសេវាកម្មដោយសេរី ៣) លំហូរវិនិយោគដោយសេរី ៤) លំហូរមូលធនសេរីជាងមុន និង ៥) លំហូរពលករជំនាញដោយសេរី (ASEAN, 2008, p. 6)។ លទ្ធផលពីសម្ភាសន៍ជាមួយអ្នកពាក់ព័ន្ធនានា បង្ហាញថា កម្ពុជាទទួលបានទាំងឱកាស និងបញ្ហាប្រឈម ពីសមាហរណកម្មទៅក្នុង AEC ឆ្នាំ២០១៥ នេះ។

AEC ឆ្នាំ២០១៥ ជាកត្តាខាងក្រៅចម្បងមួយជួយជំរុញកំណែទម្រង់ផ្ទៃក្នុងនៅក្នុងប្រព័ន្ធអប់រំកម្ពុជា ដើម្បីកុំឲ្យដើរក្រោយប្រទេសដទៃទៀតក្នុងការផ្គត់ផ្គង់កម្លាំងពលកម្មជំនាញ ទៅឲ្យលំហូរពលករជំនាញដោយសេរីនេះ។ វាជាការដាស់ស្មារតីកុំឲ្យ HEIs និងក្រសួងមេរបស់ពួកគេ ផ្តោតតែលើការពង្រីកបរិមាណ ប៉ុន្តែត្រូវគិតពីការពង្រឹងគុណភាព និងភាពជាប់ទាក់ទងល្អនៃការអប់រំដែលផ្តល់ឲ្យផងដែរ។ ទន្ទឹមនឹងគ្នានេះ វាជាការដាក់សម្ពាធមួយ ជំរុញរដ្ឋាភិបាលឲ្យធ្វើកំណែទម្រង់ប្រព័ន្ធអប់រំថ្នាក់ឧត្តមសិក្សា ដើម្បីផ្គត់ផ្គង់កម្លាំងពលកម្មជំនាញឲ្យបានគ្រប់គ្រាន់នៅឆ្នាំ២០១៥ និងជំរុញឲ្យ HEIs ធ្វើកំណែទម្រង់ខ្លួនឯង និងដំណើរការឲ្យបានកាន់តែប្រសើរ ប្រសិនបើចង់ស្ថិតនៅក្នុងទីផ្សារប្រកួតប្រជែងនៃការផ្តល់សេវាអប់រំថ្នាក់ឧត្តមសិក្សា។

ទោះយ៉ាងណាក្តីមានអ្នកខ្លះវែកញែកថាវាយឺតពេលណាស់ហើយដែលកម្ពុជាទើបចាប់ផ្តើមលើកកម្ពស់គុណភាពការអប់រំថ្នាក់ឧត្តមសិក្សា និងកម្លាំងពលកម្មរបស់ខ្លួន។ ចំណុចទាំងពីរនេះគួរតែរៀបចំឲ្យបានល្អតាំងពីពីរបីឆ្នាំកន្លងទៅ សម្រាប់សមាហរណកម្មដែលបានគ្រោងទុក។ AEC ឆ្នាំ២០១៥ នឹងក្លាយជាបញ្ហាប្រឈមសម្រាប់រដ្ឋាភិបាល និងប្រព័ន្ធអប់រំថ្នាក់ឧត្តមសិក្សារបស់កម្ពុជា ជាពិសេសចំពោះ HEIs ដែលមានដំណើរការអន់ខ្សោយ។ លំហូរដោយសេរីនៃពលករមានជំនាញដែលជាលទ្ធផលនៃ AEC នឹងបើកទ្វារទទួលជំនាញការមកពីប្រទេសដទៃទៀតក្នុងតំបន់ ឲ្យមកធ្វើការនៅកម្ពុជា ដែលនឹងបង្កើនអត្រាគ្មានការងារធ្វើក្នុងចំណោមនិស្សិតកម្ពុជាក្រោយបញ្ចប់ការសិក្សា។ ពិតហើយ និស្សិតកម្ពុជាក៏ទទួលបានឱកាសស្វែងរកការងារនៅក្នុងប្រទេសអាស៊ានឯទៀតដែរ ប៉ុន្តែលទ្ធភាពនេះហាក់មានតិចតួច ព្រោះជាច្រើននាក់មិនមានជំនាញបច្ចេកទេស និងគុណសម្បត្តិផ្ទាល់ខ្លួនសម្រាប់ប្រកួតប្រជែងយកការងារទាំងនោះឡើយ។

---

[៧] តាមការប៉ាន់ស្មាន ជារៀងរាល់ឆ្នាំ មានអ្នកចំណូលថ្មីប្រហែល ៣០០.០០០នាក់ ទៅក្នុងកម្លាំងពលកម្ម ប៉ុន្តែសេដ្ឋកិច្ចកម្ពុជា អាចបង្កើតការងារថ្មីបានប្រហែលតែ ១៥០.០០០កន្លែងប៉ុណ្ណោះ (MoLVT, 2008; World Bank, 2012)។

### ៣.៤ សេចក្តីសន្និដ្ឋាន

ប្រព័ន្ធអប់រំថ្នាក់ឧត្តមសិក្សានៅកម្ពុជានាបច្ចុប្បន្ន ស្ថិតក្នុងលក្ខណៈ មានរដ្ឋអំណាចជាច្រើនស្ថាប័នប្រជែងគ្នាគ្រប់គ្រង មានបរិយាកាសផ្នែកទីផ្សារច្របូកច្របល់និងមានការត្រួតពិនិត្យតិចតួច និងជាសហគមន៍សិក្សាដែលកាន់តែអន់ខ្សោយទៅៗ។ អវត្តមាននៃ អង្គភាពសម្របសម្រួលគោលនយោបាយអប់រំរួម ស្ថាប័នផ្តល់ការទទួលស្គាល់មានដំណើរការល្អ ប្រព័ន្ធព័ត៌មានទីផ្សារការងារល្អ និងចំណងទាក់ទងល្អរវាងសាកលវិទ្យាល័យ-វិស័យឧស្សាហកម្ម បានបង្កផលប៉ះពាល់ធ្ងន់ធ្ងរដល់ការប្រើប្រាស់ប្រកបដោយប្រសិទ្ធភាពនូវ ធនធានមានកំណត់ ដើម្បីកែលំអប្រព័ន្ធអប់រំថ្នាក់ឧត្តមសិក្សា គុណភាពនៃការត្រួតពិនិត្យនិងអនុវត្តគោលនយោបាយអប់រំ គុណភាពនិងភាពជាប់ទាក់ទងល្អនៃការអប់រំជាមួយទីផ្សារការងារ និងលទ្ធភាពមានការងារធ្វើក្រោយបញ្ចប់ការសិក្សាដែលអាចបង្កជាហានិភ័យខាងសង្គមផ្សេងៗ។ ចំណុចទាំងនេះបង្កើតជាបញ្ហាប្រឈមធំមួយចំពោះភាពប្រកួតប្រជែងទៅថ្ងៃអនាគត និងកំណើនសេដ្ឋកិច្ចនៅកម្ពុជា ជាពិសេស នៅពេលដែលកម្ពុជាធ្វើសមាហរណកម្មទៅក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ាន នៅឆ្នាំ២០១៥។

ទោះយ៉ាងណាក្តី ការចាត់វិធានការអនុវត្តបានត្រឹមត្រូវល្អនាពេលបច្ចុប្បន្ន វាប្រសើរជាងការមិនធ្វើសកម្មភាព ហើយវាអាចនឹងផ្លាស់ប្តូរគន្លងនៃការវិវត្តទៅថ្ងៃអនាគត។ កម្ពុជាត្រូវការនូវអង្គភាពជាតិមួយដែលមានសមត្ថភាពគ្រប់គ្រាន់ និងមានការទទួលស្គាល់ពេញលេញ សម្រាប់ការសម្របសម្រួល និងត្រួតពិនិត្យការអនុវត្តគោលនយោបាយអប់រំថ្នាក់ឧត្តមសិក្សាសំខាន់ៗ។ ស្ថាប័នផ្តល់ការទទួលស្គាល់គុណភាពអប់រំថ្នាក់ជាតិ ត្រូវតែមានការពង្រឹងបន្ថែម។ ម្យ៉ាងទៀត គួរមានការបង្កើតនូវគោលនយោបាយសំខាន់ៗ ដូចជា គោលនយោបាយស្តីពី ហិរញ្ញប្បទាន និងអភិបាលកិច្ចការអប់រំថ្នាក់ឧត្តមសិក្សា ដែលកាន់តែប្រសើរដើម្បីដោះស្រាយបញ្ហាប្រឈមនានានៅក្នុងប្រព័ន្ធអប់រំថ្នាក់ឧត្តមសិក្សានាពេលបច្ចុប្បន្ន។ គោលនយោបាយទាំងនេះ គួរផ្សារភ្ជាប់នឹងគោលនយោបាយផ្នែកឧស្សាហកម្មសំខាន់ៗដទៃទៀត ក៏ដូចជា គោលនយោបាយអភិវឌ្ឍន៍ជាតិផងដែរ។ ប្រព័ន្ធព័ត៌មានទីផ្សារការងារ គួររៀបចំឲ្យបានស្រេចបាច់យ៉ាងឆាប់ ហើយការលើកកម្ពស់ទំនាក់ទំនងរវាង HEI និងផ្នែកឧស្សាហកម្ម គួរតែពង្រឹង និងពង្រីកបន្ថែម។ នៅមានមុខងារបន្ទាន់និងសំខាន់ៗជាច្រើនទៀតដែលមិនទាន់បានអនុវត្តនៅឡើយ ហើយវាទាមទារនូវការប្តេជ្ញាចិត្ត និងឆន្ទៈនយោបាយដ៏មុតមាំពីសំណាក់តួអង្គចម្បងៗ ដើម្បីអនុវត្តឲ្យបាន។

## ឯកសារយោង


ASEAN (2008).*ASEAN Economic Community Blueprint*. Jakarta: ASEAN.

CAMFEBA (2008).*Youth and Employment: Bridging the Gap*. Phnom Penh: CAMFEBA.

HRINC (2010).*Higher Education and Skills for the Labour Market in Cambodia*. Phnom Penh: HRINC.

IIEP (2011).*Education and Fragility in Cambodia*. Paris: IIEP.

MoLVT (2008). *National TVET Development Plan—2008*. Phnom Penh: MoLVT.

Pak, T. (2011).*Driving High Growth and Sustainable Development for Cambodia—Opportunities and Challenges*.Statement by the Director General of Higher Education, MoEYS in the 2011 Cambodia Outlook Conference. Phnom Penh, Cambodia.

Pijano, C.V. (2012). *Quality Assurance and Accreditation – The Journey Continues*. A presentation at the International Seminar on "Governance and Financing of Higher Education", 26-27 July 2012, Phnom Penh.

RGC (2005).*Sub-decree No. 52 on the Arrangement and Operation of the Ministry of Labour and Vocational Training*. Phnom Penh: RGC.

RGC (2007).*Education Law*. Phnom Penh, Cambodia.

Sen, V. & Ros, S. (forthcoming).*Anatomy of Higher Education Governance in Cambodia*. CDRI Working Paper. Phnom Penh: CDRI.

UNDP. (2011). *Human Capital Implications of Future Economic Growth in Cambodia: Elements of a Suggested Roadmap*. Phnom Penh: UNDP.

World Bank. (2010a). *Country Summary Cambodia: Conference on Governance and Financing of Higher Education – South and East Asia*. Washington, D.C.: The World Bank.

World Bank (2010b).*Providing Skills for Equity and Growth: Preparing Cambodia's Youth for the Labour Market*. Washington, D.C.: The World Bank.

World Bank (2012).*Matching Aspirations: Skills for Implementing Cambodia's Growth Strategy*. Phnom Penh: The World Bank.

You, V. (2012).*Higher Education System and Quality Improvement: The Case of Cambodia*. A paper presented at the 2012 Asia-Pacific Quality Network Conference on Quality Assurance in Higher Education, 29 February—01 March 2012. Siem Reap, Cambodia.

-៤-

# និន្នាការនៃការចុះកិច្ចសន្យាជួលសេវា ក្នុងវិស័យសុខាភិបាលនៅប្រទេសកម្ពុជា

*ដោយ វង្ស ស្រីទូច*[១]

## ៤.១ សេចក្តីផ្តើម

ដោយពិនិត្យឃើញភាពទន់ខ្សោយក្នុងប្រព័ន្ធថែទាំសុខភាពនៅកម្ពុជា រាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រសួងសុខាភិបាល បានបន្តធ្វើកំណែទម្រង់សំខាន់ៗចាប់ពីឆ្នាំ១៩៩៦ ដល់ ២០០៨ លើផ្នែកហិរញ្ញប្បទានសម្រាប់វិស័យសុខាភិបាល ការធ្វើផែនការសុខាភិបាល និងការគ្រប់គ្រងសេវាថែទាំសុខភាព។ គំនិតផ្តួចផ្តើមទាំងនេះ សំដៅឆ្លើយតបនឹងបញ្ហា សមត្ថភាពអ្នកធ្វើការផ្នែកសុខាភិបាល ការគ្រប់គ្រងនិងផ្តល់សេវាជាលក្ខណៈដាច់ដោយដុំ ការគ្របដណ្តប់កម្រិតទាបនៅជនបទ និងអសមធម៌សម្រាប់ក្រុមប្រជាជនក្រីក្រ និងខ្វះសិទ្ធិក្នុងសង្គម ក្នុងលទ្ធភាពប្រើប្រាស់សេវាសុខភាព (Grundy *et al.,* 2009)។ កំណែទម្រង់ចាប់ផ្តើមពីដំបូងនៅឆ្នាំ១៩៩៦ តាមការបង្កើតលក្ខន្តិកៈនៃការផ្តល់ហិរញ្ញប្បទានផ្នែកសុខាភិបាល ដើម្បីធ្វើឲ្យប្រព័ន្ធបង់ថ្លៃប្រើប្រាស់សេវាមានភាពត្រឹមត្រូវពេញច្បាប់ បន្ទាប់មកទៀតមាន ការបង្កើតផែនការដែនគ្របដណ្តប់ផ្នែកសុខាភិបាល និងសេចក្តីណែនាំសម្រាប់ស្រុកប្រតិបត្តិ (OD) ដែលតាក់តែងឡើងទៅតាមគោលការណ៍នៃការធ្វើផែនការវិស័យសុខាភិបាល ដើម្បីរៀបចំសេវាកម្មឡើងវិញដោយផ្អែកលើកញ្ចប់សេវាចាំបាច់ និងការកំណត់ចំនួនអប្បបរមានៃប្រជាជនអ្នកទទួលផល។ នៅឆ្នាំ១៩៩៨ រដ្ឋាភិបាលកម្ពុជាបានធ្វើកំណែទម្រង់លើការគ្រប់គ្រងសេវាសុខភាព ដោយពង្រឹងកិច្ចសហការរវាងវិស័យឯកជន នឹងវិស័យសាធារណៈ ក្នុងការផ្តល់សេវាកម្ម តាមរយៈការណែនាំនូវគំរូកិច្ចសន្យាខាងក្រៅ (External Contracting) ដើម្បីពង្រីកប្រព័ន្ធសុខាភិបាលនៅជនបទ និងកែលំអការផ្តល់សេវាសុខភាព។

អត្ថបទនេះ ផ្អែកលើការសិក្សាឯកសារមានស្រាប់ដែលបានធ្វើឡើងសម្រាប់គម្រោងមួយរបស់ CDRI ស្តីពី "ដំណើរការផ្លាស់ប្តូរនៃការចុះកិច្ចសន្យាជួលសេវាក្នុងវិស័យសុខាភិបាលនៅកម្ពុជា"ដែលជាសមាសធាតុមួយក្នុងចំណោមសមាសធាតុទាំង៣នៃកម្មវិធីស្រាវជ្រាវមានឈ្មោះថា ReBUILD ឬ "ការស្រាវជ្រាវដើម្បីកសាងប្រព័ន្ធសុខាភិបាលទ្រទ្រង់ដល់ជនក្រីក្រក្នុងពេលកសាងប្រទេសក្រោយជម្លោះ" ដែលទទួលបានជំនួយទ្រទ្រង់ពីក្រសួងអភិវឌ្ឍន៍អន្តរជាតិអង់គ្លេស (DFID UK)។ ការប្រមូលព័ត៌មានធ្វើឡើងតាមរយៈប្រព័ន្ធអ៊ីនធឺណែត ក្នុងកម្មវិធី Hinari និង Google Scholar។ឯកសារផ្សេងៗក៏ទទួលបានផងដែរពីបណ្ណាល័យនៃវិទ្យាស្ថានជាតិសុខភាពសាធារណៈ (NIPH) និងមជ្ឈមណ្ឌលព័ត៌មានសាធារណៈ (PIC) នៃធនាគារពិភពលោក ដោយប្រើពាក្យគន្លឹះដូចជា contracting of health service, health sector reform, Special Operating Agency (SOA), Health Sector Support Project ជាដើម។ អត្ថបទសារព័ត៌មានបន្ថែមខ្លះទៀត ក៏បានរកឃើញនៅក្នុងបញ្ជីឯកសារយោងនៃរបាយការណ៍ផ្សេងៗ។ ប្រភពព័ត៌មានដទៃទៀត មានដូចជា

---

[១] កញ្ញា វង្ស ស្រីទូច ជាអ្នកស្រាវជ្រាវក្នុងកម្មវិធីអភិវឌ្ឍន៍សង្គម នៅវិទ្យាស្ថាន CDRI។

របាយការណ៍ដែលមិនបានបោះពុម្ពផ្សាយមួយចំនួន និងអត្ថបទបទបង្ហាញផ្សេងៗ។

អត្ថបទនេះ មានសង្ខេបពីប្រវត្តិនៃការចុះកិច្ចសន្យាជួលសេវាក្នុងវិស័យសុខាភិបាលនៅកម្ពុជា ដោយពន្យល់ពីលក្ខណៈសំខាន់ៗនៃគំរូកិច្ចសន្យាផ្សេងៗ បន្ទាប់មកមានការពិពណ៌នាពីលក្ខណៈសំខាន់ៗនៃទីភ្នាក់ងារប្រតិបត្តិការពិសេស (SOA) ដែលជាគំរូកិច្ចសន្យាតាមប្រព័ន្ធខាងក្នុង (Internal Contracting) កំពុងប្រើប្រាស់នៅកម្ពុជានាពេលបច្ចុប្បន្ន។ អត្ថបទនេះ ជាដំបូងមានរៀបរាប់ពីប្រភេទផ្សេងៗនៃកិច្ចសន្យាបានប្រើប្រាស់នៅកម្ពុជាតាំងពីឆ្នាំ១៩៩៩ ហើយបន្តរហូតដល់គំរូកំពុងប្រើការនាបច្ចុប្បន្ន ដែលមានឈ្មោះថា SOA។ ការពិភាក្សា និងសេចក្តីសន្និដ្ឋានមានចុះនៅផ្នែកខាងក្រោយនៃអត្ថបទ។

## ៤.២ បទពិសោធន៍ចុះកិច្ចសន្យានៅកម្ពុជា

### *៤.២.១ ដំណាក់កាលទី១ នៃការចុះកិច្ចសន្យា៖ ដំណាក់កាលសាកល្បង (១៩៩៩-២០០២)*

ការចុះកិច្ចសន្យា បានអនុវត្តសាកល្បង និងពង្រីកថែមនៅកម្ពុជា តាំងពីចុងទសវត្សរ៍១៩៩០ ដើម្បីបង្កើនល្បឿនងើបឡើងវិញនៃប្រព័ន្ធសុខាភិបាលជនបទ និងកែលំអការផ្តល់សេវាសុខភាព។ ចាប់ពីឆ្នាំ១៩៩៩ មក ការចុះកិច្ចសន្យាខាងក្រៅ ដែលជាផ្នែកមួយនៃកម្មវិធីទ្រទ្រង់វិស័យសុខាភិបាល ផ្តល់មូលនិធិដោយ ADB/DFID ត្រូវបានណែនាំឲ្យអនុវត្តក្នុង ៥ស្រុកប្រតិបត្តិ[២] នៅកម្ពុជា (Khim & Annear 2011)។ ដំណាក់កាលនេះ គេក៏ហៅដែរថាជា កិច្ចសន្យារវាងក្រសួងសុខាភិបាល (MoH) នឹងអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ (INGOs) សម្រាប់គ្រប់គ្រងការផ្តល់សេវា ដោយមានកម្រិតស្វ័យភាពខុសៗគ្នា។ អ្នកចុះកិច្ចសន្យា ទទួលខុសត្រូវលើការផ្តល់កញ្ចប់សកម្មភាពអប្បបរមា(MPA)ពោលគឺសេវាថែទាំសុខភាពមួយសំណុំដែលគ្រប់មណ្ឌលសុខភាពតាមស្រុកនៅកម្ពុជា ត្រូវផ្តល់ឲ្យបាន (Bhushan *et al.*, 2007)។ កិច្ចសន្យា មានកំណត់នូវគោលដៅច្បាស់លាស់សម្រាប់សូចនាករសេវាសុខភាពចំនួន៨ ជាប់ទាក់ទងនឹងសុខភាពមាតានិងទារក ដូចជា ការចាក់ថ្នាំការពារជំងឺឲ្យកុមារ ការផ្តល់វីតាមីន A ដល់កុមារ ការថែទាំគភ៌សម្រាប់ស្ត្រីមានផ្ទៃពោះ ការបង្កើតកូនដោយអ្នកវិជ្ជាជីវៈមានការបណ្តុះបណ្តាលត្រឹមត្រូវ ការសម្រាលកូននៅមណ្ឌលសុខភាព ការយល់ដឹងនិងប្រើប្រាស់វិធីសាស្ត្រពន្យារកំណើត និងការប្រើប្រាស់មណ្ឌលសុខភាពសាធារណៈនៅពេលត្រូវការសេវាថែទាំសុខភាព (Bhushan *et al.,* 2007)។ ការចុះកិច្ចសន្យាខាងក្រៅ ដែលគេបានអនុវត្តសាកល្បងក្នុងដំណាក់កាលនេះ មាន ២ទម្រង់ខុសគ្នា គឺ កិច្ចសន្យាជួលសេវាសុខាភិបាលជាមួយភ្នាក់ងារខាងក្រៅ (CO) និង កិច្ចសន្យាជួលសេវាគ្រប់គ្រងលើអង្គភាពសុខាភិបាលខាងក្នុង (CI) ដោយមានការប្រៀបធៀបទៅនឹងស្រុកប្រតិបត្តិគ្រប់គ្រងដោយប្រព័ន្ធសុខាភិបាលរបស់រដ្ឋ (Control OD)។

ភាពខុសគ្នារវាងទម្រង់ទាំងពីរនៃកិច្ចសន្យាជួលសេវាសុខាភិបាល គឺកម្រិតស្វ័យភាពផ្តល់

---

[២] ផែនការដើម គឺជ្រើសរើស ៥ស្រុកប្រតិបត្តិ សម្រាប់ការចុះកិច្ចសន្យា CO, ៥ស្រុកប្រតិបត្តិសម្រាប់ការចុះកិច្ចសន្យា CI និង ៥ស្រុកប្រតិបត្តិទៀត សម្រាប់ប្រើជាស្រុកប្រតិបត្តិគ្រប់គ្រងដោយប្រព័ន្ធសុខាភិបាលរបស់រដ្ឋ (control OD) ដើម្បីធ្វើការត្រួតពិនិត្យ។ ប៉ុន្តែបន្ទាប់ពីការវាយតម្លៃ មានតែ ១២ស្រុកប្រតិបត្តិប៉ុណ្ណោះ ដែលសក្តិសមសម្រាប់ការសាកល្បង នៅដំណាក់កាលទី១។ ចំនួនស្រុកប្រតិបត្តិ ត្រូវបានកាត់បន្ថយថែមទៀត ដោយសារខ្វះអ្នកចូលរួមដេញថ្លៃ (ADB, 2004)។

ទៅឲ្យអ្នកចុះកិច្ចសន្យា។ នៅក្នុង CO មានកញ្ចប់សេវាកម្មមួយ ត្រូវបានផ្តល់ទៅឲ្យអង្គភាពខាងក្រៅគ្រប់គ្រង។ ក្នុងគំរូនេះ អ្នកចុះកិច្ចសន្យា មានស្វ័យភាព និងការទទួលខុសត្រូវពេញលេញ លើការគ្រប់គ្រង និងការរៀបចំសេវា។ សម្រាប់ការចុះកិច្ចសន្យាជួលសេវានេះ អ្នកចុះកិច្ចសន្យា មានការទទួលខុសត្រូវពេញលេញលើការផ្តល់សេវាជាក់លាក់មួយចំនួននៅក្នុងស្រុក ជួលប្រើបុគ្គលិករបស់ខ្លួនដោយផ្ទាល់ និងមានការគ្រប់គ្រងពេញលេញលើស្រុកប្រតិបត្តិ (Schwart & Bhushan 2005; Bhushan *et al.,* 2007)។ CI ជាទម្រង់កិច្ចសន្យាមួយ ដែលតាមនោះ អង្គភាពស្របច្បាប់មួយត្រូវបានដាក់តាមរយៈការចុះកិច្ចសន្យា ឲ្យចូលគ្រប់គ្រងអង្គភាពសេវាសុខភាពមួយ នៅក្នុងប្រព័ន្ធសុខាភិបាលធំទូលាយ ដែលជាអង្គការចាត់តាំងផ្តល់សេវាសុខភាព។ ក្នុងការចុះកិច្ចសន្យាជួលសេវានេះ អ្នកចុះកិច្ចសន្យា ផ្តល់តែការគាំទ្រផ្នែកគ្រប់គ្រងប៉ុណ្ណោះ ទៅឲ្យបុគ្គលិកសុខាភិបាលរបស់រដ្ឋ ហើយថវិកាចំណាយជាប្រចាំត្រូវបានផ្តល់ឲ្យតាមរយៈបណ្តាញរដ្ឋាភិបាលដែលមានស្រាប់។

### ៤.២.២ ដំណាក់កាលទី២ នៃការចុះកិច្ចសន្យា

ដំណាក់កាលបន្ទាប់នៃការចុះកិច្ចសន្យា ត្រូវបានដាក់បញ្ចូលនៅក្នុងគម្រោងទ្រទ្រង់វិស័យសុខាភិបាល (HSSP) ឆ្នាំ២០០៤-២០០៨ ក្រោមទិសដៅគោលនយោបាយដែលមានចែងក្នុងផែនការយុទ្ធសាស្ត្រសុខាភិបាល ឆ្នាំ២០០៣-២០០៧។ ក្នុងដំណាក់កាលនេះ ការចុះកិច្ចសន្យា មានលក្ខណៈសម្គាល់ពិសេសមួយ គឺការគួបផ្សំគ្នានូវប្រភេទកិច្ចសន្យា CI និង កិច្ចសន្យាតាមប្រព័ន្ធខាងក្នុង (Internal Contracting) ហើយជំនួយទ្រទ្រង់ក្នុងដំណាក់កាលនេះ ទទួលបានពី ធនាគារពិភពលោក (WB) មូលនិធិប្រជាជនអង្គការសហប្រជាជាតិ (UNFPA) DFID និង ADB (Bigdeli n.d.)។ ជាលទ្ធផល ១១ស្រុកប្រតិបត្តិ ត្រូវបានចុះកិច្ចសន្យាដោយ INGOs ហើយ ៥ ស្រុកប្រតិបត្តិផ្សេងទៀត ត្រូវបានចុះកិច្ចសន្យាដោយមន្ទីរសុខាភិបាលនៃខេត្តពាក់ព័ន្ធ ដោយប្រើប្រាស់គំរូកិច្ចសន្យាផ្អែកលើលទ្ធផល។ គំរូកិច្ចសន្យាក្នុងដំណាក់នេះ ជាកិច្ចសន្យាបែបកូនកាត់គឺ NGOs ចុះកិច្ចសន្យាជាមួយបុគ្គលិករបស់ MoH នៅកម្រិតគ្រប់គ្រងនិងផ្តល់សេវា ដោយដាក់អនុវត្តនូវបទបញ្ញត្តិសម្រាប់មន្ត្រីរដ្ឋាភិបាល ទៅលើបុគ្គលិក MoH ទាំងអស់ ប៉ុន្តែក៏អាចជួលបុគ្គលិកផ្សេងបានដែរ ប្រសិនបើខ្វះខាតបុគ្គលិកផ្តល់ឲ្យដោយ MoH (MoH, 2007)។ ស្រុកប្រតិបត្តិដែលបានចុះកិច្ចសន្យាខាងក្នុង ទទួលបានជំនួយទ្រទ្រង់ពី អង្គការសហប្រតិបត្តិការបច្ចេកទេសបែលហ្ស៊ិក (Belgium Technical Cooperation: BTC) និងគ្រប់គ្រងដោយអ្នកគ្រប់គ្រងស្រុកប្រតិបត្តិជាមន្ត្រីរដ្ឋាភិបាល ក្រោមការគាំទ្រពីមន្ទីរសុខាភិបាលខេត្ត។ គ្រឿងលើកទឹកចិត្តផ្អែកលើលទ្ធផល ការពិនិត្យតាមដាន និងការគ្រប់គ្រងបែបសកម្មប្រយុទ្ធលើស្រុកប្រតិបត្តិ ជាលក្ខណៈពិសេសនៃរបៀបរបបក្នុងកិច្ចសន្យានេះ (Khim & Annear, 2011)។

### ៤.២.៣ ដំណាក់កាលទី៣ នៃការចុះកិច្ចសន្យា៖ ទីភ្នាក់ងារប្រតិបត្តិការពិសេស

របៀបរបបចុះកិច្ចសន្យាបច្ចុប្បន្ន មានទម្រង់ជាការចុះកិច្ចសន្យាតាមប្រព័ន្ធខាងក្នុង (Internal Contracting) ដែលគេហៅថា ទីភ្នាក់ងារប្រតិបត្តិការពិសេស (SOA)។ SOA ផ្អែកលើគោលគំនិតនៃកំណែទម្រង់រដ្ឋបាលសាធារណៈនៅកម្ពុជា ដែលសំដៅកែលំអការផ្តល់សេវា ពង្រឹងការចំណាយនិងភាពមានការងារធ្វើ កសាងសមត្ថភាពបុគ្គលនិងស្ថាប័ន និង ជំរុញការប្រើប្រាស់បច្ចេកវិទ្យាទំនាក់ទំនងនិងព័ត៌មាន។ SOA ត្រូវបានបង្កើតឡើងដើម្បី ១) កែលំអការផ្តល់សេវាដល់អ្នកប្រើប្រាស់សេវា និងការពិគ្រោះយោបល់ជាមួយអ្នកប្រើប្រាស់សេវា ការតាមដាន ត្រួតពិនិត្យ

គុណភាពសេវា ២) លើកកម្ពស់ប្រសិទ្ធភាពចំណាយនៅក្នុងអភិក្រមនៃការផ្តល់សេវា ៣) កែប្រែផ្នត់គំនិត និងអាកប្បកិរិយាមន្ត្រី ៤) ធ្វើប្រតិភូកម្មការទទួលខុសត្រូវការងារប្រតិបត្តិការក្នុងការផ្តល់សេវាសាធារណៈ ៥) ធ្វើឲ្យបានកាន់តែប្រសើរឡើងនូវការប្រើប្រាស់បច្ចេកទេសព័ត៌មាន និង ៦) បង្ហាញនូវសកម្មភាព និងការយកចិត្តទុកដាក់របស់រដ្ឋាភិបាល ក្នុងការងារគ្រប់គ្រងឲ្យមានប្រសិទ្ធភាព (CAR, 2008)។

SOA ជាយន្តការអាចបត់បែនបាន ដើម្បីពង្រឹងការអនុវត្ត និងគណនេយ្យភាពក្នុងការផ្តល់សេវាសាធារណៈ។ SOA ត្រូវបានបង្កើតឡើងនៅក្នុងកម្មវិធីទ្រទ្រង់វិស័យសុខាភិបាល២ (HSSP2) ដោយទទួលបានជំនួយគាំទ្រពីម្ចាស់ជំនួយចម្បងៗ ៧ គឺ៖ WB, DFID, AusAID, UNFPA, UNICEF, ទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍ (AFD) និង BTC។ យោងតាមក្រសួងសុខាភិបាល SOAs ជាអង្គភាពថ្មីក្នុងវិស័យសុខាភិបាល។ SOAs ជាផ្នែកមួយនៃក្រសួងសុខាភិបាល ប៉ុន្តែនៅក្នុងអាណត្តិដែលបានឯកភាពគ្នានោះ គឺមានស្វ័យភាពផ្នែកប្រតិបត្តិការលើការផ្តល់សេវាក្រោមកិច្ចសន្យាជាមួយក្រសួង" (MoH, 2009)។ ជាទូទៅ SOA ជាអង្គភាពរដ្ឋាភិបាលមួយដំណើរការដោយមន្ត្រីរដ្ឋាភិបាល និងទទួលហិរញ្ញប្បទានតាមរយៈមធ្យោបាយផ្សេងៗ ដូចជា ថវិការដ្ឋាភិបាល ជំនួយឥតសំណងសម្រាប់ការផ្តល់សេវាក្នុងកម្មវិធី HSSP2 ថ្លៃសេវាបង់ដោយអ្នកប្រើប្រាស់ មូលនិធិសមធម៌សុខភាព (HEF) និង ថវិកាទ្រទ្រង់ពីម្ចាស់ជំនួយផ្ទាល់ ទៅដល់កន្លែងផ្តល់សេវា។ SOA ជាស្ថាប័នផ្តល់សេវាសាធារណៈ ដែលបានកែសម្រួលឲ្យទៅជាអង្គភាពពាក់កណ្តាលស្វយ័តមានសិទ្ធិអំណាចគ្រប់គ្រងធំជាងមុន។ អង្គភាពនេះ ត្រូវបានបង្កើតជាផ្លូវការដោយអនុក្រឹត្យលេខ៦៩ ក្នុងឆ្នាំ ២០០៨ និងមានគោលដៅដូចតទៅ៖

១. កែលំអគុណភាព និងផ្តល់សេវាសាធារណៈនៅតាមទីកន្លែង និងពេលវេលាដែលមានតម្រូវការ
២. កែប្រែផ្នត់គំនិត និងអាកប្បកិរិយាមន្ត្រីស្របតាមលក្ខណសម្បត្តិរបស់រដ្ឋបាលសាធារណៈ គឺមាន ឆន្ទៈម្ចាស់ការ ភក្តីភាព សីលធម៌វិជ្ជាជីវៈ និងវប្បធម៌សេវាសាធារណៈ
៣. លើកកម្ពស់ការគ្រប់គ្រងផ្អែកលើលទ្ធផលការងារ ដោយភាពប្រុងប្រយ័ត្ន មានប្រសិទ្ធភាព និងមានតម្លាភាព
៤. អភិវឌ្ឍសមត្ថភាពក្នុងការផ្តល់សេវាសាធារណៈ

ការអនុវត្តការងាររបស់ SOA មានពាក់ព័ន្ធនឹងតួអង្គជាច្រើន ដូចជា ក្រសួងសុខាភិបាល ឬតំណាងក្រសួង ប្រធានមន្ទីរសុខាភិបាលខេត្ត ការិយាល័យស្រុកប្រតិបត្តិ និងបុគ្គលិកនៅកន្លែងផ្តល់សេវាសុខភាពដែលស្ថិតក្រោម SOA ក៏ដូចជា មន្ទីរពេទ្យបង្អែក មណ្ឌលសុខភាព និងប៉ុស្តិ៍សុខភាព។ ស្របតាមវិធីសាស្ត្រមានការចូលរួម ក្រុមការងារទ្រទ្រង់សុខភាពតាមភូមិ (VHSG) តំណាងឲ្យសហគមន៍ និងក្រុមអ្នកប្រើប្រាស់សេវាសុខភាព ក្នុងការចូលរួមកិច្ចប្រជុំរបស់គណៈកម្មាធិការគ្រប់គ្រងមណ្ឌលសុខភាព (HCMC) ដែលជាកន្លែងអាចធ្វើការពិភាក្សាពីមតិ និងយោបល់ត្រឡប់ផ្សេងៗ លើសេវាថែទាំសុខភាព (Khim & Annear 2011)។

## ៤.៣ ការពិភាក្សា

ប្រភេទនៃការចុះកិច្ចសន្យាជួលសេវានៅក្នុងវិស័យសុខាភិបាលនៅប្រទេសកម្ពុជា បានរីកលូតលាស់ពេញលេញហើយ។ ដោយចាប់ផ្តើមពី ៥ស្រុកប្រតិបត្តិសាកល្បង រួចពង្រីកដល់ ១១ស្រុក នៅក្នុងដំណាក់កាលដំបូង នាបច្ចុប្បន្ននេះ នៅប្រទេសកម្ពុជាមានរហូតដល់ ៣០ SOAs ដែលកំពុងអនុវត្តតាមទម្រង់កិច្ចសន្យាខាងក្នុង។ អត្ថប្រយោជន៍នៃការចុះកិច្ចសន្យានៅកម្ពុជា មានបង្ហាញនៅក្នុងការសិក្សា និងរបាយការណ៍វាយតម្លៃមួយចំនួន។ លទ្ធផលនៃការសិក្សាទាំងនោះបង្ហាញថា ការចុះកិច្ចសន្យាផ្តល់សេវាសុខភាពជាមួយអង្គភាពមិនមែនរដ្ឋាភិបាល គឺអាចអនុវត្តទៅបាន មានសមធម៌និងប្រសិទ្ធភាពខាងការចំណាយ ព្រមទាំងផ្តោតចំល្អនិងផ្តល់អត្ថប្រយោជន៍ដល់ជនក្រីក្រ។ ប្រភេទនៃការចុះកិច្ចសន្យានេះ បានពង្រីកសេវាកម្មយ៉ាងលឿនទៅដល់ប្រជាជនកាន់តែច្រើន និងបានកាត់បន្ថយអត្រាមរណៈមាតា ទារក និងកុមារ។ ដោយមានចំណាយជាប្រចាំធំជាងជិតពីរដង គំរូការចុះកិច្ចសន្យាខាងក្រៅ បានផ្តល់លទ្ធផលប្រសើរជាង គំរូការចុះកិច្ចសន្យាខាងក្នុង និងស្រុកប្រតិបត្តិគ្រប់គ្រងដោយប្រព័ន្ធសុខាភិបាលរបស់រដ្ឋ។ ទោះជាការវាយតម្លៃពីដំណាក់កាលទី១ នៃការចុះកិច្ចសន្យា បង្ហាញនូវលទ្ធផលដូចគ្នាក៏ដោយ ក៏នៅមានការចោទសំណួរពីសមធម៌នៃការទទួលសេវាក្នុងចំណោមប្រជាជនក្នុងក្រុមក្រីក្របំផុតដែរ។ ការសិក្សាមួយបានរកឃើញថាទោះបីជាការប្រើប្រាស់សេវាសុខភាពសាធារណៈបានកើនឡើងក្តីក៏មិនមានកំណត់ត្រាអ្វីច្បាស់លាស់ពី ការប្រើប្រាស់សេវាទាំងនោះដោយក្រុមប្រជាជនក្រីក្របំផុតឡើយ (MoH, 2007)។ ការប្រើប្រាស់សេវាកម្មដោយប្រជាជនក្រីក្របំផុត ក៏អាចកើតមានដោយសារការដាក់ប្រើប្រាស់នូវមូលនិធិសមធម៌សុខភាព (HEF) ដែលបានលើកលែងជនក្រីក្រក្នុងការបង់ថ្លៃសេវាកម្ម នៅតាមកន្លែងផ្តល់សេវាសុខភាពសាធារណៈ។

ដំណាក់កាលទី២ នៃការចុះកិច្ចសន្យា បង្ហាញពីការរីកចម្រើនគួរកត់សម្គាល់ក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងកំណើនលទ្ធភាពទទួលបាន និងការប្រើប្រាស់សេវាសុខភាពសាធារណៈ ទាក់ទងនឹងសុខភាពមាតានិងទារក មានជាអាទិ ការចាក់ថ្នាំបង្ការឲ្យកុមារ និង ការថែទាំសុខភាពពេលមានផ្ទៃពោះ (MoH, 2007)។ លទ្ធផលសំខាន់ជាងគេនៃការចុះកិច្ចសន្យានេះ គឺការស្តារទំនុកចិត្ត និងការជឿជាក់លើសេវាសុខភាពសាធារណៈ (MoH, 2007)។ ភស្តុតាងនេះបង្ហាញថា អត្រាប្រើប្រាស់សេវាសុខភាពសម្រាប់អ្នកជម្ងឺមិនសម្រាកពេទ្យ និងសម្រាប់អ្នកជំងឺសម្រាកពេទ្យ បានកើនឡើងនៅគ្រប់កន្លែងដែលមានការចុះកិច្ចសន្យាផ្តល់សេវាសុខភាព (MoH, 2007)។ លទ្ធផលនៅដំណាក់កាលនេះបង្ហាញថា នៅពេលមានការផ្សារភ្ជាប់គ្រឿងលើកទឹកចិត្តទៅនឹងលទ្ធផលសម្រេចបាន លទ្ធផលការងាររបស់អ្នកផ្តល់សេវាបានកើនឡើង ហើយសេវាថែទាំសុខភាពមាតា និងទារក ក៏កាន់តែប្រសើរឡើងដែរ (Keller et al., 2008)។

ការចុះកិច្ចសន្យានៅកម្ពុជា គេមើលឃើញថា ជាយន្តការមួយសម្រាប់លើកកម្ពស់ការផ្តល់សេវាសាធារណៈ ជាពិសេសនៅពេលដែលរដ្ឋមិនមានលទ្ធភាពរ៉ាប់រងបន្ទុកចំណាយលើការផ្តល់សេវា ដើម្បីបំពេញតាមតម្រូវការរបស់អ្នកប្រើប្រាស់ និងលើការកែលំអប្រសិទ្ធភាពការងារ និងគុណភាពសេវា ដើម្បីកសាងទំនុកចិត្តរបស់សាធារណជនចំពោះប្រព័ន្ធសុខាភិបាល។ បទពិសោធន៍នៃការចុះកិច្ចសន្យាខាងក្រៅក្នុងដំណាក់កាលទី១ និងការចុះកិច្ចសន្យានៅដំណាក់កាលទី២ បង្ហាញថា ការចុះកិច្ចសន្យាអាចពង្រឹងគុណភាពសេវាកម្ម ពង្រីកដែនគ្របដណ្តប់សេវាកម្ម កាត់បន្ថយការចំណាយចេញពីហោប៉ៅរបស់អ្នកប្រើសេវា និងការផ្តល់សេវាកាន់តែមានសមធម៌សម្រាប់

សហគមន៍។ ប៉ុន្តែក្នុងនេះ ចំណាយប្រតិបត្តិការវាមានកម្រិតខ្ពស់ជាង បើធៀបនឹង ODs ធម្មតាៗ ដែលដំណើរការដោយរដ្ឋាភិបាល។

មកទល់ពេលនេះ មានការសិក្សាតិចតួចនៅឡើយអំពី ដំណើរផ្លាស់ប្តូរនៃការចុះកិច្ចសន្យា និងមូលហេតុនៃការផ្លាស់ប្តូរពីប្រភេទកិច្ចសន្យាមួយទៅកិច្ចសន្យាមួយទៀត។ ទោះជាយ៉ាងនេះក្តី ការសិក្សាទាំងនោះ បានគូសបញ្ជាក់ពីសមាសធាតុគន្លឹះខ្លះៗ ដូចជា ចំណាយខ្ពស់ក្នុងការអនុវត្តការចុះកិច្ចសន្យា បរាជ័យក្នុងការផ្ទេរចំណេះដឹង និងជំនាញ និងភាពជាម្ចាស់ការដែលអាចបង្អាក់ទឹកចិត្តក្នុងការបន្តអនុវត្តការចុះកិច្ចសន្យា ហើយផ្លាស់ប្តូរមកប្រើគំរូ SOA វិញ។ ដោយសារចំណាយប្រតិបត្តិការរបស់ ODs ដែលបានចុះកិច្ចសន្យា វាធំជិតស្មើពីរដងនៃចំណាយរបស់ ODs ដំណើរការដោយរដ្ឋាភិបាលនោះ ក្រសួងសុខាភិបាលគិតថា ការវិនិយោគទុនច្រើនៗទៅលើការអនុវត្តចុះកិច្ចសន្យា មិនមែនជាយុទ្ធសាស្រ្តមានចីរភាពទេ នៅក្នុងស្ថានភាពថវិកាផ្នែកសុខាភិបាលមានកម្រិតដូចសព្វថ្ងៃ និងការពឹងផ្អែករបស់ប្រទេសកម្ពុជាទៅលើមូលនិធិបានពីម្ចាស់ជំនួយ (Kim & Annear 2011:51)។ ទី២ បញ្ហាកង្វះការចូលរួម និង ការចែកចាយព័ត៌មានរវាងអ្នកចុះកិច្ចសន្យាខាងក្រៅ និងបុគ្គលិក OD បានធ្វើឲ្យបរាជ័យដល់ការផ្ទេរចំណេះដឹង និងជំនាញក្នុងចំណោមបុគ្គលិក។ ហេតុនេះ មានការពិចារណាថា ការផ្ទេរចំណេះដឹងនិងជំនាញ អាចមានប្រសិទ្ធភាពជាងនេះ ប្រសិនបើបុគ្គលិករដ្ឋាភិបាលនៅកម្រិតស្រុក ចូលរួមយ៉ាងសកម្មក្នុងការងារដែលផ្តល់ដោយអ្នកចុះកិច្ចសន្យាខាងក្រៅ។ ម្យ៉ាងទៀត នៅក្នុងក្រសួងសុខាភិបាល ក៏មានផុសមតិដែលឆ្លុះបញ្ចាំងពីការរំពឹងទុករបស់សាធារណជនថា ក្រសួងសុខាភិបាលមានទំនួលខុសត្រូវក្នុងការគ្រប់គ្រង ថែទាំ និងផ្តល់សេវា នៅក្នុងប្រព័ន្ធសុខាភិបាល។ បន្ថែមលើនេះទៀត គេមិនច្បាស់ទេថា តើអ្នកចុះកិច្ចសន្យាបានចូលរួមល្អឬទេក្នុងដំណើរការធ្វើផែនការ និងការបង្កើតផែនការប្រតិបត្តិការប្រចាំឆ្នាំ (AoP)។ ផ្ទុយទៅវិញ អ្នកចុះកិច្ចសន្យាហាក់បានព្យាយាមដាក់ចូលជំនួសវិញនូវគោលដៅ និងអាទិភាពនានារបស់ពួកគេ ដើម្បីសម្រេចនូវគោលដៅរបស់ជាតិ។ ម្យ៉ាងទៀតក៏មានការព្រួយបារម្ភដែរចំពោះយុទ្ធសាស្រ្តចាកចេញរបស់អ្នកចុះកិច្ចសន្យា ដើម្បីប្រគល់នីតិវិធីនានាទៅឲ្យប្រព័ន្ធគ្រប់គ្រងបច្ចុប្បន្ននៃ MoH វិញ នៅពេលគម្រោងចុះកិច្ចសន្យាត្រូវចប់នៅឆ្នាំ២០០៧។

បទពិសោធន៍ចុះកិច្ចសន្យានៅកម្ពុជា និងការសិក្សាផ្សេងៗទៀតបង្ហាញថា លទ្ធផលវិជ្ជមានអាចពិនិត្យឃើញមែន ក្នុងការកែលំអសេវាសុខភាពសាធារណៈ តាមរយៈការអនុវត្តរបៀបរបបចុះកិច្ចសន្យា។ ទោះយ៉ាងនេះក្តី អ្នកនិពន្ធមួយចំនួនបានរំលឹកថា ការចុះកិច្ចសន្យាមិនមែនជាឱសថទិព្វនោះទេ ព្រោះមានបញ្ហាប្រឈម និងគុណវិបត្តិជាច្រើនក្នុងការដាក់អនុវត្ត (Ashton 1998) ដែលទាមទារនូវសមត្ថភាពខ្ពស់ក្នុងការធ្វើផែនការ រៀបចំ គ្រប់គ្រង និងពិនិត្យតាមដានកិច្ចសន្យា ហើយចំណាយក៏កើនឡើងក្នុងការគ្រប់គ្រង និងពិនិត្យតាមដានកិច្ចសន្យា ដែលអាចប៉ះពាល់ដល់សេវាកម្មផ្សេងទៀតក្រៅពីកិច្ចសន្យា (Mills & Broomberg, 1998, Eldridge & Palmer, 2009)។ ការសិក្សាមួយទៀតបានរៀបរាប់ដោយសង្ខេបនូវ បញ្ហានានានៃការអនុម័តយករបៀបរបបចុះកិច្ចសន្យាមកអនុវត្ត គឺមាន ចំណាយប្រតិបត្តិការខ្ពស់ ដែលអាចច្រើនជាងផលចំណេញទទួលបានពីការចុះកិច្ចសន្យា, សមត្ថភាពទាបក្នុងការគ្រប់គ្រងកិច្ចសន្យា អាចរារាំងមិនឲ្យទទួលបានផលចំណេញច្រើនគ្រប់គ្រាន់ពីការចុះកិច្ចសន្យា, ក្នុងករណីអ្នកដេញថ្លៃមានតិចនាក់ កិច្ចសន្យាអាចចុះហត្ថលេខាជាមួយអ្នកផ្តល់សេវាដែលអន់ខ្សោយ ធ្វើឲ្យសេវាផ្គត់ផ្គង់មានគុណភាពទាប, តម្រូវការទទួលបានព័ត៌មានច្បាស់លាស់ និងគ្រប់គ្រាន់ដើម្បីចៀសវាងការប៉ាន់ស្មានថ្លៃដើមខ្ពស់ពេក ហើយបង់ថ្លៃច្រើនពេកទៅឲ្យអ្នកផ្គត់ផ្គង់សេវា នៅពេលកំណត់ថ្លៃក្នុង

កិច្ចសន្យា, ការពិនិត្យតាមដាន និងវាយតម្លៃដែលអាចជួយពង្រឹងការអនុវត្តកិច្ចសន្យា ត្រូវការនូវសមត្ថភាពជំនាញច្បាស់លាស់ ដែលអាចមានតម្លៃខ្ពស់ (Khim & Annear, 2011)។

នៅកម្ពុជា ការចុះកិច្ចសន្យា ជាវិធីពេញនិយមក្នុងចំណោមអ្នកផ្តល់ជំនួយ និងអ្នកផ្គត់ផ្គង់សេវាសុខភាព។ តាមរយៈការចុះកិច្ចសន្យាផ្អែកលើលទ្ធផល អ្នកផ្គត់ផ្គង់សាធារណៈអាចទទួលបានគ្រឿងលើកទឹកចិត្តបន្ថែម ដើម្បីពង្រឹងការអនុវត្ត និងកែលំអគុណភាពសេវា។ នៅកម្ពុជា ការចុះកិច្ចសន្យាមានការវិវត្តស្មុគស្មាញ។បទពិសោធន៍ចុះកិច្ចសន្យានៅកម្ពុជា បង្ហាញពីឥទ្ធិពលវិជ្ជមានទៅលើសេវាសុខភាពនៅតាមកន្លែងព្យាបាលសាធារណៈ។ ទោះយ៉ាងនេះក្តី ការប្រើប្រាស់គំរូកិច្ចសន្យាខាងក្រៅ ដូចជា ការចុះកិច្ចសន្យាជាមួយ INGOs ឬការចុះកិច្ចសន្យាផ្អែកលើលទ្ធផលជាមួយបុគ្គលជាបុគ្គលិកសំខាន់ក្នុងការផ្តល់សេវានៅតាមកន្លែងសាធារណៈ អាចធ្វើឲ្យអ្នកជំនាញៗចេញទៅធ្វើជាបុគ្គលិកក្នុងវិស័យឯកជន។ ក្នុងបរិបទកម្ពុជាដែលធនធានមនុស្សខាងសុខាភិបាលមានតិចនាក់នៅឡើយ ការហូរចេញអ្នកផ្តល់សេវាសុខភាពពីវិស័យសាធារណៈ ទៅវិស័យឯកជនអាចប៉ះពាល់ខ្លាំងដល់ការផ្តល់សេវាសុខភាពជូនប្រជាជនកម្ពុជា។ ហើយចំណុចនេះអាចជាកត្តាជំរុញការផ្លាស់ប្តូរពីការចុះកិច្ចសន្យាខាងក្រៅ ទៅជាការចុះកិច្ចសន្យាខាងក្នុង តាមរយៈការបង្កើត SOA។

## ៤.៤ សេចក្តីសន្និដ្ឋាន

យោងតាមបទពិសោធន៍នៅអន្តរជាតិ និងកម្ពុជា គេយល់ថា ការចុះកិច្ចសន្យាជាវិធីមួយសម្រាប់ឲ្យរដ្ឋាភិបាលពង្រឹងគុណភាពសេវាសុខភាព តាមរយៈកិច្ចសន្យាប្រភេទផ្សេងៗ ជាពិសេស កិច្ចសន្យាមានគ្រឿងលើកទឹកចិត្តផ្អែកលើលទ្ធផល។ វិធីនេះមានប្រើប្រាស់នៅប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើន ដែលក្នុងនោះវិស័យឯកជនដើរតួនាទីយ៉ាងសំខាន់ជួយផ្តល់សេវាជូនសាធារណជន។ ក្នុងទិដ្ឋភាពនេះ កិច្ចសន្យាគឺជាឧបករណ៍មួយសម្រាប់ធ្វើឲ្យរលូនគ្នាល្អរវាងអ្នកផ្តល់សេវាក្នុងវិស័យសាធារណៈ នឹងឯកជន ដើម្បីបានអត្ថប្រយោជន៍ល្អប្រសើរដល់ប្រជាជន។ ទោះយ៉ាងនេះក្តី ជោគជ័យនៃរបៀបរបបចុះកិច្ចសន្យាផ្សេងៗ វាអាស្រ័យលើសមត្ថភាពគ្រប់គ្រងរបស់ក្រសួង និងរដ្ឋាភិបាល ជាមេកើយ។

ជាចំណែកមួយនៃកំណែទម្រង់វិស័យសុខាភិបាល ប្រទេសកម្ពុជាបានដាក់អនុវត្តចាប់ពីឆ្នាំ១៩៩៩ មក នូវគំរូចុះកិច្ចសន្យា ដែលតាំងពីពេលនោះមក បានរីកចម្រើនពេញលេញហើយ។ ការវាយតម្លៃលើវិធីចុះកិច្ចសន្យានេះពីមុនមក បានបង្ហាញថា ការចុះកិច្ចសន្យាគឺ អាចអនុវត្តបានមានប្រសិទ្ធភាពចំណាយល្អ មានសមធម៌ និងអាចផ្តោតចំលើអ្នកក្រ។ តាមរយៈវិធីសាស្ត្រ ថ្មីនេះ ការផ្តល់សេវានៅតាមកន្លែងព្យាបាលសាធារណៈបានរីកចម្រើនយ៉ាងលឿន និងទៅដល់ប្រជាជនកាន់តែច្រើនឡើង។ ដើម្បីអនុវត្តតាមបទពិសោធន៍ចុះកិច្ចសន្យានេះឲ្យបានច្រើនកន្លែង រាជរដ្ឋាភិបាលកម្ពុជា បានបង្កើតនិងដំណើរការ SOA ដើម្បីពង្រឹងគុណភាពសេវាសុខភាពសាធារណៈ។ ប៉ុន្តែដោយសារទើបអនុវត្តបានពីរបីឆ្នាំប៉ុណ្ណោះ ដំណើរការ និងលទ្ធផលរបស់វា មិនទាន់អាចវាយតម្លៃបានទេ។ ម្យ៉ាងទៀត គេបានដឹងតិចតួចណាស់ពីការវិវត្តនៃការចុះកិច្ចសន្យានៅកម្ពុជា ព្រមទាំងបែបបទនិងមូលហេតុនៃការផ្លាស់ប្តូរតាំងពីពេលដំបូង រហូតមកដល់របៀបរបបបច្ចុប្បន្ន។ មានការសិក្សាមួយចំនួនតូចបានពិភាក្សាពីផលប៉ះពាល់នៃការចុះកិច្ចសន្យាទៅលើសមធម៌។ ទោះយ៉ាងនេះក្តី គេមិនទាន់មានភស្តុតាងច្បាស់លាស់ទេថា ការចុះកិច្ចសន្យាប្រភេទផ្សេងៗ ជាពិសេស SOA វាបានជួយកែលំអសមធម៌សម្រាប់សហគមន៍ដែរឬទេ។ ដូច្នេះ ការស្រាវជ្រាវទៅអនាគត គួរពិនិ

ត្យពីដំណើរវិវត្តន៍នៃការចុះកិច្ចសន្យា និងផលប៉ះពាល់ទៅលើទំហំសេវាគ្របដណ្តប់ និងសមធម៌សម្រាប់សហគមន៍ក្រីក្រ។

## គន្ថនិទ្ទេស


Ashton, T. (1998), "Contracting for Health Services in New Zealand: A Transaction Cost Analysis", *Social Science & Medicine,* 46(3), pp. 357-367

Bhushan, I., E. Bloom, D. Clingingsmith, R. Hong, E. King, M. Kremer, B. Loevinsohn & J. Brad Schwartz (2007), "Contracting for Health: Evidence from Cambodia", http://faculty.weatherhead.case.edu/clingingsmith/cambodia13jun07.pdf (accessed 25 November 2012)

Bigdeli, M. (n.d.), "Contracting in Cambodia", PowerPoint slides, http://performancebasedfinancing.files.wordpress.com/2009/12/bigdeli.ppt (accessed 14 October 2011)

CAR–Council for Administrative Reform (2008), *Special Operating Agencies: Implementation Guide* (Phnom Penh: CAR)

Eldridge, C. & N. Palmer (2009), "Performance-based Payment: Some Reflections on the Discourse, Evidence and Unanswered Questions", *Health Policy and Planning,* 24(3), pp. 160-166

Grundy, J., Q.Y. Khut, S. Oum, P. Annear & V. Ky (2009), "Health System Strengthening in Cambodia- A Case Study of Health Policy Response to Social Transition", *Health Policy,* 92, pp. 107-115

Keller, S., J. Jong & J.M. Thomé (2008), *Assessment of Performance Contracting in Kompong Cham Province, Cambodia* (Phnom Penh: Belgium Technical Cooperation)

Khim. K. & P. Annear (2011),"The Transition to Semi-Autonomous Management of District Health Services in Cambodia: Assessing Purchasing Arrangements, Transaction Costs and Operational Efficiencies of Special Operating Agencies", in Hossein Jalilian & Vicheth Sen (eds.), *Improving Health Sector Performance: Institutions, Motivations and Incentives-The Cambodia Dialogue* (Singapore: ISEAS) pp.45-75

Mills, A., S. Bennett & S. Russell with N. Attanayake, C. Hangoro, V.R. Muralheedharan & P. Smithson (2001), *The Challenge of Health Sector Reform: What Must Governments Do?* (New York, NY: Palgrave)

Mills, A. & J. Broomberg (1998), *Experiences of Contracting Health Services: An Overview of the Literature,* Working Paper, Health Economics and Financing Programme (London: London School of Hygeine and Tropical Medicine)

MoH–Ministry of Health (2007), *Cambodia Health Services Contracting Review: Final Report* (Phnom Penh: MoH)

MoH (2009), *Special Operating Agency Manual* (Phnom Penh: Department of Planning and Health Information, MoH)

Schwartz, J.B. & I. Bhushan (2004), *Cambodia: Using Contracting to Reduce Inequity in Primary Health Care Delivery,* HNP Discussion Paper, Reaching the Poor Programme Paper No. 3 (Washington, DC: World Bank)

WHO–World Health Organisation (2008), Consultation on Strategic Contracting in Health Systems: Synthesis of the Meeting, Geneva, 9-11 January 2008 http://www.who.int/contracting/Synthesis_EN_WEB.pdf (accessed August 2012)

-៥-

# ការឡើងថ្លៃម្ហូបអាហារនៅប្រទេសកម្ពុជា៖ មូលហេតុ ផលប៉ះពាល់ និងគោលនយោបាយឆ្លើយតប

*ដោយលោក លន់ ពិដេ និង តុង គឹមស៊ុន*[១]

## ៥.១ សេចក្តីផ្តើម

នៅមុនពេលវិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាកល រាលដាលមកដល់ប្រទេសកម្ពុជាក្នុងឆ្នាំ ២០០៨ ក៏ដូចជាប្រទេសនានាទៀត គេឃើញមានការឡើងថ្លៃម្ហូបអាហារជាសន្ទុះៗ រហូតដល់ពាក់កណ្តាលឆ្នាំ២០០៨ ដែលនៅពេលនោះ វាស្ទុះឡើងដល់កម្រិតខ្ពស់បំផុត ហើយសន្ទស្សន៍ថ្លៃម្ហូបអាហារក៏បានឡើងខ្ពស់មិនធ្លាប់មានពីមុនមក។ តួយ៉ាងដូចជាក្នុងអំឡុងត្រីមាសទី២ ឆ្នាំ២០០៨ អង្ករបានឡើងថ្លៃដល់ជាង ៩០%។ ថ្លៃម្ហូបអាហារបានចាប់ផ្តើមធ្លាក់ចុះបន្តិចម្តងៗមកវិញក្នុងអំឡុងពេលដំបូងនៃវិបត្តិនេះ ប៉ុន្តែស្ទើរតែមិនទាន់ធ្លាក់ចុះដល់កម្រិតដើមវិញផង វាក៏ចាប់ផ្តើមកើនឡើងវិញតាំងពីក្នុងត្រីមាសទី២ ឆ្នាំ២០០៩ មក។ គិតត្រឹមខែឧសភា ២០១១ សន្ទស្សន៍ថ្លៃម្ហូបអាហារបានកើនប្រមាណជាង ៤% លើសពីសន្ទស្សន៍ថ្លៃម្ហូបអាហារដ៏ខ្ពស់បំផុតកាលពីខែមិថុនា ២០០៨។ និន្នាការនេះ បង្កការព្រួយបារម្ភយ៉ាងខ្លាំងពី ផលប៉ះពាល់អវិជ្ជមានទៅលើប្រជាជនក្រីក្រ។

ការសិក្សានេះប្រើប្រាស់ វិធីសាស្ត្រពិសោធន៍ ដើម្បីវាស់វែងផលប៉ះពាល់នៃការឡើងថ្លៃម្ហូបអាហារ ទៅលើជនក្រីក្រនៅកម្ពុជា និងផ្តល់ចម្លើយលើសំណួរសំខាន់ៗមួយចំនួន ដូចជា មូលហេតុនិងផលប៉ះពាល់នៃការឡើងថ្លៃម្ហូបអាហារ ហើយធ្វើការវិភាគលើគោលនយោបាយឆ្លើយតបរបស់រដ្ឋាភិបាល។ ការសិក្សាមួយចំនួន (ដូចជា Chan 2009; Tong 2009; UNICEF 2008) បានបង្ហាញពីផលប៉ះពាល់អវិជ្ជមាននៃការឡើងថ្លៃម្ហូបអាហារ ដែលរួមមាន ការខូចខាតសុខមាលភាព ការថមថយសុខភាពបណ្តាលមកពីការកាត់បន្ថយបរិមាណនិងគុណភាពម្ហូបអាហារ កំណើនអត្រាកង្វះអាហារូបត្ថម្ភក្នុងចំណោមកុមារ និងកំណើនបំណុលក្នុងគ្រួសារ។ ដូច Chan (2009) បានលើកឡើង វិបត្តិថ្លៃម្ហូបអាហារ បណ្តាលឲ្យគ្រួសារងាយធ្លាក់ខ្លួនក្រ ហើយក៏ជា កត្តារាំងស្ទះដល់ការប្រឹងប្រែងកាត់បន្ថយភាពក្រីក្រនៅកម្ពុជាផងដែរ។

វិធីសាស្ត្រដើម្បីវាស់វែងផលប៉ះពាល់នៃ ការឡើងថ្លៃម្ហូបអាហារ គឺត្រូវគណនា អនុបាតនៃផលសុទ្ធ ហើយកំណត់អត្តសញ្ញាណគ្រួសារ ថាតើជាអ្នកលក់អាហារសុទ្ធ ឬជាអ្នកទិញអាហារសុទ្ធ។ អនុបាតនៃផលសុទ្ធ គឺជា ផលដក រវាងអនុបាតនៃការចំណាយលើម្ហូបអាហារ និងអនុបាតនៃផលម្ហូបអាហារដែលគ្រួសារបានផលិតដោយខ្លួនឯង។ តាមនេះ គ្រួសារណាមួយគឺជាអ្នកលក់អាហារសុទ្ធ ប្រើសិនបើគ្រួសារនោះមានអនុបាតនៃផលសុទ្ធវិជ្ជមាន និងគឺជាអ្នកទិញអាហារសុទ្ធ ប្រសិនបើមានអនុបាតនៃផលសុទ្ធអវិជ្ជមាន។ អនុបាតនៃការចំណាយលើម្ហូបអាហារ គឺជា ផលធៀបរវាង ការចំណាយលើការទិញម្ហូបអាហារ និងការចំណាយសរុបក្នុងគ្រួសារ រីឯអនុបាតនៃផលម្ហូបអាហារផលិតដោយខ្លួនឯង គឺជា ផលធៀបរវាង ចំណូលពីការលក់និងប្រើប្រាស់ម្ហូបអាហារផលិតដោយខ្លួនឯង និងចំណូលសរុបក្នុងគ្រួសារ។ អ្នកលក់អាហារសុទ្ធ ទទួលបានផលចំណេញ

---

[១] លោក លន់ ពិដេ និង តុង គឹមស៊ុន ជាអ្នកស្រាវជ្រាវ នៅវិទ្យាស្ថាន CDRI។

នៅពេលថ្លៃម្ហូបអាហារកើនឡើង តែអ្នកទិញអាហារសុទ្ធត្រូវខាតបង់។ វិធីសាស្ត្រវាស់វែងផលប៉ះពាល់នេះ មិនមែនជាវិធីសាស្ត្រថ្មីទេ ព្រោះក្រោយលោក Deaton (1989) បានសរសេរវាឡើង គឺមានអ្នកស្រាវជ្រាវជាច្រើននាក់បានយកវាមកប្រើប្រាស់យ៉ាងទូលំទូលាយ ដូចជា Budd (1993), Barrett & Dorosh (1996), Minot & Goletti (2000), Kytchnikova & Diop (2006), Arndt *et al.* (2008) និង Ivanic & Martin (2008) ។

ដោយប្រើទិន្នន័យអង្កេតគ្រួសារឆ្នាំ២០១១ លទ្ធផលនៃការសិក្សានេះបង្ហាញថា ការឡើងថ្លៃម្ហូបអាហារ ធ្វើឲ្យខូចខាតដល់សុខមាលភាពគ្រួសារ និងបង្កើនអត្រាភាពក្រីក្រ។ អ្នកក្រីក្របំផុតជាអ្នករងគ្រោះខ្លាំងជាងគេ ព្រោះ សមត្ថភាពផលិតម្ហូបអាហារដោយខ្លួនឯងនៅខ្សោយ។ មូលហេតុចម្បងៗដែលបង្ក កំណើនថ្លៃម្ហូបអាហារក្នុងឆ្នាំ២០០៨ និង ២០១១ នៅកម្ពុជា មិនមែនមានត្រឹមតែ កត្តាខាងក្រៅដូចជា ការឡើងថ្លៃទំនិញជាទូទៅនៅទីផ្សារអន្តរជាតិ ការឡើងថ្លៃប្រេងឥន្ធនៈ និងការធ្លាក់ថ្លៃប្រាក់ដុល្លារអាមេរិកប៉ុណ្ណោះទេ ប៉ុន្តែកត្តាខាងក្នុងក៏រួមចំណែកធ្វើឲ្យថ្លៃម្ហូបអាហារកើនឡើងដែរ ដូចជា តម្រូវការក្នុងស្រុកកើនខ្ពស់ខុសប្រក្រតី និងការរំពឹងទុកពីកំណើនថ្លៃទំនិញ ឬអតិផរណា។ ជាជម្រើសគោលនយោបាយ ការសិក្សានេះបញ្ជាក់ថា សំណាញ់សុវត្ថិភាពសង្គមមួយដ៏ខ្លាំង និងមានប្រសិទ្ធភាព និងការផ្ដោតលើការអភិវឌ្ឍវិស័យកសិកម្មក្នុងរយៈពេលវែង គឺជាកត្តាសំខាន់ដើម្បីដោះស្រាយ និង ទប់ទល់ការឡើងថ្លៃម្ហូបអាហារនៅកម្ពុជា។

អត្ថបទនេះចែកចេញជា៦ផ្នែក។ ផ្នែកទី២ នៅខាងក្រោម បង្ហាញដោយសង្ខេបពី វិធីសាស្ត្រ និងទ្រឹស្ដីពាក់ព័ន្ធនឹងការសិក្សានេះ ផ្នែកទី៣ ពិភាក្សាពី និន្នាការ និងមូលហេតុនៃការឡើងថ្លៃម្ហូបអាហារ ផ្នែកទី៤ បង្ហាញពីផលប៉ះពាល់នៃការឡើងថ្លៃម្ហូបអាហារលើភាពក្រីក្រ ផ្នែកទី៥ ពិនិត្យពីគោលនយោបាយឆ្លើយតបរបស់រដ្ឋាភិបាល និង ផ្នែកទី៦ ជាសេចក្ដីសន្និដ្ឋាន។

## ៥.២ ទ្រឹស្ដី និងវិធីសាស្ត្រស្រាវជ្រាវ

ដើម្បីវាយតម្លៃពីផលប៉ះពាល់នៃ ការឡើងថ្លៃម្ហូបអាហារទៅលើជនក្រីក្រ ការសិក្សានេះបានយក វិធីសាស្ត្រវាស់វែងផលប៉ះពាល់សុខមាលភាព (welfare impact model) ដែលរកឃើញដោយ Deaton (1989) មកកែសម្រួល និងប្រើប្រាស់។ វិធីសាស្ត្រនេះកំណត់អត្តសញ្ញាណគ្រួសារថា តើជាអ្នកលក់អាហារសុទ្ធ ឬជាអ្នកទិញអាហារសុទ្ធ។ អ្នកលក់អាហារសុទ្ធ ទទួលប្រយោជន៍ពីការឡើងថ្លៃម្ហូបអាហារ ខណៈដែលអ្នកទិញអាហារសុទ្ធ ប្រឈមនឹងការខូចខាតសុខមាលភាព។ គ្រួសារមួយត្រូវបានចាត់ថ្នាក់ជា អ្នកលក់អាហារសុទ្ធ លុះត្រាតែផលអាហារសរុបដែលគ្រួសារនោះផលិតបាន មានតម្លៃលើសពីការហូប។[២] ផ្ទុយទៅវិញ ប្រសិនបើគ្រួសារនោះ ផលិតអាហារតិចជាងការហូប គឺត្រូវចាត់ទុកជា អ្នកទិញអាហារសុទ្ធ។ នៅពេលថ្លៃម្ហូបអាហារកើនឡើង អ្នកលក់អាហារសុទ្ធទទួលបានផលចំណេញ រីឯអ្នកទិញអាហារសុទ្ធទទួលរងគ្រោះ។ ប្រសិនបើគ្រួសារមួយផលិតបានច្រើនជាងការហូប (អ្នកលក់អាហារសុទ្ធ) ផលិតផលលើស និងការឡើងថ្លៃម្ហូបអាហារធ្វើឲ្យជីវភាពគ្រួសារនោះគ្រាន់បើជាងមុន។ សមីការខាងក្រោម ត្រូវបានយកមកប្រើប្រាស់ ដើម្បីវាស់វែងផលប៉ះពាល់នៃការឡើងថ្លៃម្ហូបអាហារ៖

$$\Delta W_h = \Delta p \times \left( \sum_{i=1}^{k} (p_i q_i - e_i) - \sum_{j=1}^{m} p_j q_j \right) / X_h,$$

---

២ ការគណនាផ្អែកលើអនុបាតផលិតកម្ម (ការប្រើប្រាស់) អាហារ ដែលជាផលធៀបនៃផលិតផល (ការប្រើប្រាស់) អាហារសរុប និងការចំណាយសរុប។

ក្នុងនេះ $\triangle W_b$ គឺជាបម្រែបម្រួលសុខមាលភាពក្នុងគ្រួសារ $\triangle P$ ជាបម្រែបម្រួលថ្លៃម្ហូបអាហារ $p_iq_i$ ជាចំណូលដុល ពីការលក់ម្ហូបអាហារ $e_i$ ជា ចំណាយថ្លៃដើមផលិតម្ហូបអាហារដែលបានលក់ $p_jq_j$ ជាចំណាយក្នុងការទិញម្ហូបអាហារ និង $X_b$ ជាចំណាយសរុប។

ដើម្បីអង្កេតពីមូលហេតុនៃការឡើងថ្លៃម្ហូបអាហារ ជាទ្រឹស្តីគេត្រូវពិនិត្យពី ការបញ្ជូនថ្លៃពីទីផ្សារអន្តរជាតិ ទៅទីផ្សារក្នុងស្រុក។ ជាទូទៅ គេតែងយក vector auto- regression (VAR) ម៉ូដែល មកប្រើដើម្បីពិនិត្យពីការបញ្ជូនកំណើនថ្លៃទាំងនោះ ដែលរួមមាន ថ្លៃម្ហូបអាហារ និង ថ្លៃប្រេងឥន្ធនៈ ទៅកាន់អត្រាអតិផរណា (Bhundia 2002; McCarthy 2007; Duma 2008)។

ការសិក្សានេះប្រើទិន្នន័យអង្កេតលើ ៤២០គ្រួសារ ក្នុងឆ្នាំ២០១១ នៅ ៨ភូមិ (៥ភូមិជាភូមិជនបទ) ក្នុង ៦ខេត្តក្រុងគឺ បាត់ដំបង កំពង់ឆ្នាំង កំពង់ធំ កំពង់ស្ពឺ សៀមរាប និងភ្នំពេញ។ ក្នុងការវិភាគពីមូលហេតុនៃការឡើងថ្លៃម្ហូបអាហារ ទិន្នន័យអំពីសន្ទស្សន៍ថ្លៃម្ហូបអាហារ និងភេសជ្ជៈ ពីឆ្នាំ ២០០៧ ដល់ ២០១១ ដែលបោះពុម្ពផ្សាយដោយ វិទ្យាស្ថានជាតិស្ថិតិ ត្រូវបានយកមកប្រើ។ ព័ត៌មានពីគោលនយោបាយឆ្លើយតបរបស់រដ្ឋាភិបាល គឺប្រមូលយកបានពីប្រភពបន្ទាប់បន្សំ ដោយរួមបញ្ចូលទាំងអត្ថបទសិក្សាស្រាវជ្រាវផ្សេងៗផង។

## ៥.៣ មូលហេតុនៃការឡើងថ្លៃម្ហូបអាហារ

**ទស្សនវិស័យពិភពលោក៖** ថ្លៃម្ហូបអាហារលើទីផ្សារអន្តរជាតិ បានកើនឡើងយ៉ាងខ្លាំង ក្នុងឆមាសទី១ ឆ្នាំ២០០៨ (រូបភាព ៥.១)។ ការសិក្សាជាច្រើនបានព្យាយាមកំណត់ពីមូលហេតុនៃការឡើងថ្លៃនេះ ដោយមានការសិក្សាខ្លះលើកថា តម្រូវការ និងការផ្គត់ផ្គង់ ជាកត្តាកំណត់នៃការឡើងថ្លៃ ចំណែកឯការសិក្សាខ្លះទៀតបកស្រាយថា ទីផ្សារហិរញ្ញវត្ថុ និងអត្រាប្តូរប្រាក់ទៅវិញទេ ដែលធ្វើឲ្យថ្លៃម្ហូបអាហារកើនឡើង។

រូបភាព ៥.១៖ សន្ទស្សន៍ថ្លៃទំនិញនៅទីផ្សារអន្តរជាតិ




ប្រភព៖ មូលនិធិរូបិយវត្ថុអន្តរជាតិ, ស្ថិតិហិរញ្ញវត្ថុអន្តរជាតិ (http://www.imf.org/external/data.htm ទទួលបានថ្ងៃទី១៤ វិច្ឆិកា ២០១១)

យ៉ាងហោចណាស់មានការបកស្រាយចំនួនបី ទាក់ទងនឹងកំណើនតម្រូវការ គឺមាន កំណើនប្រជាជនក្នុងពិភពលោក និងកំណើនប្រាក់ចំណូលគួរឲ្យកត់សម្គាល់ក្នុងប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួន, កំណើនផលិតកម្មអេតាណុល និងជីវឧស្ម័នដែលត្រូវការផលិតផលកសិកម្មយ៉ាងច្រើន, និងការប្រុងប្រយ័ត្នជ្រុលរបស់ប្រទេសមួយចំនួន ក្នុងអំឡុងពេលថ្លៃម្ហូបអាហារកើនឡើងនាឆ្នាំ២០០៨ (ការស្តុកអង្ករទុកច្រើនលើសលុប)។ ក្នុងពេលជាមួយគ្នា ការផ្គត់ផ្គង់ជួបឧបសគ្គខ្លះដូចជា ការថយចុះស្តុកម្ហូបអាហារ ផលិតភាពធ្លាក់ចុះ ភាពមិនអំណោយផលនៃអាកាសធាតុ ការឡើងថ្លៃប្រេងឥន្ធនៈ និងការរឹតត្បិតការនាំចេញពីសំណាក់ប្រទេសនាំចេញ ក៏បានរួមចំណែកធ្វើឲ្យម្ហូបអាហារឡើងថ្លៃដែរ។

**ទស្សនវិស័យប្រទេសកម្ពុជា៖** សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់បង្ហាញពីការឡើងថ្លៃម្ហូបអាហារគួរឲ្យកត់សម្គាល់នៅកម្ពុជា ចាប់តាំងពីពាក់កណ្តាលឆ្នាំ២០០៧ មក។ ថ្លៃម្ហូបអាហារ និងភេសជ្ជៈគ្មានជាតិស្រា ដែលមានកំណើនទាបជាងមុខទំនិញដទៃទៀតក្នុងឆ្នាំ១៩៩៧-២០០៧ បានកើនឡើងយ៉ាងខ្លាំងចាប់តាំងពីខែមិថុនា ២០០៧ ដល់ កញ្ញា ២០០៨។ ក្នុងពេលជាមួយគ្នា ថ្លៃផ្ទះសម្បែង និងការផ្គត់ផ្គង់សាធារណៈ (ទឹក និងអគ្គិសនី) ក៏កើនឡើងខ្លាំងដែរ ដោយសារមូលហេតុចម្បង ការហូរចូលសាច់ប្រាក់ពីបរទេស ធ្វើឲ្យតម្លៃអចលនទ្រព្យកើនឡើង។ ដោយឡែក ថ្លៃម្ហូបអាហារ និងភេសជ្ជៈគ្មានជាតិស្រា កើនលឿនបំផុត ដល់ទៅ ៤៨,៦% ក្នុងរយៈពេល១ខែ នៅខែឧសភា ២០០៨។ សន្ទស្សន៍ថ្លៃម្ហូបអាហារ និងភេសជ្ជៈគ្មានជាតិស្រា បានបន្តកើនឡើងរហូតដល់កម្រិតខ្ពស់បំផុត ចាប់តាំងពីសន្ទស្សន៍នេះត្រូវបានគណនានៅឆ្នាំ១៩៩៧ មក ប៉ុន្តែ អត្រាកំណើនរបស់វាមានលក្ខណៈថេរជាងកាលពីឆ្នាំ២០០៤-២០០៦។ ថ្លៃម្ហូបអាហារ និងភេសជ្ជៈគ្មានជាតិស្រា បានកើនឡើងសារជាថ្មីក្នុងរយៈពេល៤ខែ រហូតដល់ខែកញ្ញា ២០១១ ដោយមានកំណើនជាមធ្យម ៨,៤% ក្នុង១ខែ ឬ ៤,២ ឯកតាភាគរយ ខ្ពស់ជាងក្នុងអំឡុងពេលពីខែមករា ដល់ មេសា ២០១១។ សន្ទស្សន៍ថ្លៃម្ហូបអាហារ និងភេសជ្ជៈគ្មានជាតិស្រា ដែលខ្ពស់ជាងសន្ទស្សន៍ថ្លៃមុខទំនិញគ្រប់មុខទៅទៀតនេះ បញ្ជាក់ថា ថ្លៃម្ហូបអាហារ និងភេសជ្ជៈគ្មានជាតិស្រា ជាមូលហេតុចម្បងនៃអតិផរណានាពេលបច្ចុប្បន្ន។

រូបភាព ៥.២៖ អតិផរណាប្រចាំខែ ឆ្នាំ១៩៩៨-២០១១




ប្រភព៖ អង្កេតថ្លៃទំនិញ CDRI (1998-2012)

ថ្លៃទំនិញកើនឡើងបន្តិចម្តងៗ ចាប់ពីឆ្នាំ១៩៩៨ ដល់ចុងឆ្នាំ២០០៦។ នៅដើមឆ្នាំ២០០៧ ថ្លៃអង្ករ ត្រី និងសាច់ជ្រូកបានបន្តកើនឡើងក្នុងកម្រិតថេរមួយ។ មួយឆ្នាំក្រោយមក ថ្លៃសាច់គោ និងប្រេងសាំងក៏កើនឡើងដែរ។ នៅពាក់កណ្តាលឆ្នាំ២០០៨ ថ្លៃទំនិញគ្រប់មុខបានកើនដល់ចំណុចខ្ពស់បំផុត ហើយការឡើងថ្លៃមុខទំនិញនីមួយៗ មានមូលហេតុខុសៗគ្នា។ ដោយឡែក ការឡើងថ្លៃប្រេងឥន្ធនៈ តម្រូវការម្ហូបអាហារខ្ពស់ ការផ្លាស់ប្តូរទៅហូបអាហារមានគុណភាពខ្ពស់ជាងមុន និងការយកផលិតផលជាអាហារមនុស្សទៅធ្វើអេតាណុលនិងប្រេងឥន្ធនៈសម្រាប់ការប្រើប្រាស់ទូទាំងសាកលលោក គឺជាកត្តាចម្បងដែលធ្វើឲ្យថ្លៃម្ហូបអាហារនៅកម្ពុជាកើនឡើង។ ការវិភាគក្នុងការសិក្សានេះក៏បានបង្ហាញថា មិនត្រឹមតែកត្តាខាងក្រៅ ដូចជា ការឡើងថ្លៃប្រេងឥន្ធនៈនិងទំនិញ និងការចុះថោកប្រាក់ដុល្លារអាមេរិកនោះទេ ដែលធ្វើឲ្យថ្លៃម្ហូបអាហារក្នុងប្រទេសកម្ពុជាកើនឡើង ប៉ុន្តែកត្តាខាងក្នុង មានជាអាទិ៍ តម្រូវការក្នុងស្រុកកើនខ្ពស់ខុសប្រក្រតី និងការរំពឹងទុកពីការឡើងថ្លៃទំនិញ ឬអតិផរណា ក៏ជាកត្តាសំខាន់មួយធ្វើឲ្យ ថ្លៃម្ហូបអាហារនៅកម្ពុជាកើនឡើងនៅឆ្នាំ២០០៨ ។

## ៥.៤ ផលប៉ះពាល់នៃការឡើងថ្លៃម្ហូបអាហារ

ក្នុងការវិភាគ ម្ហូបអាហារត្រូវបានបែងចែកជាពីរប្រភេទ គឺ អង្ករ និងអាហារផ្សេងទៀតដែលរួមមាន ដំណាំក្រៅពីអង្ករ សាច់ និងត្រី។

លទ្ធផលបឋមនៃអង្កេតនេះ បង្ហាញថា ៦៨% នៃគ្រួសារជនបទសរុបក្នុងសំណាក ជាអ្នកផលិតស្រូវដោយមានផលិតភាពជាមធ្យម ២តោន/ហិកតា។ ម៉្យាងទៀត ៧២% នៃគ្រួសារជនបទសរុបមានដីកសិកម្ម ហើយជាមធ្យមគ្រួសារនីមួយៗមានដីតិចជាងមួយហិកតា។ ផលស្រូវសរុបជាមធ្យមក្នុងមួយគ្រួសារនៅជនបទមានតម្លៃប្រហែល ២លានរៀល (ឬប្រហែល ៥០០ដុល្លារអាមេរិក) ក្នុងមួយឆ្នាំ។ ផលអាហារផ្សេងទៀតក្នុងមួយគ្រួសារជនបទ មានតម្លៃជាមធ្យមខ្ពស់ជាងនេះ គឺប្រមាណ ៤លានរៀលក្នុងមួយឆ្នាំ។

ក្នុងចំណោមភូមិទាំងបីនៅទីក្រុង មានភូមិមួយផលិតបានស្រូវច្រើនដល់ប្រហែល ២លានរៀលក្នុងមួយឆ្នាំ ដោយហេតុថា ៩២% នៃគ្រួសារទាំងអស់ក្នុងភូមិនេះ ជាអ្នកដាំស្រូវ និងទទួលបានទិន្នផលខ្ពស់ រហូតដល់ប្រមាណ ៤តោនក្នុងមួយហិកតា ដែលខ្ពស់ជាងទិន្នផលមធ្យមក្នុងភូមិជនបទទៅទៀត។ ផលអាហារមិនមែនស្រូវផ្សេងៗក្នុងភូមិនេះក៏មានតម្លៃខ្ពស់ដែរ ហើយមួយគ្រួសារទទួលបានប្រហែល ៦,៥លានរៀលក្នុងមួយឆ្នាំ។ ភូមិទីក្រុងពីរទៀត មិនមែនជាភូមិផលិតស្រូវទេ ហើយបរិមាណផលិតផលមិនមែនស្រូវផ្សេងៗ ក៏មានតម្លៃទាបដែរ។

ចំណែកនៃការចំណាយទៅលើអង្ករក្នុងចំណាយសរុបលើម្ហូបអាហារនៅភូមិជនបទ(៣២%) មានកម្រិតខ្ពស់ ជាងនៅភូមិទីក្រុង (២២%)។ តួលេខនេះបង្ហាញថា ភូមិទីក្រុង ចំណាយច្រើនទៅលើអាហារមិនមែនជាអង្ករ។ ចំណាយសរុបក្នុងមនុស្សម្នាក់ (អាហារ និងមិនមែនអាហារ) នៅភូមិទីក្រុង មានចំនួនប្រមាណ ៥០% ច្រើនជាងការចំណាយនៅភូមិជនបទ។

**អ្នកលក់អាហារសុទ្ធ និងអ្នកទិញអាហារសុទ្ធ៖** ក្នុងចំណោមភូមិជនបទទាំងប្រាំ មានភូមិតែមួយគត់ជាអ្នកលក់អង្ករសុទ្ធ រីឯភូមិជនបទបួនផ្សេងទៀតនោះ ផលិតបានស្រូវតិច មិនគ្រប់សម្រាប់ការប្រើប្រាស់ក្នុងភូមិខ្លួនឯងទេ។ ដូចគ្នាដែរ ក្នុងចំណោមភូមិទីក្រុងទាំងបី មានភូមិតែមួយគត់ជាអ្នកលក់អង្ករសុទ្ធ ព្រោះមានសមត្ថភាពផលិតស្រូវខ្ពស់។ ម៉្យាងទៀត ក្នុងចំណោមភូមិទាំង៨ មិនមានភូមិណាមួយជាអ្នកលក់អាហារ (អង្ករ និងអាហារផ្សេងទៀត) សុទ្ធទេ ដែលមានន័យថា ចំណូលបានមកពីការផលិតអាហារក្នុងគ្រួសារ មិនអាចទូទាត់ចំណាយសរុបលើអាហារវិញទេ ហើយ

គ្រួសារទាំងនោះគឺជាអ្នកទិញអាហារសុទ្ធ។ គ្រួសារខ្លះជាអ្នកលក់អង្ករសុទ្ធ តែប្រហែលមិនមែនជាអ្នកលក់អាហារសុទ្ធទេ ប្រសិនបើចំណូលពីការលក់អង្ករ វាមិនគ្រប់គ្រាន់សម្រាប់ការចំណាយទៅលើការទិញអាហារសរុបក្នុងគ្រួសារ។

**ផលប៉ះពាល់ទៅលើសុខមាលភាព៖** ផលប៉ះពាល់នៃការឡើងថ្លៃម្ហូបអាហារ អាចបែងចែកជាពីរដំណាក់កាលគឺ អតិផរណាថ្លៃម្ហូបអាហារនៅឆ្នាំ២០០៧ និង ២០០៨ និងអតិផរណាថ្លៃម្ហូបអាហារប្រចាំឆ្នាំពីឆ្នាំ២០០៩ ដល់ ២០១១ (ខែមករា ដល់ កញ្ញា)។ លទ្ធផលមានបង្ហាញដោយឡែកៗពីគ្នាសម្រាប់ អង្ករ និងអាហារសរុប(រួមទាំងអង្ករ)។

អតិផរណាថ្លៃអង្ករមានកម្រិតខ្ពស់ ក្នុងអំឡុងពេលមានវិបត្តិថ្លៃម្ហូបអាហារ។ អតិផរណាថ្លៃអង្ករប្រចាំឆ្នាំជាមធ្យមនៅឆ្នាំ២០០៧ និង ២០០៨ មានប្រមាណ ៧៣%។ ប៉ុន្តែ ពីឆ្នាំ២០០៩ ដល់ ២០១១ (ក្នុង ៩ខែដើមឆ្នាំ) អតិផរណាមានត្រឹម ៣% ប៉ុណ្ណោះ។ ដូចមានបង្ហាញក្នុង តារាង ៥.១ ការខូចខាតសុខមាលភាពគ្រួសារនៅជនបទ មានប្រហែល ២,៩% រីឯគ្រួសារទីក្រុងមានប្រហែល ៣,៤% ។ ការខូចខាតសុខមាលភាពសរុប មានប្រហែល ៣,៥% ក្នុងពេលមានវិបត្តិថ្លៃម្ហូបអាហារនៅឆ្នាំ២០០៨ និង ០,១% ប៉ុណ្ណោះ ក្នុងពេលឡើងថ្លៃអង្ករថ្មីៗនៅឆ្នាំ២០១១។

តារាង ៥.១៖ ផលប៉ះពាល់ទៅលើសុខមាលភាពដោយសារការឡើងថ្លៃអង្ករ

| | កំណើនថ្លៃអង្ករ | |
|---|---|---|
| តំបន់ | 73% (2007-2008) | 3% (2009-2011) |
| ជនបទ | −2.96 | −0.12 |
| ទីក្រុង | −3.36 | −0.13 |
| កម្ពុជា | −3.50 | −0.12 |

ប្រភព៖ គណនាដោយអ្នកនិពន្ធ

អតិផរណាថ្លៃម្ហូបអាហារក្នុងអំឡុងពេលវិបត្តិ មានកម្រិត ៣២% (ដែលជាកំណើនមធ្យមប្រចាំឆ្នាំពីឆ្នាំ២០០៦-២០០៨) ហើយពីឆ្នាំ២០០៩ ដល់ ២០១១ (គិតពីខែមករា ដល់ កញ្ញា) មាន ១០%។ ក្នុងអំឡុងពេលមានវិបត្តិថ្លៃម្ហូបអាហារ ការខូចខាតសុខមាលភាពរបស់គ្រួសារជនបទមានប្រហែល ៩% រីឯគ្រួសារទីក្រុងមានប្រហែល ១០%។ ការខូចខាតសុខមាលភាពសរុប ដោយសារការឡើងថ្លៃអាហារពីឆ្នាំ២០០៩ ដល់ខែកញ្ញា ២០១១ មានកម្រិតទាបជាងត្រឹមប្រមាណ ៣% (តារាង ៥.២)។

តារាង ៥.២៖ ផលប៉ះពាល់ទៅលើសុខមាលភាពដោយសារការឡើងថ្លៃម្ហូបអាហារ

| | កំណើនថ្លៃម្ហូបអាហារ | |
|---|---|---|
| តំបន់ | 32% (2007-2008) | 10% (2009-2011) |
| ជនបទ | −9.18 | −2.86 |
| ទីក្រុង | −9.80 | −3.06 |
| កម្ពុជា | −9.70 | −2.93 |

ប្រភព៖ គណនាដោយអ្នកនិពន្ធ

**ផលប៉ះពាល់ទៅលើភាពក្រីក្រ៖** វិធីសាស្ត្រសាមញ្ញបំផុតមួយ សម្រាប់វាស់វែងផលប៉ះពាល់ទៅលើភាពក្រីក្រ គឺការគណនា ចំណាយប្រើប្រាស់ក្នុងគ្រួសារសរុប នៅមុន និងក្រោយពេលឡើងថ្លៃម្ហូបអាហារ។ តួលេខនៃការកើនឡើង ឬថយចុះនៃចំណូលពិត (សុខមាលភាព) ក្រោយការឡើងថ្លៃម្ហូបអាហារ ត្រូវបានប្រើប្រាស់ដើម្បីគណនា ចំណាយថ្មីនៃការប្រើប្រាស់ក្នុងគ្រួសារ និងបន្ទាប់មកប៉ាន់ស្មានផលប៉ះពាល់លើភាពក្រីក្រ។ ដូចមានបង្ហាញក្នុង តារាង ៥.៣ ក្នុងអំឡុងពេលនៃវិបត្តិថ្លៃម្ហូបអាហារឆ្នាំ២០០៨ ចំនួនអ្នកក្រីក្របានកើនឡើងគួរឲ្យកត់សម្គាល់ជិតដល់ ៦ ឯកតាភាគរយ។ លទ្ធផលនេះ ស្រដៀងគ្នានឹង លទ្ធផលរបស់ ADB (2011) ដែលបង្ហាញថា ចំនួនអ្នកក្រីក្រត្រូវកើនឡើង ៦,៨ ឯកតាភាគរយ ប្រសិនបើថ្លៃម្ហូបអាហារកើនឡើង ៣០%។ ចំណែកឯលទ្ធផលនៃការសិក្សានេះ ក៏ស្រដៀងគ្នាទៅនឹងលទ្ធផលរបស់ Ivanic and Martin (2008) (តារាង ៥.៤) ដែលសន្និដ្ឋានថា ចំនួនអ្នកក្រីក្រត្រូវកើនឡើង ០,៥ ឯកតាភាគរយ ប្រសិនបើថ្លៃអង្ករកើនឡើង ១០%។

តារាង ៥.៣៖ ផលប៉ះពាល់ទៅលើភាពក្រីក្រដោយសារ ការឡើងថ្លៃម្ហូបអាហារ

| តំបន់ | ចំនួនអ្នកក្រីក្រ (%) | | បម្រែបម្រួល ចំនួនអ្នកក្រីក្រ (ឯកតាភាគរយ) |
|---|---|---|---|
| | មុនវិបត្តិ | ក្រោយវិបត្តិ | |
| ជនបទ | 6.3 | 9.8 | +3.5 |
| ទីក្រុង | 19.2 | 25.2 | +6.0 |
| កម្ពុជា | 15.6 | 21.4 | +5.8 |

ប្រភព៖ គណនាដោយអ្នកនិពន្ធ

តារាង ៥.៤៖ ផលប៉ះពាល់ទៅលើភាពក្រីក្រដោយសារ ការឡើងថ្លៃអង្ករ

| តំបន់ | ចំនួនអ្នកក្រីក្រ (%) | | បម្រែបម្រួល ចំនួនអ្នកក្រីក្រ (ឯកតាភាគរយ) |
|---|---|---|---|
| | មុនវិបត្តិ | ក្រោយវិបត្តិ | |
| ជនបទ | 6.3 | 8.0 | +1.7 |
| ទីក្រុង | 19.2 | 23.5 | +4.3 |
| កម្ពុជា | 15.6 | 18.6 | +3.0 |

ប្រភព៖ គណនាដោយអ្នកនិពន្ធ

## ៥.៥ គោលនយោបាយឆ្លើយតប

ប្រទេសកម្ពុជា ក៏ដូចជាប្រទេសឯទៀតក្នុងតំបន់ដែរ បានដាក់ចេញវិធានការដោយផ្ទាល់ និងដោយប្រយោលមួយចំនួន ដើម្បីកាត់បន្ថយផលប៉ះពាល់អវិជ្ជមានផុសចេញពីការឡើងថ្លៃម្ហូបអាហារឆ្នាំ២០០៨។ រដ្ឋាភិបាល ក៏បានបង្កើតក្រុមការងារឃ្លាំមើលថ្លៃទំនិញ ដើម្បីតាមដានបញ្ហានេះឲ្យបានដិតដល់។ គោលនយោបាយរយៈពេលខ្លី និងមធ្យមដែលបានអនុវត្ត និងប្រសិទ្ធិភាពរបស់វា មានជាសង្ខេបដូចខាងក្រោម៖

| គោលនយោបាយរយៈពេលខ្លី (ភ្លាមៗ) | គោលនយោបាយរយៈពេលមធ្យម |
|---|---|
| • បិទការនាំអង្ករចេញជាបណ្តោះអាសន្ន<br>• បញ្ចេញអង្ករ ៣០០តោន លក់ក្នុងតម្លៃទាបជាងទីផ្សារ<br>• ផ្តល់កម្ចី ១២លានដុល្លារអាមេរិកដល់ធនាគារអភិវឌ្ឍន៍ជនបទដើម្បីបង្កើនស្តុកអង្ករ<br>• មិនយកពន្ធលើវត្ថុធាតុដើមកសិកម្ម<br>• ដកចេញការហាមឃាត់លើការនាំជ្រូកចូល<br>• កាត់បន្ថយពន្ធលើម្ហូបអាហារនាំចូលដល់កម្រិតសូន្យ<br>• ការយកពន្ធថេរ<br>• ឧបត្ថម្ភធនលើពន្ធអគ្គិសនី<br>• ត្រួតពិនិត្យអាជីវករលក់ប្រេង ដើម្បីទប់ស្កាត់ការប៉ាន់ស្មានតម្លៃជាមុន<br>• ផ្តល់គ្រាប់ពូជមានទិន្នផលខ្ពស់ដល់កសិករខ្នាតតូច<br>• លក់ពូជ និងជីក្នុងតម្លៃមានឧបត្ថម្ភធនជូនកសិករមួយចំនួន<br>• តម្លើងទុនបម្រុងធនាគារពីរដងពី ៨ ទៅ ១៦%<br>• កំណត់កម្ចីក្នុងវិស័យអចលនទ្រព្យត្រឹម ១៥%<br>• តម្រូវឲ្យធនាគារពាណិជ្ជកម្មតម្លើងដើមទុនអប្បបរមា | • មិនយកពន្ធលើវត្ថុធាតុដើមកសិកម្ម តែតម្លើងពន្ធលើទំនិញប្រណីត (រថយន្ត ស្រា គ្រឿងសម្អាង)<br>• បង្កើនផលិតភាពកសិកម្ម<br>• បង្កើនផ្ទៃដីស្រោចស្រព និងផ្ទៃដីដាំដុះ<br>• បង្កើនឃ្លាំងស្តុកធញ្ញជាតិតាមទីជនបទ តាមកសិដ្ឋាន ថ្នាក់ខេត្ត និងថ្នាក់ជាតិ<br>• បង្កើនផលិតកម្មតាមរយៈការបង្កើនការស្រោចស្រព សម្រាប់ ដំណាំស្រូវដាំលើកទីពីរ និងបន្ទាប់<br>• កាត់បន្ថយការបាត់បង់ក្រោយពេលប្រមូលផល<br>• ធ្វើឲ្យប្រសើរឡើងនូវការស្តុកទិន្នន័យ ដើម្បីបំពេញបន្ថែមការធ្វើអន្តរាគមន៍គោលនយោបាយ |

គោលនយោបាយអន្តរាគមន៍របស់រដ្ឋាភិបាល ក្នុងការគ្រប់គ្រងតម្រូវការទីផ្សារដុល ឃើញថាមានប្រសិទ្ធភាព ដើម្បីទប់ស្កាត់អតិផរណា ក្នុងអំឡុងពេលមានវិបត្តិថ្លៃម្ហូបអាហារ ទោះជាមិនទាន់មានការសិក្សាស្វែងយល់ឲ្យជាក់លាក់ពីលទ្ធផលល្អនេះក្តី។ រដ្ឋាភិបាលក៏យល់ឃើញដែរថា ការរឹតបន្តឹងបទបញ្ញត្តិនានា ដើម្បីគ្រប់គ្រងតម្រូវការទីផ្សារ មិនមែនជាវិធីតែមួយគត់ដែលអាចទប់ស្កាត់អតិផរណាទេ។ ដូច្នេះក៏មានការដាក់ចេញនូវវិធានការរឹតបន្តឹងផ្នែកសារពើពន្ធ។ គេយល់ថាគោលនយោបាយសារពើពន្ធក៏អាចគ្រប់គ្រងកំណើនតម្រូវការទីផ្សារផងដែរ។ នៅកម្ពុជា គោលនយោបាយសារពើពន្ធនាពេលនោះ មិនមែនជាការតម្លើងពន្ធទេ តែជាការកែលំអការប្រមូលចំណូល និងកាត់បន្ថយចំណាយរដ្ឋបាលមិនសូវចាំបាច់។ ទោះជានៅពេលនោះ មានអតិរេកថវិកាក្តី ក៏ផលប៉ះពាល់លើអតិផរណា បានពីការរឹតបន្តឹងផ្នែកសារពើពន្ធ មានកម្រិតតិចតួច។

វិធានការជាលក្ខណៈម៉ាក្រូ ពុំសូវមានប្រសិទ្ធភាពទេ ក្នុងការកាត់បន្ថយផលប៉ះពាល់ពីការឡើងថ្លៃម្ហូបអាហារ កើតចេញពីកត្តាខាងក្រៅដូចជា ការឡើងថ្លៃប្រេង ការចុះថ្លៃប្រាក់ដុល្លារអាមេរិក និងការឡើងថ្លៃម្ហូបអាហារលើទីផ្សារអន្តរជាតិ។ ដូច្នេះ វិធានការបន្ទាន់គឺ ត្រូវបិទការនាំចេញ និងបញ្ចេញស្តុកផលិតផលកសិកម្ម។ នៅកម្ពុជា ការលក់អង្ករក្នុងតម្លៃទាបជាងទីផ្សារក្នុងអំឡុងពេលមានវិបត្តិ បានកាត់បន្ថយថ្លៃអង្ករក្នុងស្រុក តែប៉ះពាល់ថ្លៃអង្ករលើទីផ្សារពិភពលោក។ ការបិទការនាំចេញធ្វើឲ្យបរិមាណទំនិញផ្គត់ផ្គង់នៅទីផ្សារពិភពលោកថយចុះ ហើយថ្លៃម្ហូបអាហាររឹតតែកើនឡើង។

រដ្ឋាភិបាលបានធ្វើកិច្ចការល្អមួយ គឺ ការដកចេញការហាមឃាត់លើ ការនាំចូលសាច់ជ្រូកពីប្រទេសជិតខាង ដែលបានដាក់ចេញមុនពេលមានវិបត្តិ ក្នុងគោលដៅទប់ស្កាត់ជម្ងឺឆ្លង។ វិធានការ

នេះ មិនត្រឹមតែធ្វើឲ្យថ្លៃសាច់ជ្រូកធ្លាក់ចុះទេ ប៉ុន្តែថ្លៃសាច់សត្វដទៃទៀតដូចជា ត្រី និងសាច់គោក៏ធ្លាក់ចុះដែរ ដោយសារអ្នកប្រើប្រាស់បង្កើនតម្រូវការសាច់ជ្រូក ហើយកាត់បន្ថយតម្រូវការសាច់សត្វដទៃទៀត។ បើទោះជាគោលនយោបាយផ្តល់ឧបត្ថម្ភធន គួរមានការពិភាក្សាវិភាគបន្ថែមក្តី ក៏ការផ្តល់ឧបត្ថម្ភធនរបស់រដ្ឋាភិបាលទៅលើប្រេងឥន្ធនៈ និងអគ្គិសនី ជាវិធានការតែមួយគត់ដែលអាចកាត់បន្ថយថ្លៃរបស់វា និងជួយសម្រាលជីវភាពប្រជាពលរដ្ឋ។ ការយកពន្ធថេរលើប្រេង ក៏ជួយកាត់បន្ថយកំណើនពន្ធត្រូវបង់ ដែលប្រែប្រួលទៅតាមថ្លៃប្រេងនៅទីផ្សារអន្តរជាតិដែរ។ ការមិនយកពន្ធលើវត្ថុធាតុដើមកសិកម្ម ការផ្តល់គ្រាប់ពូជមានទិន្នផលខ្ពស់ដល់ប្រជាកសិករ និងការលក់គ្រាប់ពូជនិងជីកសិកម្មក្នុងតម្លៃមានឧបត្ថម្ភធន ក៏សុទ្ធសឹងជាវិធានការសំខាន់ៗ។

នៅកម្ពុជា ទោះបីថ្លៃម្ហូបអាហារបានចាប់ផ្តើមកើនឡើងម្តងទៀតចាប់ពីឆមាសទី២ ឆ្នាំ ២០០៩ ក្តី ក៏រដ្ឋាភិបាលពុំឃើញមានដាក់ចេញនូវវិធានការបន្ទាន់ណាមួយ ដូចកាលពីឆ្នាំ២០០៨ទេ។ ហេតុផលមួយ គឺប្រហែលជា រដ្ឋាភិបាលអាចគ្រប់គ្រងអតិផរណាទំនិញជាទូទៅបាន (ក្រោម ១០%) ទោះជាមានការឡើងថ្លៃម្ហូបអាហារក្តី។ ក្រោយពីវិបត្តិថ្លៃម្ហូបអាហារឆ្នាំ២០០៨ រដ្ឋាភិបាលបានផ្តោតការយកចិត្តទុកដាក់ទៅលើគោលនយោបាយរយៈពេលវែង ពោលគឺការជំរុញវិស័យកសិកម្ម ដែលរួមមាន ការមិនយកពន្ធលើវត្ថុធាតុដើមកសិកម្មដូចកំពុងអនុវត្តរហូតដល់សព្វថ្ងៃ និងគោលនយោបាយនាំអង្ករចេញតាមរយៈការបម្រុងថវិកាចំនួន ៣០០លានដុល្លារអាមេរិកក្នុងរយៈពេលពីរឆ្នាំ ដើម្បីកែលំអប្រព័ន្ធធារាសាស្ត្រ និងបង្កើនស្តុកម្ហូបអាហារ។ ទោះបីគោលនយោបាយជាលក្ខណៈទូលំទូលាយទាំងនេះ មិនមានគោលដៅដោះស្រាយការឡើងថ្លៃម្ហូបអាហារដោយផ្ទាល់ក្តី ក៏អាចជួយលើកទឹកចិត្តកសិករឲ្យប្រឹងបង្កើនទិន្នផលកសិកម្ម ហើយសម្រេចបានកំណើនបរិមាណម្ហូបអាហារផ្គត់ផ្គង់ក្នុងស្រុក ក៏ដូចជាលើសកលលោក ដែលអាចជួយកាត់បន្ថយហានិភ័យនៃវិបត្តិម្ហូបអាហារ និងអសន្តិសុខស្បៀង។

វិបត្តិម្ហូបអាហារឆ្នាំ២០០៨ ក៏បានជម្រុញឲ្យបណ្តាប្រទេសអាស៊ានដាក់ចេញនូវវិធានការទប់ទល់ដែរ។ ប្រទេសនាំអង្ករចេញដូចជា វៀតណាម និងថៃ បានបិទការនាំចេញ រីឯប្រទេសនាំអង្ករចូលដូចជា ហ្វីលីពីន ខិតខំទិញអង្ករស្តុកទុកឲ្យបានច្រើន។ ការបញ្ចេញអង្ករលក់ក្នុងតម្លៃមានឧបត្ថម្ភធន ក៏ឃើញមានអនុវត្តក្នុងប្រទេស វៀតណាម ហ្វីលីពីន និងថៃ។ ប្រទេសថៃ បានដាក់ចេញនូវ កម្មវិធីសំណាញ់សុវត្ថិភាពសង្គម តែមានបញ្ហាចោទក្នុងការកំណត់អត្តសញ្ញាណជនក្រីក្រឲ្យបានត្រឹមត្រូវ។

មេរៀនពីវិបត្តិម្ហូបអាហារឆ្នាំ២០០៨ ក៏បានជំរុញឲ្យរដ្ឋាភិបាលបណ្តាប្រទេសអាស៊ាន ជាពិសេសប្រទេសនាំស្បៀងចូល ផ្តល់អាទិភាពខ្ពស់ដល់បញ្ហាសន្តិសុខស្បៀង និងភាពមានស្បៀងអាហារគ្រប់គ្រាន់សម្រាប់ខ្លួនឯង។ តួយ៉ាង ប្រទេសហ្វីលីពីន បានបង្កើនស្តុកអង្កររហូតដល់ ៣,៤ លានតោន។ ប្រទេសឥណ្ឌូនេស៊ីបានផ្តល់អាទិភាពខ្ពស់ដល់ការជំរុញវិស័យកសិកម្ម ដោយផ្តល់ប្រាក់លើកទឹកចិត្ត និងការលើកលែងពន្ធលើការផ្គត់ផ្គង់ផលិតផលកសិកម្ម ហើយប្រទេសវៀតណាមក៏បានពង្រីកហេដ្ឋារចនាសម្ព័ន្ធ ដូចជា ការបង្កើនកន្លែងស្តុកផលិតផលកសិកម្ម ជាដើម។

## ៥.៦ សង្ខេបលទ្ធផលសំខាន់ៗ សេចក្តីសន្និដ្ឋាន និងជម្រើសគោលនយោបាយ

ការសិក្សានេះប្រើទិន្នន័យអង្កេតគ្រួសារឆ្នាំ២០១១ មកវាស់វែងផលប៉ះពាល់នៃការឡើងថ្លៃម្ហូបអាហារ ទៅលើជនក្រីក្រនៅកម្ពុជា និងប្រើវិធីសាស្ត្រសាមញ្ញមួយដែលក្នុងនោះ ទិន្នន័យពីផលិតកម្ម និងការចំណាយលើម្ហូបអាហារក្នុងគ្រួសារនីមួយៗ ត្រូវបានយកមកប្រើប្រាស់ដើម្បី

កំណត់ថាគ្រួសារណាជាអ្នកលក់អាហារសុទ្ធ និងគ្រួសារណាជាអ្នកទិញអាហារសុទ្ធ។ ការសិក្សានេះក៏ធ្វើវិភាគផងដែរពី មូលហេតុនៃការឡើងថ្លៃម្ហូបអាហារនៅកម្ពុជា និងគោលនយោបាយឆ្លើយតបរបស់រដ្ឋាភិបាល។

ការសិក្សាបានរកឃើញថា មានកត្តាចម្បងៗមួយចំនួនបានរួមចំណែកដល់ ការឡើងថ្លៃម្ហូបអាហារក្នុងស្រុកក្នុងឆ្នាំ២០១១ ដូចជា ការឡើងថ្លៃទំនិញលើទីផ្សារអន្តរជាតិ ការឡើងថ្លៃប្រេងឥន្ធនៈ និងការចុះថ្លៃប្រាក់ដុល្លារអាមេរិក។ ចំណែកឯអតិផរណាកម្រិតខ្ពស់ខ្លាំងនៅឆ្នាំ២០០៨ វាកើតចេញពី កំណើនខ្ពស់ខុសប្រក្រតីនៃតម្រូវការក្នុងស្រុក (ការរីកលូតលាស់ខ្លាំងក្នុងវិស័យអចលនទ្រព្យ) ការឡើងថ្លៃប្រេងនិងទំនិញ និងការចុះថោកប្រាក់ដុល្លារអាមេរិក។ ទោះជាអតិផរណាក្នុងឆ្នាំ២០១១ វាទាបជាងក្នុងឆ្នាំ២០០៨ ក្តី ក៏ថ្លៃម្ហូបអាហារនៅកម្ពុជាក្នុងឆ្នាំ២០១១ នៅតែមានកម្រិតខ្ពស់ ដែលបង្ហាញថា ការឡើងថ្លៃទំនិញលើទីផ្សារអន្តរជាតិ ការឡើងថ្លៃប្រេងឥន្ធនៈ និង ការចុះថ្លៃប្រាក់ដុល្លារអាមេរិក គឺជាមូលហេតុសំខាន់។ ម្យ៉ាងទៀត ការវិភាគដោយប្រើវិធី សាស្ត្រ VAR ម៉ូដែល ក៏បង្ហាញដែរថា កត្តាខាងក្រៅដូចបានរៀបរាប់ខាងលើ វាជាមូលហេតុនៃការឡើងថ្លៃទំនិញនៅកម្ពុជា ប៉ុន្តែវារួមចំណែកតិចតួចណាស់ក្នុងការឡើងថ្លៃនេះ។ ភស្តុតាងបានបញ្ជាក់ថា កត្តាខាងក្នុង ពោលគឺ ការរំពឹងទុកពីការឡើងថ្លៃទំនិញ ឬអតិផរណា វាជាកត្តារួមចំណែកធំនៅក្នុងកំណើនអត្រាអតិផរណា។ ដូច្នេះ អតិផរណាថ្លៃទំនិញនៅកម្ពុជា មិនមែនបណ្តាលមកតែពីកត្តាខាងក្រៅដែលរដ្ឋាភិបាលមិនអាចគ្រប់គ្រងបាននោះទេ។

ចំពោះផលប៉ះពាល់វិញ ការសិក្សានេះបង្ហាញថា ការឡើងថ្លៃទំនិញនៅកម្ពុជា ធ្វើឲ្យគ្រួសារខូចខាតសុខមាលភាព ហើយគ្រួសារក្រីក្របំផុតទទួលរងគ្រោះខ្លាំងជាងគេ។ ផលប៉ះពាល់ទៅលើភាពក្រីក្រក៏មានទំហំគួរឲ្យកត់សម្គាល់ ហើយវាស្រដៀងគ្នានឹង ការរកឃើញក្នុងការសិក្សាឯទៀតៗដែរ។ គ្រួសារក្រីក្របំផុតរងគ្រោះខ្លាំងជាងគេ ព្រោះមានអនុបាតនៃផលសុទ្ធ ទាបជាងគ្រួសារធូរធារ។ គ្រួសារនៅទីជនបទក្នុង សំណាកសម្រាប់ការសិក្សានេះ ភាគច្រើនមិនមែនជាអ្នកលក់អង្ករសុទ្ធទេ គឺបានន័យថា បរិមាណអង្ករដែលពួកគេផលិតបាន វាមិនគ្រប់គ្រាន់សម្រាប់ចិញ្ចឹមគ្រួសារទាំងមូលបានពេញមួយឆ្នាំឡើយ។ គ្រួសារដែលមានអនុបាតនៃផលសុទ្ធខ្ពស់ ភាគច្រើនជាអ្នកធូរធារមានអតិរេកខ្ពស់ក្នុងផលិតកម្មម្ហូបអាហារ ជាពិសេសអង្ករ។ ផលប៉ះពាល់ទៅលើភាពក្រីក្រមានទំហំតូចជាងមុន ប្រសិនបើ ថ្លៃអង្ករតែមួយមុខកើនឡើង ហើយថ្លៃទំនិញដទៃទៀតនៅថេរ។ ចំណុចនេះបញ្ជាក់ថា សម្រាប់ប្រទេសនាំចេញអង្ករដូចជាកម្ពុជា ការឡើងថ្លៃអង្ករមិនប្រាកដថា ផ្តល់ផលប្រយោជន៍ដល់អ្នកក្រទេ ហើយវាអាចកាត់បន្ថយអំណាចទិញរបស់ពួកគេថែមទៀត។

ការដាក់ចេញនូវ គោលនយោបាយឆ្លើយតបរបស់ រដ្ឋាភិបាល ពិតជាអាចជួយកាត់បន្ថយផលប៉ះពាល់នៃការឡើងថ្លៃទំនិញ ប៉ុន្តែវាអាចកាត់បន្ថយបានកម្រិតណា គឺជា សំណួរមួយដែលត្រូវមានការសិក្សាវែកញែកបន្ថែម។ គោលនយោបាយឆ្លើយតបខាងផ្នែករូបិយវត្ថុ សារពើពន្ធ និងអត្រាប្តូរប្រាក់ សុទ្ធតែជាវិធានការដ៏ចាំបាច់ មានប្រសិទ្ធភាពខ្ពស់ សម្រាប់ទប់ស្កាត់កំណើនអតិផរណាថ្លៃទំនិញជាទូទៅមិនមែនត្រឹមតែថ្លៃអង្ករមួយមុខទេ។វិធានការផ្ទាល់ដទៃទៀតភាគច្រើនមានរយៈពេលខ្លី រីឯវិធានការទាក់ទិននឹងពាណិជ្ជកម្មឆ្លងដែន ដូចជា ការបិទការនាំអង្ករចេញជាដើម វាជាវិធានការដែលអាចធ្វើឲ្យខូចដល់ទីផ្សារ។ បន្ថែមពីលើការប្តេជ្ញារបស់រដ្ឋាភិបាលក្នុងការជំរុញវិស័យកសិកម្ម ជាពិសេសដំណាំស្រូវ និងការពង្រឹងសំណាញ់សុវត្ថិភាពសង្គម រដ្ឋាភិបាលក៏បានដាក់ចេញនូវ វិធានការរយៈពេលខ្លីមួយចំនួនទៀត ដើម្បីទប់ទល់ការឡើងថ្លៃទំនិញ។ ដោយហេតុថា ការចំណាយទៅលើគម្រោងសំណាញ់សុវត្ថិភាពសង្គមភាគច្រើន ផ្តោតតែលើមន្ត្រី

រដ្ឋាភិបាល និងអ្នកធ្វើការក្នុងវិស័យផ្លូវការ ដូច្នេះគម្រោងនេះគួររួមបញ្ចូលអ្នកធ្វើការក្នុងវិស័យមិនផ្លូវការផង ដូចជា អ្នកធ្វើអាជីវកម្មដោយខ្លួនឯង និងនិយោជិតក្នុងសហគ្រាសដែលមិនបានចុះបញ្ជីពាណិជ្ជកម្ម ព្រោះអ្នកទាំងនោះមានចំនួនច្រើនលើសលុប ក្នុងកម្លាំងពលកម្មសរុបនៅកម្ពុជា។ CDRI (2002) បានប៉ាន់ស្មានថា ក្នុងឆ្នាំ២០០១ អ្នកធ្វើការក្នុងវិស័យមិនផ្លូវការមានប្រមាណ ៩៥% នៃកម្លាំងពលកម្មសរុប រីឯ វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា បានប៉ាន់ស្មានថា អ្នកធ្វើការក្នុងវិស័យមិនផ្លូវការមានប្រមាណ ៨៥% (ដកស្រង់ចេញពី ILO 2006)។

គោលនយោបាយសម្រាប់ដោះស្រាយបញ្ហាថ្លៃម្ហូបអាហារ រួមមានទាំងវិធានការរយៈពេលខ្លី មធ្យម និងវែង។ សម្រាប់គោលនយោបាយរយៈពេលខ្លី រដ្ឋាភិបាលគួរមានផ្តល់នូវ សំណាញ់សុវត្ថិភាពសង្គម ដែលរួមមាន កម្មវិធីផ្តល់ប្រាក់ដោយមានលក្ខខណ្ឌ កម្មវិធីពលកម្មដូរនឹងស្បៀងអាហារ និងកម្មវិធីផ្តល់ប័ណ្ណទិញអាហារ ជាដើម។ ប្រសិនបើគោលនយោបាយខាងលើ មិនបានដាក់អនុវត្តទេ ជនងាយរងគ្រោះជាច្រើន ដូចជា គ្រួសារក្រីក្រនៅទីក្រុង និងគ្មានដីធ្លី អាចប្រឈមមុខនឹងការស្រុតចុះផ្នែកសង្គម និងជីវភាព កង្វះអាហារូបត្ថម្ភ និងភាពក្រីក្រខ្លាំង។ តម្រូវការសំណាញ់សុវត្ថិភាពសង្គមដ៏រឹងមាំមួយនៅកម្ពុជា មានគូសរំលេចយ៉ាងច្បាស់ក្នុងការសិក្សាជាច្រើន។ ការសិក្សានេះក៏ខិតខំគូសបញ្ជាក់ដែរថា កម្មវិធីសំណាញ់សុវត្ថិភាពសង្គម ចាំបាច់ខ្លាំងណាស់។ ទោះយ៉ាងនេះក្តី ថវិកា និងសមត្ថភាព នៅតែជាបញ្ហាចោទនៅកម្ពុជា។ ម្យ៉ាងទៀត យន្តការសម្រាប់បញ្ជូនធនធានទាំងនេះ គួរមានតម្លាភាព និងប្រសិទ្ធភាព ដើម្បីជួយគាំទ្រឲ្យធនធានបានទៅដល់ដៃក្រុមគោលដៅ។ ក្រុមគោលដៅ គួរជាក្រុមងាយរងគ្រោះ និងអ្នកក្រីក្របំផុត។ ឧបករណ៍ប្រើប្រាស់សម្រាប់កំណត់ក្រុមគោលដៅ តួយ៉ាងដូចជា កម្មវិធីកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ របស់ក្រសួងផែនការ ជាដើម គួរតែយកមកអនុវត្តឲ្យបានទូទាំងប្រទេស។

គោលនយោបាយរយៈពេលមធ្យម និងវែង គួរគិតគូរពិចារណា ឲ្យបានស្របពេលជាមួយគោលនយោបាយរយៈពេលខ្លី។ កត្តាមួយក្នុងចំណោមកត្តាច្រើនទៀតដែលបង្កអតិផរណាថ្លៃម្ហូបអាហារ គឺអតុល្យភាពរវាងតម្រូវការ នឹងការផ្គត់ផ្គង់។ អ្នកស្រាវជ្រាវ និងអង្គការអន្តរជាតិនានា ក្នុងវិស័យម្ហូបអាហារ មានជំនឿថា កង្វះការយកចិត្តទុកដាក់លើការអភិវឌ្ឍជនបទ និងការផ្តល់ធនធានតិចទៅលើការស្រាវជ្រាវ និងអភិវឌ្ឍវិស័យកសិកម្ម ដើម្បីជំរុញវិធីអនុវត្តន៍ថ្មីៗ និងបង្កើនផលិតភាព វាជាមូលហេតុនាំឲ្យមានវិបត្តិថ្លៃម្ហូបអាហារ។ ចំណុចទាំងអស់នេះ សុទ្ធតែកម្ពុជាអាចអនុវត្តបាន។ សារគន្លឹះមួយនៃការសិក្សានេះ គឺ កម្ពុជាត្រូវប្រឹងជំរុញវិស័យកសិកម្មថែមទៀត។

ជាប្រការល្អណាស់ដែល រដ្ឋាភិបាលបានបង្ហាញការប្តេជ្ញាចិត្តជំរុញផលិតកម្មស្រូវ និងប្រឹងប្រែងធ្វើឲ្យកម្ពុជា បានស្ថិតក្នុងចំណោមប្រទេសនាំអង្ករចេញធំៗជាងគេនៅលើសកលលោកក្នុងឆ្នាំ២០១៥។ ការប្រឹងប្រែងនេះ មិនត្រឹមតែសំខាន់សម្រាប់ជំរុញជម្រុញកំណើនសេដ្ឋកិច្ចប៉ុណ្ណោះទេ តែក៏អាចជួយធានាឲ្យមានស្បៀងអាហារគ្រប់គ្រាន់សម្រាប់ខ្លួនឯង មានស្ថិរភាពថ្លៃ និងកាត់បន្ថយហានិភ័យអសន្តិសុខស្បៀងដែរ។ អនុសាសន៍មួយទៀតនៃការសិក្សានេះ គឺកម្ពុជាគួរជំរុញការអភិវឌ្ឍដំណាំជាអាហារផ្សេងទៀតក្រៅពីស្រូវ ព្រោះកម្ពុជាមានកត្តាអំណោយផលមួយចំនួន ដូចជា សម្បូរកម្លាំងពលកម្ម និងផ្ទៃដីដាំដុះ។ ដើម្បីគាំទ្រគោលដៅខាងលើ ការកសាង និងកែលំអហេដ្ឋារចនាសម្ព័ន្ធទាំងផ្នែកទន់ និង ផ្នែករឹង ការស្រាវជ្រាវនិងផ្សព្វផ្សាយកសិកម្ម ការគ្រប់គ្រងដីធ្លី ការពង្រីកការផ្តល់ឥណទាន ការផ្សព្វផ្សាយនិងរកទីផ្សារសម្រាប់ផលិតផល ការសម្រួលពាណិជ្ជកម្ម និងភស្តុភារ និងការបង្កើនសមត្ថភាពកែច្នៃ សុទ្ធសឹងជាកត្តាដ៏សំខាន់សម្រាប់ការអភិវឌ្ឍវិស័យកសិកម្មទាំងមូល។

# គន្ថនិទ្ទេស

Abbott, C. Philip, Christopher Hurt & Wallace E. Tyner (2011), "What's Driving Food Prices in 2011?" (Oak Brook, IL: Farm Foundation)

Alston, M. Julian, Kenneth A. Foster & Richard D. Gree (1994), "Estimating Elasticities with the Linear Approximate Almost Ideal Demand System: Some Monte Carlo Results", *Review of Economics and Statistics,* 76(2), pp. 351–356

Arndt, Channing, Rui Benfica, Nelson Maximiano, Antonio M. D. Nucifora & James T. Thurlow (2008), "Higher Fuel and Food Prices: Impacts and Responses for Mozambique", *Agricultural Economics,* 39(1), pp. 497–511

ADB–Asian Development Bank (2011), *Global Food Price Inflation and Developing Asia* (Manila: ADB)

Barrett, B. Christopher & Paul A. Dorosh (1996), "Farmers' Welfare and Changing Food Prices: Nonparametric Evidence from Rice in Madagascar", *American Journal of Agricultural Economics,* 78(3), pp. 656–669

Bhundia, Ashok (2002), *An Empirical Investigation of Exchange Rate Pass-Through in South Africa*, IMF Working Paper No. 02/165 (Washington, DC: International Monetary Fund)

Budd, W. John (1993), "Changing Food Prices and Rural Welfare: A Nonparametric Examination of the Côte d'Ivoire", *Economic Development and Cultural Change,* 41(3), pp. 587–603

CDRI–Cambodia Development Resource Institute (2002), *Cambodia's Annual Economic Review* (Phnom Penh: CDRI)

Chan Sophal (2009), "Impact of High Food Prices in Cambodia", *Annual Development Review 2008–09* (Phnom Penh: CDRI) pp. 39-64

Deaton, Angus (1989), "Rice Prices and Income Distribution in Thailand: A Non-parametric Analysis", *Economic Journal,* 99(395), pp. 1–37

Duma, Nombulelo (2008), *Pass-Through of External Shocks to Inflation in Sri Lanka*, IMF Working Paper No. 08/78 (Washington, DC: International Monetary Fund)

Hay Sovuthea (forthcoming), "Government Response to Inflation Crisis and Global Financial Crisis" (Phnom Penh: CDRI)

IFAD–International Fund for Agricultural Development (2011), "Policy Responses to the Food Price Crisis and Their Implications: The Case of Four Greater Mekong Subregion Countries", IFAD Occasional Paper (Rome: IFAD)

ILO–International Labour Organisation (2006), "Decent Work for Women and Men in the Informal Economy: Profile and Good Practices in Cambodia" (Bangkok; Phnom Penh: ILO)

Ivanic, Maros & Will Martin (2008), "Implications of High Global Food Prices for Poverty in Low-income Countries", *Agricultural Economics*, 39 (1), pp. 405–416

Klytchnikova, Irina & Ndiame Diop (2006), *Trade Reforms, Farm Productivity, and Poverty in Bangladesh*, Policy Research Working Paper Series No. 3980 (Washington, DC: World Bank)

McCarthy, Jonathan (2007), "Pass-Through of Exchange Rates and Import Prices to Domestic Inflation in Some Industrialized Economies", *Eastern Economic Journal*, 33 (4), pp. 511–537

Minot, Nicholas & Francesco Goletti (2000), *Rice Market Liberalization and Poverty in Vietnam*, International Food Policy Research Institute Research Report 114 (Washington, DC: IFPRI)

Tong Kimsun (2009), "How Did Cambodian Rural Households Cope with Shocks from Food and Oil Price Increases?" *Annual Development Review 2009–10* (Phnom Penh: CDRI) pp. 69-80

UNICEF–United Nations International Children's Fund (2008), *Cambodia Anthropometrics Survey Report* (Phnom Penh: UNICEF)

-៦-

# ការសម្រាលផលប៉ះពាល់នៃវិបត្តិហិរញ្ញវត្ថុសាកល ទៅលើទីផ្សារពលកម្មនៅជនបទកម្ពុជា

*ដោយលោក ហ៊ីង វុត្ថា*[១]

## ៦.១ សេចក្តីផ្តើម

ក្នុងចំណោមផលប៉ះពាល់ជាច្រើន[២] បង្កដោយវិបត្តិហិរញ្ញវត្ថុសាកលឆ្នាំ២០០៨ ទៅលើសេដ្ឋកិច្ចកម្ពុជា ផលប៉ះពាល់លើទីផ្សារពលកម្មមានលក្ខណៈគួរឲ្យបារម្ភជាពិសេស។ ការបាត់បង់ការងារមួយចំនួនធំ ការថយចុះប្រាក់ឈ្នួលកម្លាំងពលកម្ម និងលក្ខខណ្ឌការងារកាន់តែអន់ឡើង ជាផលវិបាកគួរឲ្យបារម្ភបំផុតចំពោះទីផ្សារពលកម្ម។ វិបត្តិនេះអាចជះឥទ្ធិពលទៅដល់សេដ្ឋកិច្ចនៅជនបទ ប៉ុន្តែមកទល់បច្ចុប្បន្ន មិនទាន់មានការស្រាវជ្រាវណាមួយដែលបង្ហាញភស្តុតាងពី ផលប៉ះពាល់ទៅលើទីផ្សារពលកម្មនៅជនបទនោះទេ។ អត្ថបទសង្ខេបនេះ មានគោលដៅពីរៈ ១) បង្ហាញភស្តុតាងពីផលប៉ះពាល់នៃវិបត្តិហិរញ្ញវត្ថុសាកលទៅលើទីផ្សារពលកម្មនៅជនបទ និង ២) ផ្តល់មតិពីចម្លើយតបខាងគោលនយោបាយ ដើម្បីសម្រាលផលប៉ះពាល់អវិជ្ជមានពីវិបត្តិ។

## ៦.២ វិបត្តិ និងឥទ្ធិពលលើទីផ្សារពលកម្មនៅជនបទ

នៅពេលទីផ្សារពលកម្មនៅទីក្រុង រងផលប៉ះពាល់ធ្ងន់ធ្ងរពីវិបត្តិហិរញ្ញវត្ថុសាកល ក្នុងទិដ្ឋភាពផ្សេងៗ ដូចជា ការកាត់បន្ថយការងារ ការលុបចោលការងារបន្ថែមម៉ោង និងការថយចុះប្រាក់ឈ្នួលនោះ ទីផ្សារពលកម្មនៅជនបទហាក់ទទួលរងតិចតួចណាស់នូវឥទ្ធិពលវាលដាលចេញពីវិបត្តិ។ ក្រៅពីមានការថយចុះប្រាក់ឈ្នួលពិត និងកំណើនអត្រាកុមារចូលរួមបម្រើការងារ ឥទ្ធិពលផ្សេងទៀតលើទីផ្សារពលកម្ម ច្រើនតែគ្មានពាក់ព័ន្ធនឹងវិបត្តិទេ។

## ៦.៣ ឥទ្ធិពលលើអត្រាចូលរួមបម្រើការងារ

ស្ថិតិបែបពិពណ៌នាដែលប៉ាន់ស្មានពី ប្រូបាប៊ីលីតេនៃការចូលរួមបម្រើការងារ និងដែលប្រើប្រាស់ម៉ូដែល Logistic regression បង្ហាញថា អត្រាចូលរួមបម្រើការងារនៅក្នុងទីផ្សារពលកម្មនៅជនបទ បានកើនឡើងក្នុងអំឡុងពេលមានវិបត្តិ[៣]។ ទាំងបុរស និងស្ត្រី បានចូលរួមកាន់តែច្រើនក្នុងទីផ្សារពលកម្ម ប៉ុន្តែស្ត្រីបានចូលរួមច្រើនជាងបុរស។ និន្នាការកើនឡើងនេះ អាច

[១] លោក ហ៊ីង វុត្ថា ជាអ្នកស្រាវជ្រាវកម្មវិធីសេដ្ឋកិច្ច ពាណិជ្ជកម្ម និងសហប្រតិបត្តិការក្នុងតំបន់ នៅវិទ្យាស្ថាន CDRI។

[២] នៅពេលវិបត្តិផ្ទុះឡើង កំណើនសេដ្ឋកិច្ចយ៉ាងលឿនរបស់កម្ពុជា ក៏ត្រូវគាំងដំណើរការ។ វិស័យជំរុញកំណើនសំខាន់ៗ ដូចជា ផ្នែកកាត់ដេរសម្លៀកបំពាក់ និងគ្រឿងសម្រាប់ពាក់នៅជើង ទេសចរណ៍ ការសាងសង់ និងអចលនទ្រព្យ ទទួលរងការប៉ះទង្គិចធ្ងន់ធ្ងរ ហើយកំណើនសេដ្ឋកិច្ចធ្លាក់ទាបបំផុតមកត្រឹម ០,១% នៅឆ្នាំ២០០៩។

[៣] អត្រានេះ កើនពី ៨២,៥% នៅមុនពេលមានវិបត្តិ រហូតដល់ ៨៥,៦% ហើយបន្ទាប់មក ធ្លាក់ទាបបន្តិចជាងកម្រិតមុនពេលមានវិបត្តិ មកត្រឹម ៨១,០% នៅឆ្នាំ២០១១។

បកស្រាយបានតាមកត្តា ៣ គឺៈ ១) ស្ត្រីរៀបការហើយមាននិន្នាការផ្លាស់ប្តូរពីការងារនៅផ្ទះគ្មានប្រាក់កម្រៃ ទៅចូលរួមក្នុងសកម្មភាពរកប្រាក់ចំណូល[៤] ២) មានកុមារ (អាយុ ១០-១៤ឆ្នាំ) កាន់តែច្រើនទៅចូលរួមក្នុងទីផ្សារពលកម្ម[៥] និង ៣) ការត្រឡប់ចូលស្រុកវិញ (ឈប់ពីការងារ និងជនចំណាកស្រុកត្រឡប់ពីទីក្រុងទៅភូមិកំណើតវិញ)។ កំណើនអត្រាកុមារចូលរួមក្នុងទីផ្សារពលកម្មជាក្តីបារម្ភមួយចំពោះកិច្ចខិតខំប្រឹងប្រែងកាត់បន្ថយពលកម្មកុមារ និងចំពោះឥទ្ធិពលទៅលើការអប់រំនិងសុខភាពរបស់កុមារ។ ចំពោះរចនាសម្ព័ន្ធនៃការងារវិញ ក្នុងពេល និងក្រោយពេលកើតវិបត្តិ មានការប្រែប្រួលកើនការងារក្នុងវិស័យកសិកម្ម ប៉ុន្តែកំណើននេះមិនសូវច្រើនទេ។

## ៦.៤ ឥទ្ធិពលលើប្រាក់ចំណូល

វិបត្តិបានប៉ះពាល់លើប្រាក់ចំណូលមធ្យមប្រចាំថ្ងៃ ក្នុងគ្រប់វិស័យ។ មុនពេលមានវិបត្តិ ប្រាក់ចំណូលប្រចាំថ្ងៃពិត មានជាមធ្យម ៤,០១ដុល្លារ ហើយបានធ្លាក់ចុះ ២០% មកត្រឹម ៣,១៤ ដុល្លារ នៅឆ្នាំ២០០៩ រួចទើបកើនឡើងវិញដល់ ៣,៤៦ដុល្លារ នៅឆ្នាំ២០១១។ ដោយសារប្រជាជនក្រីក្រភាគច្រើនរកចិញ្ចឹមជីវិតតាមការលក់ពលកម្មប្រចាំថ្ងៃ ដូច្នេះមានជីវភាពងាយរងគ្រោះខ្លាំងណាស់ ដែលអាចជះឥទ្ធិពលមិនល្អទៅលើចំណាយប្រើប្រាស់ និងសន្តិសុខស្បៀងរបស់ពួកគេ។

## ៦.៥ ឥទ្ធិពលលើចំណាកស្រុក

ចំណាកស្រុកឆ្លងកាត់ព្រំដែន បានថយចុះគួរកត់សំគាល់ ពីមុនពេល ដល់ក្រោយពេលមានវិបត្តិ។ ពលករចំណាកស្រុក មានដល់ ៦,០៥% នៃកម្លាំងពលកម្មក្នុងស្រុកសរុបនៅឆ្នាំ ២០០៨ ហើយធ្លាក់មកត្រឹម ៣,៦១% នៅឆ្នាំ២០០៩ និង ២,៧៦% នៅឆ្នាំ២០១១។ ប្រាក់ផ្ញើទៅផ្ទះ ក៏ធ្លាក់ចុះខ្លាំងដែរ ទាំងចំនួនទឹកប្រាក់ និងតួលេខប្រៀបធៀប។ ប្រាក់ផ្ញើទៅផ្ទះជាមធ្យមពីជនចំណាកស្រុកនៅបរទេស សម្រាប់មួយគ្រួសារទទួលផល មានដល់ ៨៣,៦៦ដុល្លារ នៅឆ្នាំ២០០៨ ប៉ុន្តែវាថយចុះអស់ ៨២,៤% មកត្រឹម ១៤,៦៩ដុល្លារ នៅឆ្នាំ២០០៩ រួចទើបកើនឡើងវិញដល់ ៣៨,៤១ដុល្លារ នៅឆ្នាំ២០១១។ ដោយសារប្រាក់ផ្ញើទៅផ្ទះ វាជាប្រភពចំណូលចម្បងសម្រាប់គ្រួសារជាច្រើន ដូច្នេះការធ្លាក់ចុះនេះ បានប៉ះពាល់យ៉ាងខ្លាំងដល់ជីវភាពរស់នៅរបស់ពួកគេ។

## ៦.៦ គោលនយោបាយឆ្លើយតប

ភស្តុតាងខាងលើ បានជួយដាស់ស្មារតីអំពីប្រភពគួរឲ្យបារម្ភនៃភាពងាយរងគ្រោះ មានជាអាទិ៍ ចំណាកស្រុកត្រឡប់មកវិញ និងការថយចុះប្រាក់ឈ្នួល។ ពិតហើយ រដ្ឋមិនគួរទប់ស្កាត់ចំណាកស្រុកត្រឡប់មកវិញ ឬក៏ត្រួតត្រាលើប្រាក់ឈ្នួលនោះទេ ប៉ុន្តែគួរប្រឹងប្រែងឲ្យពេញទំហឹង ដើម្បីកំណត់ទីតាំងបណ្តាគ្រួសារងាយរងគ្រោះបំផុត។ សម្រាប់គ្រួសារទាំងនោះ វិធានការរយៈពេលខ្លីមួយ អាចជាគម្រោងការ "ថ្លៃឈ្នួលការងារ" ដែលផ្តល់ឲ្យជនងាយរងគ្រោះម្នាក់ៗនូវការងារក្នុងការកែលំអ ជួសជុល និងកសាងហេដ្ឋារចនាសម្ព័ន្ធនៅមូលដ្ឋាន។ បទពិសោធន៍

---

[៤] ចំណែកនៃការធ្វើការងារផ្ទះរបស់ស្ត្រី បានធ្លាក់ចុះពី ៧,៨% នៅឆ្នាំ២០០៨ ដល់ ៦,៨% នៅឆ្នាំ២០០៩ និង ៣,៤% នៅឆ្នាំ២០១១។

[៥] អត្រាចូលរួមរបស់កុមារ កើនពី ៤៥,៥% នៅឆ្នាំ២០០៨ ដល់ ៤៧,៣% នៅឆ្នាំ២០០៩។

កន្លងមក បានផ្តល់គំនិតថា កម្មវិធីប្រភេទនេះអាចជាដំណោះស្រាយបណ្តោះអាសន្នដ៏សក្តិសិទ្ធិ ដោយមានឥទ្ធិពលវិជ្ជមានពីរ ពោលគឺ វាផ្តល់ចំណូលដល់គ្រួសារផង និងបង្កើតផលប្រយោជន៍ជាសាធារណៈផង។ វិធានការបណ្តោះអាសន្នមួយផ្សេងទៀត គឺការបង្កើនវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈដែលមានស្រាប់ ដោយផ្តោតលើ ជនចំណាកស្រុកត្រឡប់មកវិញ យុវជន/យុវនារីគ្មានការងារធ្វើ និងស្ត្រីភេទ រួចហើយជួយពួកគេឲ្យរកបានការងារធ្វើ។ នាបច្ចុប្បន្ន ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានបង្កើត មូលនិធិបណ្តុះបណ្តាលពិសេសមួយរួចហើយ ប៉ុន្តែកម្មវិធីបណ្តុះបណ្តាលភាគច្រើនដំណើរការតែនៅតាមទីក្រុងធំៗ រីឯការបណ្តុះបណ្តាលផ្អែកលើសហគមន៍នៅខ្វះខាតជាខ្លាំង។

ក្តីព្រួយបារម្ភមួយទៀត គឺកំណើនពលកម្មកុមារ។ បញ្ហានេះហុចលទ្ធផលមិនល្អទេ ដូច្នេះគួរកែតម្រូវតាមរយៈអន្តរាគមន៍គោលនយោបាយដ៏សមស្រប។ កម្មវិធីមានស្រាប់ជាអាហារូបករណ៍សម្រាប់ជនក្រីក្រ ទំនងមានប្រសិទ្ធភាពខ្លាំងក្នុងការជួយរក្សាឲ្យកុមារៗបាននៅរៀនសូត្រ ហើយកម្មវិធីនេះគួរពង្រីកឲ្យគ្របដណ្តប់លើសពីជនក្រីក្រទៅទៀត។ កម្មវិធីការពារកុមារ ក៏អាចជាការឆ្លើយតបប្រកបដោយប្រសិទ្ធភាពមួយដែរ។ ទោះបីប្រព័ន្ធសុវត្ថិភាពសង្គមមានស្រាប់នានា បានដោះស្រាយប្រភពភាពងាយរងគ្រោះមួយចំនួនក្តី ក៏អន្តរាគមន៍ជាច្រើនមិនបានទៅដល់ក្រុមប្រជាជនខ្លះឡើយ ហើយកម្មវិធីភាគច្រើន មានដែនគ្របដណ្តប់ភូមិសាស្ត្រតូច។ ដូច្នេះ ក្នុងរយៈពេលមធ្យម និងវែង ត្រូវមានដាក់អនុវត្តប្រព័ន្ធសុវត្ថិភាពសមស្រប ដែលផ្សារភ្ជាប់ទៅនឹងប្រភពភាពងាយរងគ្រោះ និងតំបន់ត្រូវការជំនួយ។ ការងារនេះត្រូវមានយុទ្ធសាស្ត្រលុនគ្នា និងគ្រប់ជ្រុងជ្រោយមួយ ដើម្បីដោះស្រាយបញ្ហាចម្បងៗផ្នែកហិរញ្ញវត្ថុ និងផ្នែកស្ថាប័ន និងជួយសម្របសម្រួលអន្តរាគមន៍ផ្សេងៗរវាងក្រសួង និងដៃគូអភិវឌ្ឍន៍នានា។ វត្តមាន យ៉ាងហោចណាស់បានត្រឹមកម្រិតស្រុកឬខេត្ត នូវទីភ្នាក់ងារផ្តល់ព័ត៌មានពីទីផ្សារ និងជួយរកការងារឲ្យធ្វើ ក៏អាចសម្រាលការប៉ះទង្គិចផ្សេងៗដល់ទីផ្សារពលកម្ម និងជួយបន្សឹតម្រូវការ ទៅនឹងការផ្គត់ផ្គង់ពលកម្មផងដែរ។

## ៦.៧ សន្និដ្ឋាន

ខ្លឹមសារសំខាន់បានពីអត្ថបទសង្ខេបនេះ គឺទីផ្សារពលកម្មនៅជនបទ ដើរតួនាទីជាដំណោះស្រាយចុងក្រោយសម្រាប់ជនចំណាកស្រុកត្រឡប់មកវិញ និងពលករនៅតាមទីក្រុងដែលត្រូវបានបញ្ឈប់ពីការងារ នៅពេលសេដ្ឋកិច្ចជួបការលំបាក។ ទោះបីវាជួយបង្កើនអត្រាចូលរួមបម្រើការងារក្តី ក៏កំណើនពលកម្មកុមារ និងការថយចុះប្រាក់ឈ្នួលនិងប្រាក់ផ្ញើទៅផ្ទះ គឺជាប្រភពចម្បងនៃភាពងាយរងគ្រោះដែរ។ អន្តរាគមន៍បណ្តោះអាសន្ននៅមានច្រើនទៀត ក្រៅពីអ្វីដែលបានរៀបរាប់នៅខាងលើ។ ដូចគ្នាដែរ យុទ្ធសាស្ត្រដ៏រលូន និងគ្រប់ជ្រុងជ្រោយស្តីពីប្រព័ន្ធសុវត្ថិភាព និងការការពារខាងសង្គមកិច្ច ព្រមទាំងយន្តការផ្តល់ព័ត៌មានទីផ្សារប្រកបដោយប្រសិទ្ធភាព គឺជាវិធានការរយៈពេលមធ្យម និងវែង សម្រាប់សម្រាលការប៉ះទង្គិចផ្សេងៗ ចំពោះសេដ្ឋកិច្ច និងជីវភាពនៅជនបទ។

## ឯកសារយោង

Hing Vutha (forthcoming), *The Global Financial Crisis and Its Impact on Rural Labour Market in Cambodia—Evidence from Nine Village Surveys* (Phnom Penh: Cambodia Development Resource Institute)

Kang Chandararot, Sina Sok & Dannet Liv (2009), *Rapid Assessment of the Impact of the Financial Crisis in Cambodia,* ILO Asia-Pacific Working Paper Series (Bangkok: International Labour Organisation)

-៧-

# ការវាយតម្លៃពីផលប្រយោជន៍នៃអង្គការកសិករ នៅលើផលិតភាពកសិកម្មៈ ភស្តុតាងបានពីអង្កេតគ្រួសារ នៅតំបន់ជនបទកម្ពុជា[១]

*ដោយលោកបណ្ឌិត ថេង វុទ្ធី, លោក កែវ សុជាតិ និង លោកស្រី ខៀវ ភិរម្យ*[២]

## ៧.១ សេចក្តីផ្តើម

### *៧.១.១ ប្រវត្តិដើម*

ប្រជាជនក្រីក្រនៅកម្ពុជា ជាង ៩០% រស់នៅតំបន់ជនបទ និងពឹងផ្អែកលើកសិកម្ម ជាប្រភពចម្បងសម្រាប់ការរស់នៅ។ វិស័យកសិកម្មកម្ពុជា ត្រូវបានសម្គាល់ជាសំខាន់ តាមការធ្វើកសិកម្មខ្នាតតូច ដោយប្រហែល ៨៤% នៃកសិករនៅទីជនបទ មានដីកសិកម្មតិចជាងមួយហិកតា។ វិស័យនេះ ស្ថិតក្នុងចំណោមសសរគ្រឹះធំៗទាំងបួននៃសេដ្ឋកិច្ចកម្ពុជា ដោយរួមចំណែកដល់ប្រហែល ៣៤% នៃ ផសស ក្នុងឆ្នាំ២០១០ (ស្ថិតិគណនីជាតិ ឆ្នាំ២០១១) និងកើនឡើងជាង ៥ ឯកតាភាគរយ ក្នុងឆ្នាំ ២០០៨, ២០០៩ និង ២០១០ ឬស្មើនឹង ២៧,៣% នៃ ផសស សរុប បើគិតតាមថ្លៃថេរឆ្នាំ២០០០។

ការស្រាវជ្រាវនាពេលថ្មីៗ បានកត់សម្គាល់នូវឧបសគ្គជាច្រើនដល់ការអភិវឌ្ឍកសិកម្ម នៅកម្ពុជា និងបញ្ហាប្រឈមផ្សេងៗដែលកសិករមានដីតូចៗកំពុងជួបប្រទះ មានជាអាទិ៍ ហេដ្ឋារចនាសម្ព័ន្ធអន់ខ្សោយ (ជាពិសេស ប្រព័ន្ធស្រោចស្រព និងហេដ្ឋារចនាសម្ព័ន្ធជនបទ) អសន្តិសុខកម្មសិទ្ធិដី លទ្ធភាពមិនគ្រប់គ្រាន់ក្នុងការទទួលបានបច្ចេកវិទ្យានិងសេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្ម លទ្ធភាពទាបក្នុងការទទួលបានឥណទាន ព័ត៌មានតិចតួចពីទីផ្សារ ការគ្រប់គ្រងគ្រោះធម្មជាតិនៅមានភាពទន់ខ្សោយ (ទឹកជំនន់ គ្រោះរាំងស្ងួត សត្វល្អិត/សត្វចង្រៃបំផ្លិចបំផ្លាញ) និងវិនិយោគសាធារណៈតិចក្នុងវិស័យកសិកម្ម។ ការសិក្សាមួយចំនួនលើកថា ដូចបានសង្កេតឃើញនៅប្រទេសកំពុងអភិវឌ្ឍឯទៀតដែរ កសិករខ្នាតតូចមិនមានលទ្ធភាពប្រើប្រាស់ប្រាក់កម្ចីប្រកបដោយប្រសិទ្ធភាពដើម្បីលើកកម្ពស់ផលិតភាព និងអំណាចរបស់ខ្លួនក្នុងការតថ្លៃជាមួយអ្នកទិញពីខាងក្រៅឡើយ ប្រសិនបើមិនមានការរៀបចំស្ថាប័នដើម្បីឲ្យពួកគាត់អាចបង្កើតជា អង្គការផលិតករជនបទនោះទេ (Couturier *et al.* 2006; Nou 2006; Bingen *et al.* 2003)។ ជាទូទៅ កសិករ

---

[១] អត្ថបទនេះ ដកស្រង់ចេញពីគម្រោងស្រាវជ្រាវស្តីពី "ការវាយតម្លៃពីផលប៉ះពាល់នៃអង្គការកសិករទៅលើសន្តិសុខស្បៀងរបស់ប្រជាជនក្រីក្រនៅតំបន់ជនបទ" ដែលទទួលហិរញ្ញប្បទានពី ធនាគារពិភពលោក និង AusAID។ ទស្សនៈ ដែលបានលើកឡើងនៅក្នុងអត្ថបទនេះ ជាគំនិតផ្ទាល់របស់អ្នកនិពន្ធ និងមិនមែនជាទស្សនៈរបស់ CDRI ធនាគារពិភពលោក ឬ AusAID ទេ។ អ្នកនិពន្ធ សូមថ្លែងអំណរគុណដល់ធនាគារពិភពលោក AusAID និង CDRI ចំពោះការទ្រទ្រង់ដល់ការសិក្សានេះ។

[២] បណ្ឌិត ថេង វុទ្ធី ជាអ្នកស្រាវជ្រាវ និងជាអ្នកសម្របសម្រួល និង លោក កែវ សុជាតិ ជាអ្នកស្រាវជ្រាវ និងលោកស្រី ខៀវ ភិរម្យ ជាជំនួយការស្រាវជ្រាវ កម្មវិធីភាពក្រីក្រ កសិកម្ម និងការអភិវឌ្ឍជនបទ នៅ វិទ្យាស្ថាន CDRI។

កម្ពុជាម្នាក់ៗ មិនមានលទ្ធភាពដោះស្រាយចន្លោះខ្វះខាតដូចលើកឡើងនៅខាងលើទេ។ ដើម្បីលើកកម្ពស់ជីវភាពផលិតករខ្នាតតូច រដ្ឋាភិបាលកម្ពុជាមានទិសដៅអភិវឌ្ឍវិស័យកសិកម្ម ដូចមានចែងក្នុងយុទ្ធសាស្ត្រចតុកោណ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងយុទ្ធសាស្ត្រសម្រាប់វិស័យកសិកម្មនិងទឹក ដែលទទួលស្គាល់ និងផ្ដល់អាទិភាពដល់ ការជំរុញកសិកម្មខ្នាតតូច និងការបង្កើតអង្គការកសិករ ដែលជាគន្លឹះសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចជនបទ និងការកាត់បន្ថយភាពក្រីក្រ។

ការពិនិត្យលើឯកសារពាក់ព័ន្ធ បង្ហាញថា តាំងពីពេលរដ្ឋាភិបាលកម្ពុជាបានបញ្ជាក់ទទួលស្គាល់ FOs ជាគន្លឹះសំខាន់សម្រាប់ការអភិវឌ្ឍកសិកម្ម និងវិស័យឯកជននៅជនបទមក នៅមានការសិក្សាតិចតួចនៅឡើយអំពី ឥទ្ធិពលនៃ FOs ទៅលើជីវភាពនៅជនបទ។ ការសិក្សាមានស្រាប់នានាបានព្យាយាមកំណត់ពីស្ថានភាពនៃ FOs ដោយវាយតម្លៃពីចំនួនអង្គការ ប្រភេទអង្គការ ដំណើរការចុះបញ្ជី FOs បញ្ហាចម្បងៗដែល FOs សព្វថ្ងៃត្រូវប្រឈមមុខ កត្តាខាងក្នុងនិងខាងក្រៅដែលជះឥទ្ធិពលទៅលើជោគជ័យនៃ FOs ព្រមទាំងគោលនយោបាយ និងក្របខ័ណ្ឌច្បាប់ដែលត្រូវមានដើម្បីជំរុញការអភិវឌ្ឍ FO នៅកម្ពុជា (Couturier *et al.* 2006; Nou 2006; Bingen *et al.* 2010)។ ប៉ុន្តែសព្វថ្ងៃមិនទាន់មានការស្រាវជ្រាវពីកម្រិតដែល FOs ជះឥទ្ធិពលទៅលើជីវភាពកសិករតូចៗនៅតំបន់ជនបទកម្ពុជាទេ កុំថាឡើយដល់ការសិក្សាពីផលប៉ះពាល់ខុសៗគ្នានៃ FO ប្រភេទខុសៗគ្នា និងការទទួលស្គាល់សមាជិកតាមផ្លូវច្បាប់ដោយ FO។ ការយល់ដឹងកាន់តែប្រសើរពីឥទ្ធិពលនៃសមាជិកភាពក្នុង FO លើការបង្កើនចំណូល នឹងជួយពង្រីកចំណេះដឹងអំពីវិស័យ FO នៅកម្ពុជា អំពីអត្ថប្រយោជន៍ដែលសមាជិក FO ទទួលបាន និង បញ្ហាប្រឈមដែល FOs កំពុងជួបប្រទះ។ ការងារនេះ ជួយផ្ដល់ជាព័ត៌មានដល់ការរៀបចំគោលនយោបាយបច្ចុប្បន្ន និងផ្ដល់គំនិតពីមធ្យោបាយមានប្រសិទ្ធភាពនានាសម្រាប់ដោះស្រាយតម្រូវការរបស់ FOs និងជួយទ្រទ្រង់កសិករខ្នាតតូច ដើម្បីកាត់បន្ថយភាពក្រីក្រ។

### ៧.១.២ គោលបំណង

គោលបំណងសំខាន់នៃការវាយតម្លៃនេះ គឺ៖ ១) វិភាគពីចរិតលក្ខណៈគ្រួសារ ដែលកំណត់នូវការចូលរួមក្នុង FOs ២) វាយតម្លៃពីផលប៉ះពាល់នៃ FOs ទៅលើសន្តិសុខស្បៀង និងជីវភាពរបស់ប្រជាជនក្រីក្រនៅជនបទ ៣) ប្រើប្រាស់លទ្ធផលស្រាវជ្រាវជាក់ស្ដែង ដើម្បីផ្ដល់ជាអនុសាសន៍ជាក់លាក់ជួយកែលំអក្របខ័ណ្ឌច្បាប់ និងបទបញ្ញត្តិពាក់ព័ន្ធនឹង FOs។

### ៧.១.៣ វិធីសាស្ត្រ

សេចក្ដីលំអិតពី វិធីសាស្ត្រស្រាវជ្រាវ ក្របខ័ណ្ឌជ្រើសយកគំរូតាង ក្របខ័ណ្ឌវិភាគ និងសម្មតិកម្ម មានបង្ហាញជូននៅក្នុងអត្ថបទជាភាសាអង់គ្លេស។

## ៧.២ លទ្ធផលស្រាវជ្រាវជាក់ស្ដែង

### ៧.២.១ ការវិភាគពីចរិតលក្ខណៈនៃការចូលរួមក្នុង FOs

លទ្ធផលសិក្សា បង្ហាញពីទំនាក់ទំនងវិជ្ជមានរវាងអាយុមេគ្រួសារ ជាមួយនឹងទំនោរក្នុងការចូលរួមក្នុង FO។ ទោះយ៉ាងនេះក្ដី នៅពេលមេគ្រួសារមានអាយុកាន់តែច្រើនឡើងទៀត គាត់មិនសូវ

ចូលរួមក្នុង FO ទេ[៣] ។ បើពិនិត្យលើគំរូតាងរងវិញ ( ឧទាហរណ៍ ក្រុមកសិករៈFG, សមាគមកសិករៈ FA, សហករណ៍កសិកម្មៈ AC) លទ្ធផលសិក្សាបង្ហាញថា អាយុរបស់មេគ្រួសារ មានឥទ្ធិពល គួរឲ្យកត់សម្គាល់ ដូចក្នុងគំរូតាងរួមដែរ លើកលែងតែ គំរូតាងរងនៃសមាជិក FG ដែលក្នុងនោះ អាយុរបស់មេគ្រួសារមិនមានឥទ្ធិពលគួរកត់សម្គាល់ទៅលើការចូលរួមទេ ( មើលតារាង ៧.១ ) ។

តារាង ៧.១៖ ការគណនាពី ទំនោរសម្រាប់ការចូលរួមក្នុង FO ( Logit Estimation for Pooled Samples )[៤]

| អថេរឯករាជ្យ | FO | AC | FA | FG |
|---|---|---|---|---|
| អាយុមេគ្រួសារ | 0.134*** | 0.294*** | 0.1874** | 0.052 |
| អាយុមេគ្រួសារលើកជាការ៉េ | -0.0012** | -0.0026*** | -0.00178** | 0.0005 |
| ចំនួនឆ្នាំសិក្សារបស់ មេគ្រួសារ | 0.0347 | 0.1095* | 0.0661 | -0.027 |
| មេគ្រួសារ ចេះអាន និងសរសេរ | 0.381 | 0.636 | 0.260 | 0.528* |
| មេគ្រួសារ ជាបុរស | -1.025*** | -0.644 | -1.693*** | -0.653 |
| មេគ្រួសារ រៀបការរួច | 0.574 | -0.294 | 1.455*** | 0.357 |
| មេគ្រួសារ អត់ការងារធ្វើ | -0.606*** | -0.132 | -0.598** | -0.842*** |
| ទំហំគ្រួសារ | -0.440** | -0.571* | -0.531** | -0.309 |
| ទំហំគ្រួសារលើកជាការ៉េ | 0.0358** | 0.034 | 0.049** | 0.026 |
| អត្រាមនុស្សក្នុងបន្ទុក (អាយុពី ១៥-៦៥ឆ្នាំ) | 0.244 | 0.334 | 0.128 | 0.217 |
| កសិកម្មជាប្រភពចម្បងនៃចំណូលគ្រួសារ | 0.0526 | -0.119 | 0.2621 | -0.066 |
| លទ្ធភាពគ្រួសារក្នុងការប្រើប្រាស់កម្ចីក្នុង ១២ខែចុងក្រោយ | 0.688*** | 0.531* | 0.742*** | 0.782*** |
| សន្ទស្សន៍ទ្រព្យសកម្មកសិកម្មក្នុងគ្រួសារ | 0.182* | 0.182 | 0.172 | 0.162 |
| តម្លៃទ្រព្យសកម្មសរុប (មុនរៀល) | 0.00087*** | 0.00265*** | 0.000289 | 0.001 |
| តម្លៃទ្រព្យសកម្មលើកជាការ៉េ | $-3.26\times10^{-7}$*** | $-8.48\times10^{-7}$*** | $-1.15\times10^{-7}$ | 0.000 |
| អញ្ញត្តិថេរ | -3.107** | -8.965*** | -5.602*** | -2.071 |
| Pseudo $R^2$ | **0.0734** | **0.1653** | **0.1001** | **0.0608** |
| ចំនួនសង្កេតឃើញ | **695** | **445** | **470** | **510** |

សម្គាល់៖ មេគុណត្រូវបានផ្តល់ឲ្យ។ *មានភាពលំអៀងផ្នែកស្ថិតិនៅកម្រិត ១០% , ** មានភាពលំអៀងផ្នែកស្ថិតិនៅកម្រិត ៥%, *** មានភាពលំអៀងផ្នែកស្ថិតិនៅកម្រិត ១% ។

---

៣ ខ្សែកោងមានរាងជាអក្សរ U នៅត្រឹមអាយុ ៥៤ឆ្នាំ ដែលមានន័យថា មេគ្រួសារអាយុច្រើនជាង ៥៤ឆ្នាំ មិនទំនងចូលរួមក្នុង FO ឡើយ។

៤ នៅពេលដកអថេរឥណទានចេញ មិនមានសញ្ញាបង្ហាញការផ្លាស់ប្តូរអ្វីលើមេគុណរបស់អថេរផ្សេងទៀតទេ ហើយម៉ូដែលគណនា កាន់តែមានស្ថិរភាពជាងមុន។ ដូច្នេះ របាយការណ៍នេះក៏មានដាក់បញ្ចូលនូវការពិភាក្សាពីអថេរឥណទាន។

លទ្ធភាពគ្រួសារក្នុងការប្រើប្រាស់កម្ចី មានទំនាក់ទំនងវិជ្ជមានគួរកត់សម្គាល់ជាមួយនឹងទំនោរក្នុងការចូលរួមក្នុង FOs (គំរូតាងរួម និង គំរូតាងរង) ដែលបង្ហាញថា គ្រួសារដែលចូលរួមក្នុង FOs មានលទ្ធភាពច្រើនជាងមុនក្នុងការបានប្រើប្រាស់ឥណទាន។ ក្នុងការសិក្សានេះ ប្រហែល ៦៧% នៃសមាជិក FO ប្រាប់ថា ការសន្សំប្រាក់ និងការផ្តល់ឥណទាន ជាសកម្មភាពចម្បងរបស់ពួកគេ។ ទោះយ៉ាងនេះក្តី អ្នកចូលរួមក្នុងការពិភាក្សាតាមក្រុមស្នូល និងអ្នកផ្តល់ព័ត៌មានគន្លឹះ បានលើកថា បរិមាណប្រាក់កម្ចីផ្តល់ឲ្យមិនអាចបំពេញតាមតម្រូវការរបស់ខ្លួនទេ ប៉ុន្តែពួកគាត់ទទួលស្គាល់ថា កម្ចីរបស់ FO មិនមានលក្ខខណ្ឌស្មុគស្មាញច្រើន ហើយមានកាលកំណត់សងប្រាក់អាចបត់បែនបាន។ កម្ចីជាមធ្យមទទួលបានពី FO ក្នុងពេលសិក្សា មានទំហំប្រហែល ៣៤០.០០០រៀល។

លទ្ធផលសិក្សាជាក់ស្តែង បង្ហាញថា ការអប់រំរបស់មេគ្រួសារ (ពោលគឺ មូលធនមនុស្ស) មិនមានទំនាក់ទំនងជាមួយ ការចូលរួមក្នុង FO ទេ ហើយវាស៊ីគ្នានឹងលទ្ធផលសិក្សាតាមវិធីសាស្រ្តបែបគុណភាពដែលបង្ហាញថា ទាំងអ្នកមានចំណេះដឹងទាប និងអ្នកមានចំណេះដឹងខ្ពស់ អាចចូលរួមក្នុង FO បាន។ សម្រាប់អថេរសុខមាលភាពគ្រួសារវិញ វាមានទំនាក់ទំនងប្រូបាបប៊ីលីតេរាងជាអក្សរ U ជាមួយនឹងការចូលរួមក្នុង FO ហើយការគណនាបង្ហាញថា គ្រួសារដែលមានទ្រព្យសម្បត្តិសរុបខ្ពស់ជាង ១៣,៦លានរៀល (៣៣៥០ដុល្លារ) ហាក់មិនសូវចូលរួមក្នុង FO ទេ។

### ៧.២.២ ឥទ្ធិពលនៃការចូលរួមក្នុង FO ទៅលើជីវភាព

ផ្នែកនេះ បង្ហាញពីលទ្ធផលនៃ ឥទ្ធិពលប្រព្រឹត្តកម្មជាមធ្យម (Average treatment effect) នៃការចូលរួមក្នុង FO ទៅលើផលិតភាពដំណាំស្រូវ និងសត្វចិញ្ចឹម ដោយប្រើប្រាស់ទាំងវិធីសាស្រ្តផ្គូផ្គងជាមួយអ្នកនៅជិតខាងបំផុត (NN Matching) និង វិធីសាស្រ្ត Kernel Matching។ ការបកស្រាយរបស់យើងនេះ ផ្អែកតែទៅលើវិធីសាស្រ្ត Kernel Matching ប៉ុណ្ណោះ។ ម្យ៉ាងវិញទៀត ដើម្បីស្វែងយល់កាន់តែស៊ីជម្រៅពី ឥទ្ធិពលនៃការចូលរួមក្នុង FO ទៅលើផលិតភាពដំណាំស្រូវ និងសត្វចិញ្ចឹម យើងបានពិនិត្យទៅលើទាំងគំរូតាងរួម និងគំរូតាងរង (គឺមាន FG, FA, AC) ដើម្បីកំណត់ពីប្រភេទ FOs ដែលជះឥទ្ធិពលខ្លាំងទៅលើជីវភាពរស់នៅរបស់សមាជិក។

ក្នុងគំរូតាងរួម ទោះជាសមាជិក FO មានប្រាក់ចំណូលខ្ពស់ជាង អ្នកដែលមិនមែនជាសមាជិកក្តី ក៏ការចូលរួមក្នុង FO (សមាជិក FO) មិនមានឥទ្ធិពលគួរឲ្យកត់សម្គាល់ទេ ទៅលើតម្លៃ (ប្រាក់ចំណូល) នៃផលិតកម្មស្រូវ។ ប៉ុន្តែនៅកម្រិតគំរូតាងរង ការចូលរួមក្នុង AC មានឥទ្ធិពលវិជ្ជមានខ្លាំងទៅលើផលិតភាពស្រូវ។ សមាជិក AC បានចំណូលពីផលស្រូវជាមធ្យមប្រហែល ៣៧៦.៤០០រៀល/ហិកតា (៩២,៧០ដុល្លារ) ខ្ពស់ជាង ពួកអ្នកមិនមែនជាសមាជិក ហើយតួលេខនេះបង្ហាញថា គ្រួសារជាសមាជិក AC មានបច្ចេកទេសកសិកម្មល្អៗជាង (តារាង ៧.២)។

ទំនាក់ទំនងរវាងសមាជិកភាពក្នុង AC និង ផលិតភាពស្រូវ អាចបណ្តាលមកពី សមាជិក FO មានលទ្ធភាពប្រើប្រាស់សេវាបច្ចេកទេស ច្រើនជាង អ្នកមិនមែនជាសមាជិក។ ប្រហែល ៥៥% ទៅ ៧០% នៃ សមាជិក FO បានទទួលសេវាបណ្តុះបណ្តាល ដូចជា ក្នុងការជ្រើសរើសគ្រាប់ពូជ ការគ្រប់គ្រងជំងឺនិងសត្វចង្រៃ ការប្រើជីគីមី ការធ្វើជីកំប៉ុស និងបច្ចេកទេសដាំដុះស្រូវ ធៀបនឹង ត្រឹមតែ ៣០% នៃអ្នកមិនមែនជាសមាជិកប៉ុណ្ណោះ។ មូលហេតុមួយទៀត គឺក្នុងចំណោម FO ទាំងបីប្រភេទ ពួកសមាជិក AC មានលទ្ធភាពខ្ចីប្រាក់បានយ៉ាងច្រើន (២,៥១លានរៀល) បើធៀបនឹងអ្នកមិនមែនជាសមាជិក (១,៣៧លានរៀល) ដោយបង់អត្រាការប្រាក់ប្រហាក់ប្រហែលគ្នា គឺ ៣,២៤% សម្រាប់សមាជិក AC និង ៣,៥៥% សម្រាប់អ្នកមិនមែនជាសមាជិក។ ហេតុផលចម្បង

ដែលជំរុញឲ្យសមាជិកនៃ FO គ្រប់ប្រភេទ និង អ្នកមិនមែនជាសមាជិក ធ្វើការខ្ចីប្រាក់នោះ គឺ ដើម្បីវិនិយោគលើការងារកសិកម្ម។

តារាង ៧.២៖ ឥទ្ធិពលប្រព្រឹត្តកម្មជាមធ្យមនៃវិធីសាស្ត្រ PSM សម្រាប់ដំណាំស្រូវ

| អថេរ | NN Matching | | | Kernel matching | | |
|---|---|---|---|---|---|---|
| | ភាពខុសគ្នា (ATT) | T-stat | ប្រព្រឹត្តកម្ម/គំរូតាងសម្រាប់ធៀប (ចំនួន) | ភាពខុសគ្នា (ATT) | T-stat | ប្រព្រឹត្តកម្ម/គំរូតាងសម្រាប់ធៀប (ចំនួន) |
| **ចំណូលពីដំណាំស្រូវ/ហិកតា** (ម៉ឺនរៀល) | | | | | | |
| គំរូតាងរួម | 13.82 | 1.37 | 292/313 | 10.40 | 1.13 | 301/313 |
| - ក្រុមកសិករ | 0.24 | 0.02 | 129/313 | 2.03 | 0.17 | 134/313 |
| - សមាគមកសិករ | 19.49 | 1.28 | 87/313 | -2.68 | -0.2 | 92/313 |
| - សហករណ៍កសិកម្ម | 19.05 | 0.95 | 74/313 | 37.64 | 2.46** | 73/313 |

សម្គាល់ *, **, *** តំណាងឲ្យភាពលំអៀងខាងស្ថិតិនៅកម្រិត ១០% ៥% និង ១% រៀងគ្នា។
ATT សំដៅលើ ឥទ្ធិពលប្រព្រឹត្តិកម្មជាមធ្យម ទៅលើ ក្រុមរងប្រព្រឹត្តកម្ម

ជាមធ្យម សមាជិក FO រកចំណូលពីផលិតកម្មសត្វចិញ្ចឹមបានប្រហែល ៩០៥.៥០០រៀល/ឆ្នាំ (២២៣ដុល្លារ) ច្រើនជាងអ្នកមិនមែនជាសមាជិក ហើយលទ្ធផលគណនានេះ មានភាពលំអៀងខាងស្ថិតិនៅកំរិត ១០% (តារាង ៧.៣)។ បើគិតតាមក្រុមគំរូតាងរងវិញ លទ្ធផលគណនាបង្ហាញថាសមាជិកភាពក្នុង FA និង AC មានឥទ្ធិពលជាវិជ្ជមានលើប្រាក់ចំណូលដែលកសិករបានពីផលិតកម្មសត្វចិញ្ចឹម។ ភាពខុសគ្នាក្នុងប្រាក់ចំណូលបានពីសត្វចិញ្ចឹម នៃសមាជិក FA និង AC ធៀបនឹងអ្នកមិនមែនជាសមាជិក គឺ ប្រហែល ២.០៧៤.១០០រៀល (៥១០,៨៦ដុល្លារ) និង ១.៤៥៦.៥០០ រៀល (៣៥៨,៧៤ដុល្លារ) រៀងគ្នា ហើយលទ្ធផលនេះមានភាពលំអៀងខាងស្ថិតិនៅកម្រិត ១០% ប៉ុណ្ណោះ។

តារាង ៧.៣៖ ឥទ្ធិពលប្រព្រឹត្តិកម្មជាមធ្យមនៃវិធីសាស្ត្រ PSM សម្រាប់ការចិញ្ចឹមសត្វ

| អថេរ | NN Matching | | | Kernel matching | | |
|---|---|---|---|---|---|---|
| | ភាពខុសគ្នា (ATT) | T-stat | ប្រព្រឹត្តកម្ម/គំរូតាងសម្រាប់ធៀប (ចំនួន) | ភាពខុសគ្នា (ATT) | T-stat | ប្រព្រឹត្តកម្ម/គំរូតាងសម្រាប់ធៀប (ចំនួន) |
| **ចំណូលពីសត្វចិញ្ចឹម** | | | | | | |
| គំរូតាងរួម | 47.18 | 0.89 | 278/297 | 90.55 | 1.80* | 290/297 |
| - ក្រុមកសិករ | -68.22 | -1.53 | 122/297 | -20.81 | -0.54 | 128/297 |
| - សមាគមកសិករ | 232.67 | 1.91** | 87/297 | 207.41 | 1.84* | 90/297 |
| - សហករណ៍កសិកម្ម | -8.12 | -0.08 | 69/297 | 145.65 | 1.69* | 69/297 |

សម្គាល់ *, **, *** តំណាងឲ្យភាពលំអៀងខាងស្ថិតិនៅកម្រិត ១០% ៥% និង ១% រៀងគ្នា។
ATT សំដៅលើឥទ្ធិពលប្រព្រឹត្តិកម្មជាមធ្យមទៅលើក្រុមរងប្រព្រឹត្តកម្ម

លទ្ធភាពធំទូលាយជាងក្នុងការទទួលបានព័ត៌មានគួរឲ្យទុកចិត្ត និងការបណ្ដុះបណ្ដាលពីការចិញ្ចឹមសត្វ អាចជាមូលហេតុមួយនៃការទទួលបានចំណូលច្រើនជាង សម្រាប់គ្រួសារជាសមាជិក FO។ លទ្ធផលអង្កេត បង្ហាញថា ប្រហែល ៦៥% នៃគ្រួសារចូលជាសមាជិក FO មានលទ្ធភាពទទួលបានព័ត៌មានស្ដីពីបច្ចេកទេសចិញ្ចឹមសត្វ ធៀបនឹងត្រឹមតែ ៣០% ប៉ុណ្ណោះសម្រាប់គ្រួសារដែលមិនមែនជាសមាជិក។ អង្កេតនេះក៏បង្ហាញដែរថា សមាជិក FO បានទទួលជំនួយទ្រទ្រង់ផ្នែកបច្ចេកទេសពីទីភ្នាក់ងារ ដូចជា មន្ទីរកសិកម្មខេត្ត (PDA) និង NGOs ជាដើម។ ប្រភពចម្បងៗនៃចំណេះដឹងពីបច្ចេកទេសចិញ្ចឹមសត្វរបស់គ្រួសារមិនមែនជាសមាជិក FO គឺ អ្នកជិតខាង NGOs និងការសិក្សាដោយខ្លួនឯង ហើយចំណុចនេះបង្ហាញថា ពួកគេភាគច្រើនមានលទ្ធភាពទទួលបានបច្ចេកទេសចិញ្ចឹមសត្វ តិចតួចជាងគ្រួសារជាសមាជិក FO។

ជាទូទៅ ការចូលរួមក្នុង FOs មិនមានឥទ្ធិពលច្រើនគួរឲ្យកត់សម្គាល់ទៅលើផលិតកម្មស្រូវទេ ប៉ុន្តែមានទំនាក់ទំនងវិជ្ជមានជាមួយផលិតកម្មសត្វចិញ្ចឹម។ បើគិតតាមក្រុមគំរូតាងវង់វិញ សមាជិកភាពក្នុង AC មានឥទ្ធិពលវិជ្ជមានខ្ពស់ ទាំងទៅលើផលិតភាពស្រូវ និងផលិតកម្មសត្វចិញ្ចឹម រីឯសមាជិកភាពក្នុង FA មានទំនាក់ទំនងវិជ្ជមានខ្លាំង ជាមួយនឹងប្រាក់ចំណូលបានពីសត្វចិញ្ចឹម។ ទោះយ៉ាងនេះក្ដី យើងមិនអាចអះអាងថា AC ជាប្រភេទ FO ដែលមានជោគជ័យជាងគេនោះទេ ព្រោះការសម្ភាសជាមួយអ្នកផ្ដល់ព័ត៌មានគន្លឹះ ដូចជា តំណាងទីភ្នាក់ងារនានា (NGOs និង PDA) បានឲ្យដឹងថា AC មួយចំនួនបានវិវត្តចេញពី FGs ឬ FAs ដែលមានដំណើរការល្អ។

ការសិក្សារបស់ Bratton (1986), Bingen *etal.* (2003) និង Chirwa *etal.* (2005) បង្ហាញថា ដើម្បីឲ្យការចូលរួមក្នុងអង្គការផលិតករជនបទ ហុចផលល្អដល់ផលិតករតូចៗនៅជនបទនោះ FOs ត្រូវផ្ដល់សេវាសំខាន់បី ទៅឲ្យសមាជិករបស់ខ្លួន គឺ ការជួយមតិណែនាំនិងការបណ្ដុះបណ្ដាល លទ្ធភាពទទួលបានធាតុចូល និងលទ្ធភាពចូលក្នុងទីផ្សារ។ ប៉ុន្តែនៅកម្ពុជា FOs មិនបានផ្ដល់កញ្ចប់សេវាកម្មជាមូលដ្ឋានទាំងនេះឲ្យពេញលេញទេ។ លទ្ធផលអង្កេតបង្ហាញថា ភាគច្រើននៃសមាជិក FO ទទួលបានត្រឹមតែការណែនាំ ឬការបណ្ដុះបណ្ដាលពីទីភ្នាក់ងារនានាដែលជួយទ្រទ្រង់ពួកគេប៉ុណ្ណោះ។ ម្យ៉ាងទៀត ៧៦% នៃសមាជិក FO រាយការណ៍ថា លទ្ធភាពទទួលបានធាតុចូលមានការដោះស្រាយឲ្យជាលក្ខណៈបុគ្គល ហើយ ៨១% ប្រាប់ថា មិនបានទទួលជំនួយទ្រទ្រង់ផ្នែកទីផ្សារសម្រាប់ផលិតផលកសិកម្មរបស់គាត់ទេ។ ជាទូទៅ អត្ថប្រយោជន៍ដែលសមាជិកអាចទទួលបានពី FO គឺលទ្ធភាពប្រសើរជាងមុនក្នុងការទទួលបានសេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្ម។ ចំណុចនេះបង្ហាញថា FO នៅកម្ពុជា មិនទាន់រីកចម្រើនបានពេញលេញ និងផ្ដល់អត្ថប្រយោជន៍បានច្រើនដល់សមាជិករបស់ខ្លួនទេ។

## ៧.៣ សេចក្តីសន្និដ្ឋាន និងនាពជំពាក់ទាក់ទងផ្នែកគោលនយោបាយ

សរុបសេចក្ដីមក ភស្ដុតាងបានពីការសិក្សាជាក់ស្ដែង បង្ហាញថា ការចូលរួមរបស់ FO នៅក្នុងផលិតកម្មកសិកម្ម នៅមានកម្រិតនៅឡើយ។ កន្លងមក កំណើនក្នុងផលិតភាពកសិកម្ម ភាគច្រើនកើតមានឡើងតាមរយៈ ការប្រើប្រាស់បច្ចេកទេសល្អៗជាងមុនដែលទទួលបានជាចម្បងពីទីភ្នាក់ងារជួយទ្រទ្រង់នានា។ សកម្មភាពរួមគ្នា ក្នុងការទិញធាតុចូល និងលក់ផលិតផលកសិកម្ម គឺស្ទើរតែគ្មានសោះ ហើយសមាជិក FO នៅតែបន្តលក់ផលិតផលជាលក្ខណៈបុគ្គលរៀងៗខ្លួនទៅទីផ្សារ។ លទ្ធផលសិក្សាទាំងនេះបង្ហាញថា វិស័យ FO នៅកម្ពុជា កំពុងស្ថិតក្នុងដំណាក់កាលដំបូងនៃការអភិវឌ្ឍ ហើយត្រូវមានកិច្ចប្រឹងប្រែងច្រើនទៀត ដើម្បីញ៉ាំងឲ្យ ការចូលរួមក្នុង FOs កាន់តែ

មានអត្ថប្រយោជន៍ច្រើនសម្រាប់ជីវភាពរស់នៅ។ ការសិក្សានេះស្នើឡើងថាការគួបផ្សំគ្នានៃយុទ្ធសាស្ត្រអភិវឌ្ឍន៍ FO និងគម្រោងការនៃការធ្វើកសិកម្មតាមកិច្ចសន្យា អាចជួយឲ្យ FO មានដំណើរការយូរអង្វែង និងផ្តល់អត្ថប្រយោជន៍បានកាន់តែច្រើនដល់សមាជិកខ្លួន។

## ៧.៣.១ ភាពជំពាក់ទាក់ទងខាងគោលនយោបាយ

ដោយសារមានទំនាក់ទំនងជាវិជ្ជមានរវាង AC ជាមួយនឹង ផលិតភាពស្រូវនិងផលិតកម្មសត្វចិញ្ចឹម និងមាន គោលនយោបាយបច្ចុប្បន្នរបស់រាជរដ្ឋាភិបាលក្នុងការជំរុញការនាំចេញស្រូវតាមរយៈការអភិវឌ្ឍ FO នោះ បណ្តា FO ដែលមានស្រាប់ទាំងឡាយ គួរទទួលបានជំនួយគាំទ្រ និងការជំរុញឡើងថែមទៀត ព្រោះសព្វថ្ងៃដំណើការមិនទាន់បានពេញលេញល្អទេ។ ភស្តុតាងបានពីការសិក្សា បង្ហាញថា កំណើនផលិតកម្មកសិកម្មរបស់គ្រួសារនៅទីជនបទ មានទំនាក់ទំនងវិជ្ជមានជាមួយនឹង ACs ខ្លាំងជាង ជាមួយនឹង FG និង FA។ ប៉ុន្តែដោយសារ ACs វាវិវត្តចេញពី FGs ពីរប្រភេទផ្សេងទៀតដែលមានដំណើរការល្អនោះ ដូច្នេះគោលនយោបាយដែលបង្កើតឡើងគួរជួយទ្រទ្រង់ និងជំរុញទាំង ACs និង ក្រុមអង្គការកសិករប្រភេទផ្សេងៗទៀតផងដែរ។

## គន្ថនិទ្ទេស


Abaru, M.B., F. Nyakuni & G. Shone (2006), *Strengthening Farmer Organisations: RELMA's Experience in Eastern and Southern Africa,* ICRAF Working Paper 23 (Nairobi: World Agroforestry Centre)

Ali, A. & A. Abdulai (2010), "The Adaptation of Genetically Modified Cotton and Poverty Reduction in Pakistan", *Journal of Agricultural Economics*, 61(1), pp. 175-192

Bachke, M.E. (2010), *Do Farmers' Organizations Enhance the Welfare of Small-Scale Farmers?* Working Paper, Norwegian University of Life Sciences

Barham, J., & C. Chitemi (2009), "Collective Action Initiatives to Improve Marketing Performance: Lessons from Farmer Groups in Tanzania," *Food Policy* 34(1), pp. 53-59

Bernard, T. & D.J. Spielman (2009), "Reaching the Poor through Rural Producer Organizations? A Study of Agricultural Marketing Cooperatives in Ethiopia", *Food Policy*, 34(1), pp. 60-69

Bingen, J., A. Serrano & J. Howard (2003), "Linking Farmers to Markets: Different Approaches to Human Capital Development", *Food Policy,* 28(4), pp. 405-419

Bratton, Michael (1986), "Farmer Organisations and Food Production", *World Development*, 14(3), pp. 367-384

Caliendo, M. & S. Kopeinig (2008), "Some Practical Guidance for the Implementation of Propensity Score Matching", *Journal of Economic Surveys*, 22(1), pp. 31-72

Chea, S. (2010), Final Report on Policy Analysis for Farmer Organisation Development, Department of Agricultural Extension (Phnom Penh: MAFF, sponsored by IFAD and FAO)

Chirwa, E., A. Dorward, R. Kachule, I. Kumwenda, J. Kydd, N. Poole, C. Poulton & M. Stockbridge (2005), "Walking Tightropes: Supporting Farmer Organisations for Market Access", *Natural Resource Perspective*, Number 99 (London: ODI)

Couturier, J., Savun S.O. & Ham P. (2006), "Inventory of Farmer Organisations in Cambodia, Cambodia", report prepared for DAE/MAFF, Phnom Penh

Davis, K., Ephraim Nkony, E. Kato, D.A. Mekonnen, M. Orendo, R. Miiro & J. Nkuba (2010), "Impact of Farmer Field Schools on Agricultural Productivity and Productivity

and Poverty in East Africa", IFPRI Discussion Paper 00992 (Washington, DC: IFPRI)

NIS–National Institute of Statistics (2011), National Account of Cambodia 1993-2010, Bulletin No. 15 (Phnom Penh: NIS, MoP)

Markelova, H., R. Meinzen-Dick, J. Hellin & S. Dohrn (2009), "Collective Action for Smallholder Market Access", *Food Policy,* 34(1), pp. 1-7

Miyata, S., N. Minot & Hu D. (2009), "Impact of Contract Farming on Income: Linking Small Farmers, Packers and Supermarkets in China", *World Development*, 37(1), pp. 1781-1790

Ngin C. (2010), "Farmer Associations in Cambodia: Internal Functions and External Relations" (Chiang Mai: Regional Centre for Social Science and Sustainable Development, Chiang Mai University)

Nou Keosothea (2006), "Emerging Structure of Agricultural Cooperatives in Cambodia, *Cambodia Development Review,* 10(1) (Phnom Penh: CDRI)

Peacock, C., A. Jowett, A. Dorward, C. Poulton & I. Urey (2004), "Reaching the Poor, a Call for Action: Investment in Small Agriculture in sub-Saharan Africa", FARM Africa, Harvest Help and Centre for Development and Poverty Reduction, Imperial College, London

Pretty, J.N. (2003), "Social Capital and the Collective Management of Resources", *Science,* 302, pp. 1912-1915

Theng V. & Koy R. (2011), "Review of Agricultural Policy and Policy Research", Policy Discussion Paper (Phnom Penh: CDRI)

Theng V., K. Socheat, N. Keosothea, S. Sreymom & K. Pirom (2013 forthcoming), *Impact of Farmer Organisations on Food Security: The Case of Rural Cambodia,* CDRI Working Paper Series (Phnom Penh: CDRI)

Thorp, R., F. Stewart & A. Heyer (2005), "When and How Far is Group Formation a Route out of Chronic Poverty?" *World Development,* 33(6), pp. 907-920

World Bank (2005), *Cambodia Rural Sector Strategy Note: Towards a Strategy for Rural Growth and Poverty Reduction* (Washington, DC: World Bank)

World Bank (2009a), *Poverty Profile and Trends in Cambodia: Findings from the 2007 Cambodia Economic Survey (CSES)* (Washington, DC: World Bank)

World Bank (2009b), *Sustaining Rapid Growth in a Challenging Environment: Cambodia Country Economic Memorandum* (Phnom Penh: World Bank)

# បញ្ជីឯកសារពិភាក្សារបស់វិទ្យាស្ថាន វបសអ

រាល់ឯកសារបោះពុម្ពផ្សាយរបស់វិទ្យាស្ថាន វបសអ-CDRI
អាចយកប្រើបាន ដោយឥតគិតថ្លៃតាមរយៈគេហទំព័រ www.cdri.org.kh

២៧. យឹម ជា និង Bruce McKenney (ធ្នូ ២០០៣) *ការនាំចេញត្រីពីបឹងទន្លេសាបទៅប្រទេសថៃ៖ការវិភាគលើការរាំងស្ទះពាណិជ្ជកម្មអភិបាលកិច្ចនិងបរិយាកាសសម្រាប់ការលូតលាស់* ជាភាសាខ្មែរ និង ជាភាសាអង់គ្លេស។

២៨. ព្រុំ តុលា និង Bruce McKenney (ធ្នូ ២០០៣) *ការធ្វើពាណិជ្ជកម្មផលព្រៃឈើនៅកម្ពុជា៖ ការប្រឈម ការគំរាមកំហែង និងឱកាសសម្រាប់ពាណិជ្ជកម្មជ័រទឹក* ជាភាសាខ្មែរ និង ជាភាសាអង់គ្លេស។

២៩. យឹម ជា និង Bruce McKenney (វិច្ឆិកា ២០០៣) *ពាណិជ្ជកម្មត្រីក្នុងស្រុក៖ ករណីសិក្សានៃម៉ាឃីទីងត្រីពីបឹង ទន្លេសាបទៅក្រុងភ្នំពេញ* ជាភាសាខ្មែរ និង ជាភាសាអង់គ្លេស។

៣០. Caroline Hughes និងគឹម សេតារា (មិថុនា ២០០៤) *ការវិវត្តន៍នៃដំណើរការប្រជាធិបតេយ្យ និងការគ្រប់គ្រង ទំនាស់នៅកម្ពុជា៖ ការសិក្សាប្រៀបធៀបការបោះឆ្នោតបីលើកនៅកម្ពុជា* ជាភាសាខ្មែរ និង ជាភាសាអង់គ្លេស។

៣១. Robert Oberndorf (កក្កដា ២០០៤) *សុខដុមនីយកម្មច្បាប់ទាក់ទងនឹងដំណើរការវិមជ្ឈការនៅកម្ពុជា* ជាភាសាខ្មែរ និង ជាភាសាអង់គ្លេស។

៣២. K. A. S. Murshid និង ទួត-សុខផល្លី (ឧសភា ២០០៥) *សេដ្ឋកិច្ចឆ្លងកាត់ព្រំដែនរបស់ប្រទេសកម្ពុជា៖ ការសិក្សាជំហានដំបូង* ជាភាសាខ្មែរ និង ជាភាសាអង់គ្លេស។

៣៣. Hansen, Kasper K. និង តុប-នេត (ធ្នូ ២០០៦) *Natural Forest Benefits and Economic Analysis of Natural Forest Conversion in Cambodia* ជាភាសាអង់គ្លេស

៣៤. ប៉ក់ គឹមជឿន, ហ៊ាង វុទ្ធី, អេង នេត្រា, អាន សុវត្ថា, គឹម សេតារា, Jenney Knowles និង David Craig (មីនា ២០០៧) *Accountability and Neo-patrimonialism in Cambodia: A Critical Literature Review* ជាភាសាអង់គ្លេស។

៣៥. គឹម-សេតារា និង Joakim Öjendal (ឧសភា ២០០៧) *Where Decentralisation Meets Democracy: Civil Society, Local Government, and Accountability in Cambodia* ជាភាសាអង់គ្លេស

៣៦. លឹម-សុវណ្ណារា (វិច្ឆិកា ២០០៧) *ចំណាកស្រុករបស់យុវជន និងនគរូបនីយកម្ម នៅប្រទេសកម្ពុជា* ជាភាសាខ្មែរ និង ជាភាសាអង់គ្លេស។

៣៧. ចែម ផល្លា និងអ្នកឯទៀត (ឧសភា ២០០៨), *Framing Research on Water Resources Management and Governance in Cambodia: A Literature Review* ជាភាសាអង់គ្លេស

៣៨. ប៉ក់ គឹមជឿន និង David Craig, *Accountability and Public Expenditure Management in Decentralised Cambodia* ជាភាសាអង់គ្លេស

៣៩. ហ៊ាង វុទ្ធី និង David Craig, *Accountability and Planning in Decentralised Cambodia* ជាភាសាអង់គ្លេស

៤០. អេង នេត្រា និង David Craig, *Accountability and Human Resource Management in Decentralised Cambodia* ជាភាសាអង់គ្លេស

៤១. ហ៊ីងវុត្ថា និង Hossein Jalilian (មេសា ២០០៩) *ផលប៉ះពាល់នៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ចិន ចំពោះបរិស្ថាន នៅតាមបណ្តាប្រទេសក្នុងមហាអនុតំបន់មេគង្គ* ជាភាសាខ្មែរ និង ជាភាសាអង់គ្លេស។

៤២. ធន់ វិមាលា, អ៊ូ ស៊ីវហួច, អេង នេត្រា និង លី តឹម (តុលា ២០០៩), *Leadership in Local Politics of Cambodia: A Study of Leaders in Three Communes of Three Provinces* ជាភាសាអង់គ្លេស

៤៣. ហ៊ីងវុត្ថា និង បណ្ឌិត ធន់វឌ្ឍនា (ធ្នូ ២០០៩) *ពាណិជ្ជកម្មកសិកម្មក្នុងមហាអនុតំបន់មេគង្គៈ ករណីដំឡូងឈើ និងកៅស៊ូ នៅកម្ពុជា* ជាភាសាខ្មែរ និង ជាភាសាអង់គ្លេស។

៤៤. ច័ន្ទ សុផល (ធ្នូ ២០០៩) *ផលប្រយោជន៍និងចំណាយនៃទេសន្តរប្រវេសន៍កំលាំងពលកម្មក្នុងមហាអនុតំបន់មេគង្គៈ ករណីសិក្សានៅប្រទេសកម្ពុជា* ជាភាសាខ្មែរ និង ជាភាសាអង់គ្លេស។

៤៥. CDRI Publication (December 2009), *Costs and Benefits of Cross-country Labour Migration in the GMS: Synthesis of the Case Studies in Thailand, Cambodia, Laos and Vietnam*

៤៦. CDRI Publication (December 2009), *Agricultural Trade in the Greater Mekong Sub-region: Synthesis of the Case Studies on Cassava and Rubber Production and Trade in GMS Countries*

៤៧. ជា ជូ (សីហា ២០១០) *The Local Governance of Common Pool Resources: The Case of Irrigation Water in Cambodia*

៤៨. CDRI Publication (August 2010), *Empirical Evidence of Irrigation Management in the Tonle Sap Basin: Issues and Challenges*

៤៩. ចែម ផល្លា និង សុមេធ ប៉ារ៉ាឌី (មីនា ២០១១), *ការប្រើប្រាស់ចំណេះដឹងជលសាស្ត្រនៃអាងស្តឹង និងការចូលរួមរបស់សហគមន៍ ដើម្បីលើកកម្ពស់ការធ្វើសេចក្តីសម្រេចចិត្តប្រកបដោយការចូលរួម ស្តីពីការបែងចែកទឹកសម្រាប់ស្រោចស្រព* ជាភាសាខ្មែរ និង ជាភាសាអង់គ្លេស។

៥០. ប៉ក់ គឹមជឿន (ឧសភា ២០១១) *វិមជ្ឈការហិរញ្ញវត្ថុនៅកម្ពុជា៖ ការងារសម្រេចបាន និងជំហានបន្ទាប់។*

៥១. Christopher Wokker, Paulo Santos, រស់ បានសុខ និង Kate Griffiths (June 2011), *Irrigation Water Productivity in Cambodian Rice System* ជាភាសាអង់គ្លេស

៥២. អ៊ុច ច័ន្ទតារ៉ានី, សាំង ច័ន្ទហង្ស និង ផាន់ ដាលីស (មិថុនា ២០១១), *ការវាយតម្លៃផលប៉ះពាល់នៃប្រទេសចិន លើការកាត់បន្ថយភាពក្រីក្រនៅមហាអនុតំបន់ទន្លេមេគង្គៈ ករណីសិក្សាប្រទេសកម្ពុជា* ជាភាសាខ្មែរ និង ជាភាសាអង់គ្លេស។

៥៣. ច័ន្ទ សុភក្តិ, Nathan Wales and Tim Frewer (សីហា ២០១១), *An Investigation of Land Cover and Land Use Change in Stung Chrey Bak Catchment, Cambodia* ជាភាសាអង់គ្លេស

៥៤. ណាំង ភិរុណ, ខៀវ ដារ៉ាវី, Philip HIRSCH និង Isabelle WHITEHEAD (កក្កដា ២០១១) *លើកកម្ពស់អភិបាលកិច្ចធនធានទឹកនៅកម្ពុជា៖ ការវិភាគអ្នកពាក់ព័ន្ធ* ជាភាសាខ្មែរ និង ជាភាសាអង់គ្លេស។
៥៥. កឹម សុធន, ឈឹម ឈន់, ថេង វុទ្ធី និង សូ សុវណ្ណារិទ្ធ (កក្កដា ២០១១) *Policy Coherence in Agricultural and Rural Development: Cambodia* ជាភាសាអង់គ្លេស
៥៦. តុង គឹមស៊ុន, ហែម សុចិត្រ និង Paulos Santos (កក្កដា ២០១១), *What Limits Agricultural Intensification in Cambodia? The role of emigration, agricultural extension services and credit constraints* ជាភាសាអង់គ្លេស
៥៧. Tong Kimsun, Hem Socheth and Paulos Santos (August 2011), *The Impact of Irrigation on Household Assets* ជាភាសាអង់គ្លេស
៥៨. ហ៊ីង វុត្ថា, លន់ ពិដេ និង ផាន់ ដាលីស (សីហា ២០០១) *ទេសន្តរប្រវេសន៍មិនស្របច្បាប់ពីកម្ពុជា* ជាភាសាខ្មែរ និង ជាភាសាអង់គ្លេស។
៥៩. ចែម ផល្លា, Philip Hirsch និង សុមេធ ប៉ារាឌី (កញ្ញា ២០០១), *Hydrological Analysis in Support of Irrigation Management: A Case Study of Stung Chrey Bak Catchment, Cambodia* ជាភាសាអង់គ្លេស
៦០. សាំង ច័ន្ទហង្ស, ហែម សុចិត្រ និង អ៊ួច ច័ន្ទតារានី ជាមួយ ផាន់ ដាលីស និង ប៊ុន ដូរីណា (កញ្ញា ២០១១) *Foreign Investment in Agriculture in Cambodia* ជាភាសាអង់គ្លេស
៦១. រស់ បណ្ណែត, លី តឹម និង Anna Thompson (កញ្ញា ២០០១), *Catchment Governance and Cooperation Dilemmas: A Case Study from Cambodia* ជាភាសាអង់គ្លេស
៦២. ជា ជូ, ណាំង ភិរុណ, Isabelle Whitehead, Phillip Hirsch and Anna Thompson (តុលា ២០១១), *Decentralised Governance of Irrigation Water in Cambodia: Matching Principles to Local Realities* ជាភាសាអង់គ្លេស និងខ្មែរ
៦៣. ហេង សីហា, គឹម សេដារា និង សូ សុខប៊ុនធឿន (តុលា ២០១១), *Decentralised Governance in Hybrid Polity: Localisation of Decentralisation Reform in Cambodia* ជាភាសាអង់គ្លេស
៦៤. តុង គឹមស៊ុន និង ស្រ៊ី បុប្ផារ័ត្ន (វិច្ឆិកា ២០១១), *Poverty and Evironment Links: The Case of Rural Cambodia* ជាភាសាអង់គ្លេស
៦៥. រស់ បានសុខ, ណាំង ភិរុណ និង ឈឹម ឈន់(ធ្នូ ២០១១), *Agricultural Development and Climate Change: The Case of Cambodia* ជាភាសាអង់គ្លេស
៦៦. តុង គឹមស៊ុន (កុម្ភៈ ២០១២), *Analysing Chronic Poverty in Rural Cambodia Evidence from Panel Data* ជាភាសាអង់គ្លេស
៦៧. Keith Carpenter ដោយមានជំនួយពី ប៊ុន ដូរីណា (កុម្ភៈ ២០១២), *A Basic Consumer Price Index for Cambodia 1993–2009* ជាភាសាអង់គ្លេស
៦៨. រ័ត្ន វឌ្ឍនា (មីនា ២០១២), *Sectoral Composition of China's Economic Growth, Poverty Reduction and Inequality: Development and Policy Implications for Cambodia* ជាភាសាអង់គ្លេស

៦៩. CDRI Publication (March 2012), *Understanding Poverty Dynamics: Evidence from Nine Villages in Cambodia* ជាភាសាអង់គ្លេស

៧០. ហ៊ីង វុត្ថា, សាំង ច័ន្ទហង្ស និង យ៉ាង សុធី (សីហា ២០១២), *Baseline Survey for Socioeconomic Impact Assessment: Greater Mekong Sub-region Transmission Project* ជាភាសាអង់គ្លេស

៧១. គឹម សេដារា និង Joakim Öjendal ជាមួយ ឈួន ណារ៉េត និង លី តឹម (ធ្នូ ២០១២), *A Gendered Analysis of Decentralisation Reform in Cambodia* ជាភាសាអង់គ្លេស

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
អគារលេខ ៥៦ ផ្លូវលេខ ៣១៥
ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា
ទូរស័ព្ទ៖ (៨៥៥ ២៣) ៨៨១ ៣៨៤, ៨៨១ ៧០១, ៨៨១ ៩១៦, ៨៨៣ ៦០៣
ទូរសារ៖ (៨៥៥-២៣) ៨៨០-៧៣៤
អ៊ីមែល៖ cdri@cdri.org.kh
គេហទំព័រ៖ www.cdri.org.kh





តម្លៃ ៨០០០រ

9 789995 052683